ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ អំពើប្រល័យពូជសាសន៍ ៖ ប្រធានបទដ៏មានសារសំខាន់បំផុត

◆ អន្លង់វែង ៖ ទស្សនៈអ្នកខាងក្រៅ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៩៣ ខែមករា ឆ្នាំ២០១៦

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៩៣ ខែមករា ឆ្នាំ២០១៦


## មាតិកា


◆ អំពើប្រល័យពូជសាសន៍ ៖ ប្រធានបទដ៏មានសារសំខាន់ ....................... ១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព សឹម សាត ផ្នែកថាមពល ....................................៣

◆ ពង្រឹងគោលជំហរសមូហភាពនៃវណ្ណៈអធនឲ្យខ្លាំងក្លា .............................៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ដំណើរជីវិតរបស់ មាស ផល ....................................................១៤

◆ ហៀបនឹងស្លាប់ដោយសារប្រទ្បំ ..................................................២០

◆ ចូលខ្មែរក្រហមដោយសារកំហឹង ................................................២២

◆ កន្លែងមួយដែលស្ទើរតែត្រូវបានបំភ្លេច..........................................២៤

◆ ពិព័រណ៍ខ្មែរក្រហមនៅវត្តថ្មី សៀមរាប..........................................២៧

◆ ការប៉ះទង្គិចរវាងយោធាខ្មែរក្រហម និងកងទ័ពវៀតណាម .................២៩

◆ ការយល់ដឹងរបស់សិស្សពីប្រវត្តិសាស្ត្រកម្ពុជាប្រជា .........................៣២

◆ ប្រវត្តិសាស្ត្រខ្មែរក្រហមនៅតែមានសារសំខាន់សម្រាប់.....................៣៤

◆ ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី ..........................៣៦

**ផ្នែកច្បាប់**

◆ សក្ខីកម្ម និងការថ្លែងទុក្ខសោករបស់ ដួង អឿន..............................៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ អន្លង់វែង ៖ ទស្សនៈអ្នកខាងក្រៅ...............................................៤៨

◆ សេចក្តីតបនៃសម្តេចព្រះមហាអរិយវង្សទៅនឹងសំណួរ ......................៥២

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ រសាត់តាមខ្យល់ ......................................................................៥៥





ជនរងគ្រោះនៅមន្ទីរសន្តិសុខស-២១


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះ*** ៖ *វេង សៀងហៃ, ភាន់ផាន់ ពោដារ៉ា, ចាន ប្រាថ្នា, អេង កុកថាយ, វៃ្តឌីស្ទេរ ហ្វេដួរ៉ូវ, សម្តេចព្រះមហាអរិយវង្ស សោរ័ ចន្ទថុល្ល និង ប៉ុកប៉ុន សូម៉ាដ* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ *ទាវ សារៈមុនិន្ទ* ***អ្នកបកប្រែ*** ៖ *សុភ័ក្ត្រ ភាណា* ***និពន្ធនាយកទូទៅ*** ៖ *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក*** ៖ *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ*** ៖ *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ*** ៖ *ឆេង វើង និង សន ល័ក្ខ* Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# អំពើប្រល័យពូជសាសន៍ ៖ ប្រធានបទដ៏មានសារសំខាន់បំផុតចំពោះពិភពលោកយើង

នៅក្នុងមករាខែនេះ គឺជាទិវារំឭកការចងចាំជាអន្តរជាតិអំពីការសម្លាប់រង្គាល ។ ទិវានេះគឺជាប្រធានបទដ៏មានសារសំខាន់បំផុតចំពោះពិភពលោករបស់យើងបច្ចុប្បន្ន ។ យើងត្រូវតែចងចាំថា យើងនឹងអើពើចំពោះបញ្ហានេះគ្រប់ពេលវេលា ។

អំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងលើជនជាតិជ្វីសនៅអឺរ៉ុប និងក្រុមជនជាតិភាគតិចស្លូតត្រង់ដទៃទៀតដោយឧក្រិដ្ឋជនពិភពលោក ជាអ្នកបំផុស និងដាក់ចេញដោយរដ្ឋអាល្លឺម៉ង់ពីចន្លោះឆ្នាំ១៩៣៣ ដល់ឆ្នាំ១៩៤៥ ហើយនឹងដែលណែនាំដល់ពិភពលោកនូវគំរូថ្មីមួយនៃប្រសិទ្ធភាពរបស់រចនាសម្ព័ន្ធជ្រុលនិយមនៅក្នុងវិទ្យាសាស្ត្រនៃការបំផ្លាញជីវិតមនុស្សដែលមានលក្ខណៈជាប្រព័ន្ធ ។ បើទោះជាមោឃភាពនៃប្រវត្តិសាស្ត្រត្រូវបានរំលេចឡើងដោយឧទាហរណ៍ដ៏ព្រឺព្រួចនៃអំពើប្រល័យពូជសាសន៍ និងយុទ្ធនាការកាប់សម្លាប់ទ្រង់ទ្រាយធំមានលក្ខណៈជាប្រព័ន្ធបង្កឡើងដោយមនុស្សមួយក្រុមដែលប្រឆាំងជាមួយអ្នកដទៃយ៉ាងណាក្តី ក៏គំរូដ៏មានប្រសិទ្ធភាពដែលបានរៀបចំឡើង និងប្រើប្រាស់ដោយរបបណាហ្ស៊ី ធ្វើឲ្យមានការភ្ញាក់ផ្អើលដល់មនសិការរួមនៃមនុស្សជាតិ ។

ដូចនៅក្នុងករណីព្រឹត្តិការណ៍ប្រល័យពូជសាសន៍ និងកាប់សម្លាប់រង្គាលដទៃទៀត កំណត់ត្រាទទួលស្គាល់ដឹងត្រូ និងឆ្លើយតបរបស់សហគមន៍អន្តរជាតិចំពោះការប្រព្រឹត្តឃោរឃៅដោយអ្នកទាំងនេះ នៅតែមិនទាន់ជោគជ័យ ។ នៅស្ទើរគ្រប់ករណីទាំងអស់ជាពិសេសនៅរយៈពេល១០០ឆ្នាំកន្លងមក ប្រព័ន្ធត្រួតពិនិត្យអន្តរាគមន៍ដែលទាន់ពេល និងមានសារសំខាន់មានលក្ខណៈយឺតយ៉ាវ និងមិនមានប្រសិទ្ធភាព ។ លទ្ធផលនៃភាពអប្រសិទ្ធភាពលើ



រូបរាប់ពីឆ្វេង ៖ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា, ជូលីន និង សេរ៉ា អ៊ីង សិល្បៈករ ពិភាក្សាគ្នាអំពីការបង្កើតវិទ្យាស្ថានអចិន្ត្រៃយ៍ស្លឹករឹត នៅវិទ្យាស្ថានជាតិអប់រំ ។

ផ្នែកនៃសហគមន៍អន្តរជាតិនេះ ជាលទ្ធផលបានបង្កើតឲ្យមានអំពើហិង្សាដែលឃោរឃៅ ទារុណកម្ម ភាពខ្វោចផ្សា និងការបាត់បង់ជីវិតលើសពីអ្វីដែលគួរកើតមាន ។ លើសពីនេះទៅទៀត បរាជ័យដែលកើតមានជាបន្តបន្ទាប់ក្នុងការរៀបចំ និងអនុវត្តនូវការឆ្លើយតបមួយដែលទាន់ពេល និងមានសារសំខាន់ បានកើតមានម្តងហើយម្តងទៀតដូចដែលខ្ញុំបានលើកឡើងអំពីការកាប់សម្លាប់នៅតាមដងវិថីនានានៃប្រទេសស៊ីរី ។ ក្រៅពីធនធានដ៏ធំសម្បើមរបស់ខ្លួន សហគមន៍អន្តរជាតិ នៅតែបន្តការបរាជ័យដែលបណ្តាលឲ្យការសម្លាប់រង្គាលបន្តឡើងដោយមនុស្សជាតិ កើតមានឡើងចំពោះមនុស្សជាតិ ។

រំព្ញកអំពីជនរងគ្រោះពីប្រវត្តិសាស្រ្ត នៅក្នុងប្រទេសកម្ពុជា យើងបានចាប់ផ្តើមប្រតិបត្តិការដោយមានជំនួយពីសំណាក់រាជរដ្ឋាភិបាលរបស់យើង និងអ្នកដទៃទៀត លើបេសកកម្មប្រវត្តិសាស្រ្តដែលមិនត្រឹមតែធ្វើការទទួលស្គាល់នូវអ្វីដែលយើងបាត់បង់ដោយសារតែយើងគ្មានជម្រើស ។ ថ្មីៗនេះ យើងបានផ្តួចផ្តើមគម្រោងមួយដើម្បីបង្កើតជាវិទ្យាស្ថានស្លឹករឹត ដែលជាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្រ្តៃយ៍ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា (ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន) ដែលជាគម្រោងដ៏អង់អាចនិងពោរពេញដោយមហិច្ឆតាក្នុងគោលបំណងផ្សះផ្សាកេរដំណែលបង្អិនបង្អោចដោយរបបព្រៃផ្សៃខ្មែរក្រហមប្រល័យពូជសាសន៍ដែលមានអាយុកាលប្រមាណ៤ឆ្នាំជាមួយនឹងកេរដំណែលបេតិកភណ្ឌវប្បធម៌ដ៏ល្អប្រណិតដែលមានអាយុកាលរាប់សតវត្សរ៍របស់កម្ពុជា ។ ផ្តោតលើតម្លៃមិនសាបសូន្យនៃយុត្តិធម៌ ការចងចាំ និងការផ្សះផ្សា វិទ្យាស្ថានស្លឹករឹត នឹងរួមបញ្ចូលមុខងារនៃសារមន្ទីរនៃការចងចាំ មជ្ឈមណ្ឌលស្រាវជ្រាវ និងគ្រឹះស្ថានឧត្តមសិក្សាដែលផ្តោតលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបណ្ណសារដ្ឋានឯកសារខ្មែរក្រហម ព្រមទាំងបណ្ណាល័យស្រាវជ្រាវដោយអមជាមួយនឹងមជ្ឈមណ្ឌលព័ត៌មាន ។ ដោយធ្វើការជាមួយនឹងអ្នកជំនាញនៅសារមន្ទីរសហរដ្ឋអាមេរិកដើម្បីការចងចាំអំពីហូឡូខស្ត៍ និងសាកលវិទ្យាល័យនានាទូទាំងពិភពលោក យើងនឹងបង្កើតឲ្យមានកម្មវិធីសិក្សាកម្រិតឧត្តមថ្មីមួយ ។ ក្នុងចំណោមប្រធានបទទាំងអស់ កម្មវិធីនេះនឹងលើកឡើងអំពីយុទ្ធសាស្រ្តដែលសហគមន៍អន្តរជាតិប្រើប្រាស់ដើម្បីទទួលស្គាល់ឲ្យបានទាន់ពេលវេលាអំពីតម្រុយនៃការបង្កើតឲ្យមាននូវសកម្មភាពឧក្រិដ្ឋកម្មដ៏ឃោរឃៅ និងអន្តរាគមន៍ដែលឆាប់រហ័សទាំងផលប៉ះពាល់ បំផ្លិចបំផ្លាញ និងជានិរន្តរ៍ ។ ខ្ញុំសូមឲ្យយើងទាំងអស់ប្រមូលផ្តុំគ្នា ដើម្បីចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងជាប្រវត្តិសាស្រ្តនេះ ។

ខ្ញុំសរសេរអត្ថបទនេះនៅក្នុងថ្ងៃនេះ គឺមិនត្រឹមតែដើម្បីគោរពដល់ជីវិតដែលបានបាត់បង់ ព្រមទាំងការចងចាំមិនសាបសូន្យរបស់អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍នៅកម្ពុជា និងការសម្លាប់រង្គាលនៅទីដទៃទៀតតែប៉ុណ្ណោះទេ ប៉ុន្តែចំពោះមនុស្សរាប់សិបលាននាក់នៅក្នុងពិភពលោក ។ ខ្ញុំនៅទីនេះ និងកន្លែងដទៃទៀត ដើម្បីចងចាំអំពីការបាត់បង់របស់ជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ និងទទួលដឹងឮអំពីភាពគ្មានកំហុសរបស់ជនរងគ្រោះទាំងអស់ ។ **ឆាំង យុ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្រ្ត

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# ចម្លើយសារភាព សឹម សាត ផ្នែកថាមពល

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D២១២៦៣*

តាមឯកសារចម្លើយសារភាពលើកទី២ របស់ សឹម សាត ធ្វើការនៅខាងថាមពល បានសារភាពពីសកម្មភាពដែលខ្លួនបានធ្វើការទាក់ទងជាមួយមនុស្សចំនួនបួននាក់មានឈ្មោះ ផល, អាចារ្យកង, ដាន់ និង សំ ។ ចម្លើយសារភាពលើកទី២ របស់ សឹម សាត ត្រូវបានវាយអង្គុលីលេខចម្លងសាឡើងវិញ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ដោយឈ្មោះ ផល្លី ហើយសាមីខ្លួនបានផ្តិតមេដៃ និងមានសរសេរអក្សរ ដោយដៃនៅពីក្រោមឈ្មោះ សឹម សាត ថា "បានអានសាថ្មី ឃើញត្រឹមត្រូវតាមអត្ថបទដែលខ្ញុំបានសរសេរហើយ ។ ថ្ងៃទី១៨-១១-៧៦ ស.ស១" ។ ខាងក្រោមនេះជាសេចក្តីដកស្រង់ទាំងស្រុងអំពីសកម្មភាពរបស់ សាត ដែលបានធ្វើសកម្មភាពទាក់ទងជាមួយអ្នកទាំងបួនដែលបានរៀបរាប់ឈ្មោះខាងលើដូចតទៅ៖

**១) សកម្មភាពទាក់ទងជាមួយអា ផល ៖**

ឆ្នាំ១៩៧២ ក្រោយពេលដែលអង្គការខទ្ទេសនាមឲ្យមកធ្វើការងារនៅផ្នែកពាណិជ្ជកម្មភាគ ដែលមានអា ឆែម ទទួលខុសត្រូវ ។ អាផល ពេលនោះ វានៅមន្ទីរពេទ្យភាគត្រពាំងអណ្តើក ចុះឡើងបើកសម្ភារៈ ថ្នាំពេទ្យ ដែលមានអាចារ្យកង ជាប្រធានមន្ទីរពេទ្យភាគ ។ តាមការពិនិត្យផ្ទាល់ខ្លួនខ្ញុំ ឃើញសកម្មភាពវាពេលនោះទាំងការនិយាយស្តី អាកប្បកិរិយា ការរស់នៅខុសសីលធម៌បដិវត្តន៍ ។ ឧទាហរណ៍ ៖ ពេលមកបើកថ្នាំម្តងៗ វាទាមទាររកស្រាផឹក រកតែនំនែក ។ វានិយាយណែនាំ អូសទាញមិត្តយើងថា "ធ្វើបដិវត្តន៍ចង់បានផ្អែតឆ្អាញ់ រស់នៅស្រួល" ។ វានិយាយសរសើរថា "នៅវៀតណាម



របងមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អង្គការបានចាប់បញ្ជូនអ្នកទោសប្រមាណជាង១៤.០០០នាក់ដែលត្រូវបានចោទប្រកាន់ថាក្បត់ មកឃុំឃាំង ធ្វើទារុណកម្ម និង សួរចម្លើយនៅមន្ទីរសន្តិសុខនេះ ។ អ្នកទោសស្ទើរតែទាំងអស់ត្រូវបានសម្លាប់ បន្ទាប់ពីឆ្លងកាត់ការសួរចម្លើយរួច ។

មានហាងលក់គ្រប់មុខ ចង់ប្រើអី បាននោះ ចង់ស៊ីអី ស៊ីនោះ« ។

ឆ្នាំ១៩៧៤ អង្គការបានចាត់តាំងឲ្យខ្ញុំ ទៅទាក់ទងទិញដូរនៅរោងវែង កំពង់ត្រាច ។ វា (ផល) បានទៅទាក់ទងខ្ញុំ ឲ្យជួយទិញថ្នាំពេទ្យ ព្រមទាំងផ្ញើទិញសម្ភារៈសម្រាប់ផ្ទាល់ខ្លួនវាទៀតផង ដូចជា ក្រណាត់ តែ ស្ករ ជាដើម ។

ចំពោះខ្លួនខ្ញុំ ដោយគោលជំហរមិនរឹង ក៏ចេះតែទោរទន់តាមការអូសទាញរបស់វា ទិញសម្ភារៈជាឯកជន មិនគោរពតាមការណែនាំរបស់អង្គការ ។ នៅឆ្នាំ១៩៧៤នេះ (មិនចាំខែ) ដែលខ្ញុំបានឮមិត្តយើង (មិនចាំឈ្មោះ) ថា អាផល និង អាងុយ រត់គេចខ្លួនពីមន្ទីរពេទ្យ ពេលខ្ញុំមកត្រពាំងអណ្ដើក កន្លែងឃ្លាំងទុកសម្ភារៈ ។

## ២) សកម្មភាពទាក់ទងជាមួយ អាចារ្យ កង

នៅឆ្នាំ១៩៧២ អាចារ្យ កង ជាប្រធានសាខាបក្សគ្រប់គ្រងសាខាមន្ទីរពេទ្យផង គ្រប់គ្រងពាណិជ្ជកម្មផង ។ គាត់បានទៅមកបើកថ្នាំខាងពាណិជ្ជកម្មជាញឹកញាប់ដែរ នៅត្រពាំងអណ្ដើក ។ ពេលនោះខ្ញុំជាអ្នកកាន់បញ្ជីចំណូលចំណាយសម្ភារៈក្នុងឃ្លាំង ការសម្រេចចែកចាយនៅលើ តាឆែម ។ តាមការពិនិត្យរបស់ខ្ញុំ គាត់ (អាចារ្យកង) ជាអ្នកលេងសើចច្រើនដែរ ហើយចូលចិត្តហូបតែ ។ គាត់ទៅមកម្ដងៗ ត្រូវឆុងតែឲ្យចត់ ។ ខ្ញុំពុំសូវបានទៅមកមន្ទីរពេទ្យដែលគាត់គ្រប់គ្រងទេ ។ ទៅតែពេលរៀនសូត្រជាវគ្គ បុណ្យខួបរបស់បក្ស ។ តាមខ្ញុំចាំ ដោយពាណិជ្ជកម្មទាក់ទងទិញដូរមិនគ្រប់គ្រាន់ គាត់បានចុះទៅរៀបចំទាក់ទងទិញខាងព្រៃល្ហាដោយខ្លួនឯង ។ ប៉ែកខាងត្បូងនៅលក ស្រុកកំពង់ត្រាច គាត់យូរៗទៅម្ដង ទាក់ទងទិញថ្នាំ ។ នៅឆ្នាំ១៩៧៤ ជួបគ្នាជាមួយខ្ញុំ នាំគ្នាហូបគុយទាវ និងឡាប់យៃរ នៅផ្សារលកម្ដងៗ ហើយណែនាំខ្ញុំឲ្យខិតខំទាក់ទងទិញថ្នាំពេទ្យឲ្យបានច្រើន ព្រោះត្រូវបើកឲ្យសមរភូមិច្រើន ។ ជាមួយអាចារ្យកង ខ្ញុំមិនដែលបានរស់នៅស្និទ្ធស្នាលជាមួយគាត់ទេ រហូតដល់រំដោះទាំងស្រុង បែកគ្នារហូត ។ កាលខ្ញុំនៅធ្វើការរោងចក្រប្រេងកាត គាត់បានទៅលេងម្ដង តែមិនបានជួបខ្ញុំទេ ជួបស.ម ហុក ។ ក្នុងរយៈខែមុន ខ្ញុំបានជួបគាត់ម្ដងនៅមន្ទីរចាត់ការថាមពល ខ្ញុំគ្រាន់តែចាប់ដៃសួរសុខទុក្ខគាត់ ហើយខ្ញុំទៅធ្វើការងារទៅ ឃើញគាត់នៅនិយាយជាមួយមិត្ត ហុក តាមខ្ញុំចាំទាក់ទងសុំសំបុត្រស្នើចេញសម្រាប់ភ្ញៀវចិន នៅកំពង់សោម ។

## ៣) សកម្មភាពទាក់ទងជាមួយ ផាន់

ខ្ញុំបានជួប និងស្គាល់ ផាន់ ប្រហែលនៅចុងឆ្នាំ១៩៧៣ ឬដើមឆ្នាំ១៩៧៤ ក្នុងវគ្គសិក្សាមួយរបស់ភាគជាលើកដំបូង ។ គាត់ (ផាន់) ទទួលភារកិច្ចខាងពាណិជ្ជកម្មភាគ នៅកំពង់សីលា តាមការចាត់តាំងរបស់គណៈកម្មការពាណិជ្ជកម្មភាគ ។ ខ្ញុំបានឃើញគាត់មកធ្វើការជាមួយមិត្ត ហុក ជាគណៈកម្មការពាណិជ្ជកម្មភាគនៅរោងវែង ។ ការទាក់ទងរវាងខ្ញុំនិងគាត់ ជាការទាក់ទងធ្វើការងារជាធម្មតាខាងពាណិជ្ជកម្ម ការនាំទំនិញចេញចូល និងតម្លៃលក់ចេញ ទិញចូល ដើម្បីផ្លាស់ប្ដូរពិសោធន៍គ្នា ។

ក្រោយរំដោះ អង្គការបានចាត់តាំងគាត់ឲ្យនៅខាងនេសាទរដ្ឋ ។ ខ្ញុំនៅធ្វើការងាររោងចក្រប្រេងកាត ក៏ពុំសូវបានជួបនឹងគាត់ដែរ ព្រោះគាត់នៅតែក្នុងសមុទ្រជាមួយកប៉ាល់ចាប់ត្រី ។ យូរៗម្ដងខ្ញុំបានឃើញគាត់ជិះម៉ូតូនៅក្រុងកំពង់សោម ។

ពេលខ្ញុំមកនៅធ្វើការងារនៅមន្ទីរចាត់ការថាមពល ក្នុងខែកញ្ញា ឃើញគាត់មករក ស.ម ឆុន ហូបបាយជាមួយគ្នាម្ដងៗ ។ ខ្ញុំគ្រាន់តែចាប់ដៃ និយាយសួរសុខទុក្ខគ្នាធម្មតា ។

ក្រោយមកទៀត ខ្ញុំបានឃើញគាត់បើកឡាន "កាត់សង់កាត់" ពណ៌ស្លឹកឈើ មកមន្ទីរចាត់ការថាមពល ជួបស.ម ឆុន ។ លើកក្រោយនេះ ខ្ញុំពុំបានទៅជួបគាត់ទេ ។

ជាមួយ ផាន់ តាំងពីបានស្គាល់គ្នាមក ខ្ញុំពុំដែលបាននិយាយលេងស្និទ្ធស្នាលជាមួយគាត់ក្រៅពីការងារទេ ។

## ៤) សកម្មភាពទាក់ទងជាមួយ សំ

ខ្ញុំស្គាល់ សំ លើកដំបូងនៅមន្ទីរភាគក្នុងវគ្គសិក្សាមួយនៅឆ្នាំ១៩៧៣-១៩៧៤ ។ ក្រោយមក ក្នុងឆ្នាំ១៩៧៤ ដដែល អង្គការបានចាត់តាំងឲ្យគាត់ទៅបំពេញភារកិច្ចនៅស្រែអំបិលកែប ។ កាលនៅស្រែអំបិលកែប គាត់បានទៅមកទាក់ទងរកសម្ភារៈសម្រាប់អង្គភាពស្រែអំបិល ។

ក្រោយរំដោះ ខ្ញុំបានឮដំណឹងពីមិត្តយើងថា អង្គភាពបានដកឲ្យគាត់ទៅធ្វើស្រែនៅបែកចាន ដោយមានវិបត្តិទាក់ទងគ្រួសាររបស់របស់គាត់ ដែលទើបចេញពីភ្នំពេញមកនៅក្នុងអង្គភាព ដោយមិនបានស្នើមតិអង្គការ ។

ក្រោយរំដោះ ខ្ញុំបានជួបគាត់នៅពេលបើកវគ្គរៀនសូត្រមួយ

នៅកែប សម្រាប់អង្គភាពស្រែអំបិល និងអង្គភាពពាណិជ្ជកម្មរបស់គណៈភាគ ។

តាំងពីពេលនោះរហូតមក ខ្ញុំបានជួបគាត់ម្តង ប្រហែលនៅខែមេសា ឬខែឧសភា ដែលខ្ញុំមកនៅបំពេញភារកិច្ចនៅមន្ទីរចាត់ការថាមពល នៅកន្លែងធ្វើអាងដាក់ប្រេង នៅមុខផ្សារបរទេស ។ ខ្ញុំបានសួរគាត់ថា «ឥឡូវធ្វើការនៅឯណា?» គាត់ថា «ខ្ញុំនៅខាងអគ្គិសនី» ហើយខ្ញុំក៏លាគាត់ត្រឡប់មកមន្ទីរចាត់ការវិញ ។

ចំពោះរាល់ការខុះខាត ជាទស្សនៈ ជាគោលជំហរ ជាសតិអារម្មណ៍ ជាអំពើប្រព្រឹត្តទាំងឡាយដែលមិនសមស្របតាមមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំសូមសារភាពជម្រាបបក្សដោយស្មោះត្រង់ ឥតវៀចវេរ ។ ខ្ញុំមានការឈឺចាប់ និងសោកស្តាយយ៉ាងខ្លាំង នៅរាល់ការខុះខាតទាំងឡាយនេះ ក្នុងជីវិតបដិវត្តន៍របស់ខ្ញុំ ព្រោះតែខ្ញុំធ្វេសប្រហែស បណ្តែតបណ្តោយខ្លួន មិនប្រុងប្រយ័ត្ន បដិវត្តន៍ខ្ពស់ជាប់ជានិច្ច ទុកឲ្យខ្មាំងជាសក្តិភូមិ នាយទុន វាស៊ីរូង និងអូសទាញសតិអារម្មណ៍ ទស្សនៈ និងគោលជំហររបស់ខ្ញុំ ។

អំណែះតទៅ ខ្ញុំសូមធ្វើសច្ចាប្រណិធានចំពោះមុខបក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ និងភ្លឺស្វាង មហាអស្ចារ្យថា៖

ប្តេជ្ញាដើរតាមមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា គោរព និងស្រឡាញ់បក្សកុម្មុយនីស្តកម្ពុជារៀងរហូតលុះត្រាអវសាន ដោយស្មោះត្រង់អស់ពីចិត្តពីថ្លើម ។

ប្តេជ្ញាកម្ចាត់នូវរាល់ការខុសឆ្គងទាំងឡាយកន្លងមក ជាទស្សនៈ ជាសតិអារម្មណ៍ ជាគោលជំហរ ជាអំពើប្រព្រឹត្តរបស់ខ្ញុំ ដែលមិនសមស្របតាមមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា ។

ប្តេជ្ញាកសាងខ្លួនជាថ្មីម្តងទៀត ដោយអនុវត្តឲ្យត្រឹមត្រូវតាមមាគ៌ានយោបាយ មាគ៌ាសតិអារម្មណ៍ និងមាគ៌ាចាត់តាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយក្តីជំនឿជឿជាក់ គោរពស្រឡាញ់ កក់ក្តៅរកទីបំផុតគ្មាន ។

ទីបំផុត ខ្ញុំសូមសន្យាចំពោះមុខបក្សកុម្មុយនីស្តកម្ពុជាថា៖ បើថ្ងៃក្រោយខ្ញុំមិនស្មោះត្រង់ វៀចវេរ មិនដើរតាមមាគ៌ា «បក្សកុម្មុយនីស្តកម្ពុជា» ខ្ញុំសូមទទួលទោសតាមវិន័យរបស់បក្សកំណត់ និងប្តេជ្ញាកែប្រែនូវការខុសឆ្គង ខុះខាតទាំងឡាយជាបន្ទាន់ ដោយកម្ចាត់ចោលឲ្យអស់រលីងពីក្នុងខ្លួននូវកម្មសិទ្ធិឯកជនគ្រប់ប្រភេទ ទាំងសម្ភារៈ សិទ្ធិអំណាច សតិអារម្មណ៍ និងមនោសញ្ចេតនា ។ កសាងកម្មសិទ្ធិសមូហភាព ឲ្យបានរឹងប៉ឹងធំទូលាយ និងកសាងធាតុវណ្ណៈ កម្មកររបស់បក្ស ឲ្យបានរឹងប៉ឹងដាច់ខាត តាមមាគ៌ាថ្មីនៃបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមរបស់បក្សកុម្មុយនីស្តកម្ពុជា ។

សូមបក្សជាទីគោរព អាធ្យាស្រ័យ និងអនុគ្រោះដល់ខ្ញុំចំពោះការខុសឆ្គង ខុះខាត ដែលខ្ញុំបានភ្លើតភ្លើន ភ្លេចភ្លាំងប្រព្រឹត្តកន្លងមក ។

ខ្ញុំមានជំនឿជឿជាក់ និងគោរពតែលើបក្សកុម្មុយនីស្តកម្ពុជាតែមួយគត់ គ្មានបក្សណាផ្សេងទៀត ដូចបក្សបានខ្ទេចខ្ទីសនាមក្នុងមីទីងបុណ្យខួបឆ្នាំទី១៦ បញ្ជាក់ពីហេតុផល អាយុបក្សកុម្មុយនីស្តកម្ពុជា និងបញ្ជាក់អំពីមាគ៌ាធ្វើបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យយើង ។

កាលពីខ្ញុំនៅបរទេស ខ្ញុំឃើញដូចជាមិនសូវមានឯកភាពទាំងទស្សនៈ ទាំងគោលជំហរ រវាងបក្សនៅខាងក្រៅ ហាណូយ និងបក្សយើងខាងក្នុងប្រទេស ។ ក្រោយការរៀនសូត្រហើយ ខ្ញុំបានប្រកាន់យកអាកប្បកិរិយាតាមមាគ៌ាបក្សខាងក្នុងប្រទេស ដែលបក្សបានខ្ទេចខ្ទីសនាមពីទស្សនៈ សភាពការណ៍ និងមាគ៌ាផ្សេងៗរបស់បក្ស ខាងសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច ។

ទោះបីនៅពេលនោះជាលើកដំបូង ដែលខ្ញុំបានរៀនសូត្រពីមាគ៌ាបក្ស ការយល់ជ្រួតជ្រាប ក៏មានកម្រិតទាប តែខ្ញុំយកអាកប្បកិរិយា តាមបក្សខ្ទេចខ្ទីសនាមក្នុងវគ្គរៀនសូត្រ និងធ្វើជីវទស្សន៍ ។

កាលខ្ញុំនៅធ្វើការក្នុងរណសិរ្ស ជាលេខាទូតនៅហាណូយ ខ្ញុំមិនបានយល់ពីភារកិច្ចអ្វីទេ ។ ភារកិច្ចសំខាន់ នៅពេលនោះ គឺខ្ញុំយកព័ត៌មានតាមវិទ្យុផ្សាយ ហើយបោះផ្សាយជាដំណឹងចែកដល់គ្រប់ស្ថានទូត ។

ក្រោយមកទើបបក្សហៅខ្ញុំទៅធ្វើការងារជាជំនួយការនៅជាប់ជាមួយបក្សរហូតដល់ត្រឡប់មកប្រទេសវិញ ។

***កំណត់ចំណាំ*** ៖ *ចម្លើយសារភាពរបស់ សឹម សាត ត្រូវបានធ្វើឡើងជាច្រើនលើកច្រើនសារដោយឆ្មាំគុក ប៉ុន្តែខ្ញុំរកឃើញតែចម្លើយលើកទីពីរដែលមានកម្រាស់៧ទំព័រប៉ុណ្ណោះ ។*

**ឆេង ខេង**

# ពង្រីងគោលជំហរសម្ងាត់នៃឧណ្ណះអធនឱ្យខ្លាំងក្លាថែមទៀត ដើម្បីឯកភាពគ្នា ក្នុងការកសាងសង្គមនិយមតាមផែនការរបស់បក្ស

*ដកស្រង់ចេញពីឯកសារទង់បដិវត្តន៍លេខ៨ ខែសីហា ឆ្នាំ១៩៧៦*

***១) សភាពការណ៍បដិវត្តន៍សង្គមនិយម នៅប្រទេសយើងក្នុងពេលបច្ចុប្បន្ន***

*និយាយពីបដិវត្តន៍សង្គមនិយមនៅក្នុងប្រទេសយើងបច្ចុប្បន្ននេះគឺនិយាយទាំងផ្នែកនយោបាយសតិអារម្មណ៍ ទាំងផ្នែកចាត់តាំង ទាំងផ្នែកចលនាជាក់ស្តែង ។*

*និយាយរួម សភាពការណ៍បដិវត្តន៍សង្គមនិយម នៅក្នុងប្រទេសយើង មិនថយក្រោយទេហើយក៏មិននៅនឹងថ្កល់ដែរ ។ វាវិវត្តមកចម្រើនជាលំដាប់ ក្នុងសភាពល្អ នឹងន មានមូលដ្ឋានរបស់វា ហើយមូលដ្ឋាននៃបដិវត្តន៍ សង្គមនិយមនេះទៀត ក៏ពង្រឹង និងពង្រីកខ្លួនវាជាលំដាប់ដែរ ។*

***១.១) អំពីនយោបាយ និងសតិអារម្មណ៍ ៈ***

*និយាយដោយឡែក ខាងនយោបាយ និងសតិអារម្មណ៍នៅទីក្រុង និងជនបទ មានទិដ្ឋភាពដូចតទៅ ៈ*

- *នៅទីក្រុង មានអគ្គភាពផ្សេងៗរបស់រដ្ឋ ។ ជាសភាពការណ៍*



កម្មករនៅរោងចក្រ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យកំពុងកែច្នៃ និងជួសជុលម៉ាស៊ីនបូមទឹក

រួម សតិអារម្មណ៍ខាងការតស៊ូកម្ចាត់របបចាស់ សំណល់ចាស់របស់សក្តិភូមិ-ម្ចាស់ដី នាយទុន ចក្រពត្តិនិយម អាណានិគមនិយមផ្សេងៗ បានលឿនមួយកម្រិតថែមទៀត ។ ប្រៀបធៀបនឹងដើមឆ្នាំ១៩៧៦ និងពាក់កណ្តាលឆ្នាំ១៩៧៦ មកឥឡូវនេះ យើងមានសន្ទុះចម្រើនច្រើន ។ យើងខិតខំតស៊ូកម្ចាត់ដោយជ្រះស្រឡះ ដោយជ្រះថ្លាជាងពីមុនច្រើន ។ ការតស៊ូមានសភាពមោះមុត ខ្លាំងក្លា មិនសម្រុះសម្រួល ដាច់ខាតជាងមុន ។

ដូច្នេះបានជា នៅគ្រប់អង្គភាពជាទូទៅ ក្នុងកងទ័ពបដិវត្តន៍ក្តី ក្នុងកម្មករតាមរោងចក្រក្តី មានការតស៊ូរវាងបដិវត្តន៍ និងមិនបដិវត្តន៍ រវាងបដិវត្តន៍ និងប្រឆាំងបដិវត្តន៍ រវាងការរីកចម្រើន និងការធាក់ក្រាញថយក្រោយ ។

ដូច្នេះហើយ បានជាយើងសម្រិតសម្រាំងនូវទស្សនៈ នូវគោលជំហរ នូវសតិអារម្មណ៍ខាងបដិវត្តន៍សង្គមនិយមនេះបានច្រើនជាងពីមុន ហើយទន្ទឹមនេះ កម្ចាត់សតិអារម្មណ៍មិនសង្គមនិយមបានច្រើន ។ ឥឡូវយើងកំពុងបន្តប្រយុទ្ធតទៅទៀត ។ ការដែលយើងពេញចិត្ត គឺការភ្ញាក់រឭករបស់ជួរបដិវត្តន៍យើង ដែលចាប់អារម្មណ៍លើបដិវត្តន៍សង្គមនិយមខ្លាំងក្លាថែមទៀត ហើយប្រុងប្រយ័ត្នជាប់ដើម្បីប្រយុទ្ធ ដើម្បីវាយសម្រុកជាបន្តបន្ទាប់ ។

◆ ការរីកចម្រើននៃបដិវត្តន៍សង្គមនិយមរបស់យើង មិនមែនកើតឡើងដោយចៃដន្យ ដោយកាលៈទេសៈ ឬដោយកត្តាសត្យានុម័តិអ្វីទេ ។ ការរីកចម្រើននេះ គឺកើតឡើងពីចលនាតស៊ូបដិវត្តន៍សង្គមនិយមជាក់ស្តែង ។ ការភ្ញាក់រឭកខាងសតិអារម្មណ៍បដិវត្តន៍សង្គមនិយម ក្លាយទៅជាកម្លាំងប្រយុទ្ធខ្លាំងក្លា ។ គ្រប់អង្គភាពបំពាក់អាវុធនេះបានក៏មានសន្ទុះកម្លាំងខ្លាំងក្លា ប្រុងប្រៀបខ្លួនប្រយុទ្ធជាប់ពិសេសប្រយុទ្ធតស៊ូរវាងបដិវត្តន៍សង្គមនិយម និងអ្វីដែលមិនមែនជាបដិវត្តន៍សង្គមនិយម ដូចជាខាងសីលធម៌ ការរស់នៅ របៀបរបបធ្វើការងារ ។ ដូច្នេះ អង្គភាពមួយៗក្លាយទៅជាកំពែងយើងរឹងមាំដើម្បីការពារ និងប្រយុទ្ធកម្ទេចនូវសំណល់ចាស់មិនបដិវត្តន៍ ។ នៅក្នុងជួរបក្សយើង ជួរបដិវត្តន៍យើង ខ្លឹមសារជាសំខាន់ហើយ ។ យើងត្រូវពង្រឹង និងពង្រីកវាជាបន្តបន្ទាប់តទៅទៀត ។

◆ គ្រប់បដិវត្តន៍តែងមានទំនាស់ គឺទំនាស់បដិបក្ខ ទំនាស់ផ្ទៃក្នុង និងទំនាស់បន្ទាប់បន្សំ ។ នៅក្នុងបដិវត្តន៍សង្គមនិយម ក៏មានប្រភេទទំនាស់យ៉ាងនេះ ។ តែបើយើងធ្វើបដិវត្តន៍សង្គមនិយមប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំបានល្អ ទោះបីមានទំនាស់យើងនេះក៏ដោយ ក៏យើងដោះស្រាយបានតាមវិធីអប់រំ កសាងជាបន្តបន្ទាប់ ។ សូម្បីតែទំនាស់បដិបក្ខ ក៏យើងដោះស្រាយបាន វាត្រូវសាបរលាបបាត់ទៅវិញ ។ ទំនាស់ផ្ទៃក្នុង ក៏ដូច្នោះ ។ យើងដោះស្រាយបាន ដោយយើងចាត់វិធានការជាបន្តបន្ទាប់ ។ ផ្ទុយទៅវិញ បើយើងមិនរវល់ចេះតែថាបដិវត្តន៍សង្គមនិយមល្អ ហើយទុកឲ្យទំនាស់ផ្ទៃក្នុងវារីកឡើងៗ នោះមួយរយៈកាល វាម្ចាស់ការលើយើងវិញ ។ វានឹងក្លាយទៅជាទំនាស់បដិបក្ខទៅវិញ យើងលំបាកដោះស្រាយកាន់តែខ្លាំង ឬដោះស្រាយពុំបានទៀតផង ព្រោះយើងបាត់គោលជំហរវាយសម្រុក ព្រោះយើងស្ពឹកស្រពន់ មិនហ៊ានប្រយុទ្ធ បាត់ម្ចាស់ការ ។

ឧទាហរណ៍ ៖ ពេលធ្វើបដិវត្តន៍ប្រជាធិបតេយ្យ មានមតិខ្លះថា ចក្រពត្តិអាមេរិកធំ ហើយខ្លាំងក្លាណាស់ យើងប្រទេសតូច វាយពុំឈ្នះវាទេ ។ នេះជាទស្សនៈប្រឆាំងបដិវត្តន៍ ធ្វើឲ្យប្រជាជនយើងស្ពឹកស្រពន់ មិនហ៊ានតស៊ូប្រយុទ្ធនឹងវា ។ តែពេលឥឡូវ មិនចោទបញ្ហានេះទេ ។ ធាតុភាពទំនាស់ មានទិដ្ឋភាពផ្សេង តែវានៅតែបន្តវាយបដិវត្តន៍សង្គមនិយមយើងដែរ ។

ឧទាហរណ៍ ៖ នៅក្នុងសហករណ៍មានសំឡេងថា ៖ «ពេលមុនសប្បាយ ឥឡូវដល់ធ្វើបដិវត្តន៍សង្គមនិយម អស់សប្បាយរលីង» ។ សំឡេងនេះ មានទិដ្ឋភាពពីរ ៖ ឬមួយគេមិនទាន់យល់ យើងត្រូវអប់រំគេ ឬមួយទៀត ជាសកម្មភាពប្រឆាំងជាក់ស្តែង ។ តែទោះជាយ៉ាងណាក៏ដោយ សំឡេងនេះជាធាតុភាពប្រឆាំងបដិវត្តន៍សង្គមនិយម ។

ឧទាហរណ៍មួយទៀត ៖ នៅក្នុងសហករណ៍ មានកម្មាភិបាលខ្លះនិយាយថា «កាលនៅជាឯកជន គោល្អ អត់ស្គមទេ ។ ដល់ពេលឥឡូវធ្វើបដិវត្តន៍សង្គមនិយម គោទៅជាស្គមវិញ ។ នេះជាឧទាហរណ៍បញ្ជាក់ថា កម្មាភិបាលយើងនិយាយខុស មិនទាន់ជ្រួតជ្រាបពីខ្លឹមសារបដិវត្តន៍សង្គមនិយមទេ បែរជាវាយប្រហារបដិវត្តន៍សង្គមនិយម វាយរបបសមូហភាព ហើយការពាររបបចាស់ របបឯកជនទៅវិញ ។ តាមពិត បដិវត្តន៍សង្គមនិយមយើង ដោះស្រាយបញ្ហាប្រជាជនបានជាមូលដ្ឋាន ។ យើងមានការរីកចម្រើនជាអតិបរមាពិតមែន តែយើងនៅមានការលំបាក ឬខ្វះខាតជាបណ្តោះអាសន្នខ្លះ ។

◆ បើបដិវត្តន៍សង្គមនិយមដំណើរការបានល្អ ការកសាងសង្គមនិយម និងការពារប្រទេសក៏បានល្អ និងខ្លាំងក្លា ។ នេះជាសភាពពិតគ្មានស្រពិចស្រពិលទេ ។ នៅក្នុងអង្គភាពមួយ បើនយោបាយសតិអារម្មណ៍ល្អហើយ អង្គភាពនោះ ពិតជាមានកម្លាំងប្រយុទ្ធខ្លាំងក្លា មានព្រំដែនច្បាស់លាស់ រវាងបដិវត្តន៍ និងមិនបដិវត្តន៍ រវាងសមូហភាព និងឯកជន ។ ដូច្នេះ ការភ្ជាក់រឭក មកខាងបដិវត្តន៍សង្គមនិយម មកខាងសមូហភាព ជាបញ្ហាសំខាន់ ។ យើងត្រូវចែកព្រំដែននេះឲ្យច្បាស់ ។ នៅទីណាក៏ដោយ បើយើងអង្គុយខាងសមូហភាពនោះអត់ខុសទេ ។ កុំបែរ ហើយកុំរេទៅខាងឯកជនឲ្យសោះ ។ បើគិតទៅខាងឯកជនហើយ ចង់មិនចង់ យើងឃ្លាតពីសមូហភាព ហើយការពារនាយទុនទៅវិញ ។

ដូច្នេះ ពិតមែនតែយើងទៅលឿនហើយ យើងត្រូវពង្រឹង និងពង្រីកចលនាយើងថែមទៀត ។

◆ តើយើងធ្វើបដិវត្តន៍សង្គមនិយមដើម្បីអ្វី?

គឺដើម្បីទាំងអស់ ដើម្បីកសាងប្រទេសបានរហ័ស ដើម្បីការពារប្រទេសបានរហ័ស និងមានប្រសិទ្ធភាព ហើយដោះស្រាយជីវភាពប្រជាជនបានរហ័ស ។ បើយើងទុកឲ្យសក្តិភូមិ ម្ចាស់ដី នាយទុនវាដោះស្រាយពុំបានទេ ព្រោះវាឈរលើឯកជន ទំនាស់បាក់បែកគ្នា ។ បើយើងឈរលើឯកជន យើងក៏ការពារប្រទេសមិនបានដែរ ។

ដូច្នេះ យើងធ្វើបដិវត្តន៍សង្គមនិយម មិនមែនដើម្បីបដិវត្តន៍សង្គមនិយមទទេទេ គឺមានន័យកសាងប្រទេស ការពារប្រទេស និងដោះស្រាយជីវភាពប្រជាជនឲ្យបានឆាប់រហ័ស ។

**២) អំពីការចាត់តាំង និងចលនា ៖**

ទន្ទឹមនឹងការរីកចម្រើនខាងនយោបាយ សតិអារម្មណ៍ ការចាត់តាំងក៏រីកចម្រើននៅទីក្រុង ក៏ដូចនៅជនបទ ពិសេសនៅជនបទ ។ យើងបានពង្រឹងពង្រីកការចាត់តាំងបានមួយកម្រិតថែមទៀត ហើយបានសម្រិតសម្រាំងជាបន្តបន្ទាប់ ។ ចំណុចដែលគួរចាប់អារម្មណ៍គឺ៖

◆ ម្យ៉ាង ការចាត់តាំងសមូហភាព បានកាន់តែល្អ កម្លាំងសមូហភាពកាន់តែខ្លាំងក្លា ទាំងនៅទីក្រុង ទាំងនៅជនបទ ពិសេសនៅជនបទ ។

◆ ម្យ៉ាងទៀត យើងរៀបចំចាត់តាំងកម្លាំងសមូហភាពកាន់តែមានប្រសិទ្ធភាពជាងមុន ។

ឧទាហរណ៍ ៖ សហករណ៍បានពង្រឹង និងពង្រីកជាមធ្យម ១០០-២០០-៣០០ គ្រួសារ ។ មានសហករណ៍ខ្លះ រហូតដល់ ៥០០ គ្រួសារ ។ នៅទូទាំងប្រទេស សហករណ៍ចាត់តាំងជាភូមិទូទៅ ។ ផែនការបក្សថា ចាត់តាំងឲ្យបានជាភូមិក្នុងឆ្នាំ១៩៧៦ ។ ឥឡូវគឺសម្រេចបាន ។ ទន្ទឹមនេះ ក៏មានចាត់តាំងសហករណ៍ឃុំ មួយចំនួនច្រើនហើយ ។ សហករណ៍ឃុំមាន៨០០-៩០០ រហូតដល់ ១០០០ គ្រួសារ ។

◆ ចំណុចមួយទៀត យើងចាត់តាំងជាកង គឺកងកម្លាំង ទី១ ទី២ ទី៣ និងទី៤ របស់សហករណ៍ ។ ការរៀបចំកម្លាំងយ៉ាងនេះបានបញ្ជាក់ថា សមូហភាពរបស់យើងមានកម្រិតកាន់តែខ្ពស់ ។ ទាល់តែកម្រិតបដិវត្តន៍ សង្គមនិយមខ្ពស់ ទើបដំណើរការយ៉ាងនេះបាន ។ បើឯកជននៅខ្លាំង យើងធ្វើយ៉ាងនេះពុំបានទេ ។ និយាយយ៉ាងនេះ មិនមែនថា យើងគ្មានឧបសគ្គទេ ។ យើងមានឧបសគ្គខ្លះដែរ ។ តែនិយាយជារួម យើងចាត់តាំងបាន ព្រោះតែយើងចាត់តាំងបាន ទើបយើងកសាងសង្គមនិយមបានរហ័ស ។ បើចាត់តាំងពុំបានដូច្នេះទេ យើងកសាងសង្គមនិយមមិនបានរហ័សទេ ។

ឧទាហរណ៍ ៖ កន្លែងខ្លះខ្វះទឹកសាបស្ងួត ។ បើនៅមានកម្មសិទ្ធិឯកជនធ្ងន់ យើងចាត់តាំងកម្លាំងពុំបានទេ ។ ឥឡូវយើងចាត់ចែងកម្លាំង ពីឃុំមួយទៅឃុំមួយ ពីស្រុកមួយទៅស្រុកមួយ ដោះស្រាយសំណាប សន្ទូង និងទឹកបានយ៉ាងងាយ ។ យកសំណាបទៅសាបកន្លែងណាដែលមានទឹកសាបមុន ឬក៏ប្រមូលកម្លាំងច្រើនឃុំ ដើម្បីដោះស្រាយទឹកនៅឃុំណាមួយទៀត ឬស្រុកណាមួយទៀតក៏បាន ។ យើងចាត់តាំងកម្លាំងធ្វើស្រែរាប់ពាន់ រាប់ម៉ឺន រាប់សែនហិកតា តាមស្រុកមួយៗ តាមតំបន់មួយៗ និងតាមភាគមួយៗបាន ។

◆ នេះជាការរៀបចំចាត់ចែងកម្លាំងផលិតកម្មធំ ជាជំហានដំបូង ។ តើមកពីអ្វី? គឺមកពីលក្ខណៈសមូហភាពកម្រិតខ្ពស់របស់យើង ។ ដូច្នោះបានជាមានចលនាខ្លាំងក្លា ។ មិនងាយរកឲ្យមានចលនាយ៉ាងនេះទេ ។

ប្រជាជនជាអ្នកសម្រេច ។ យើងមានជំនឿជាមូលដ្ឋាន ។ លំបាកនៅត្រង់ចលនាមហាជននេះឯង ។ ក៏ប៉ុន្តែ ចលនាមហាជននេះ យើងបំផុសបាន ហើយពង្រឹង និងពង្រីកបានទៀត ។ ទៅអនាគតចលនានេះ រឹតតែខ្លាំងថែមទៀត ។ ដូច្នេះទើបយើងឃើញថា ប្រជាជនយើងល្អណាស់ មានកម្រិតសមូហភាពខ្ពស់ណាស់ ។ ៨៥

ភាគរយ សស្រោកសស្រាំ មានដំនឿជឿជាក់នឹងចលនា ។ ពិតហើយ នៅមានអ្នកជំទាស់ខ្លះ តែមាន១ ឬ២ទេ នៅក្នុង១០០ ។

**៣) សភាពការណ៍កសាងសង្គមនិយម**

សសភាពការណ៍រហូតមកដល់ថ្ងៃនេះ វិវត្តមកល្អជាងពេលមុនច្រើន ។ ប្រៀបធៀបនឹងឆ្នាំ១៩៧៥ គឺខុសគ្នាឆ្ងាយ ។ ប្រៀបធៀបនឹងឆ្នាំ១៩៧៦ ក៏ល្អជាង ។

**៣.១) នៅជនបទ៖**

និយាយរួមទូទាំងប្រទេស យើងដោះស្រាយស្បៀងបាន ។ និយាយដោយឡែក មានតំបន់១ ឬ២ នៅខ្វះខាត ។ ក្នុងសភាពខ្វះខាតនេះ ក៏យើងដោះស្រាយបាន ដោយជួយគ្នាដោះស្រាយក្នុងភាគមួយៗផង និងជួយគ្នាដោះស្រាយ នៅទូទាំងប្រទេសផង ។

◆ នៅតាមភូមិភាគធំៗ យើងដោះស្រាយបានចលនាខ្លាំងជាងឆ្នាំទៅ ។ កម្លាំងរៀបរយជាងឆ្នាំទៅ ។ ស្រូវ សន្ទូង និងពន្រោះល្អជាងឆ្នាំទៅ ។ ទឹកមានជាទូទៅ ដោយភ្លៀងម៉្យាង និងដោយប្រឡាយ និងព្រែកដឹកយើង ម៉្យាងទៀត ។

◆ កន្លែងខ្លះទៀត តាមសេចក្តីរាយការណ៍ គឺមានទឹកធ្វើស្រែទូទាំងភូមិភាគ គ្មានកន្លែងរអាក់រអួលទេ ។ ស្បៀងក្នុងរយៈឆ្លងកាត់ក៏ដោះស្រាយបាន គេមានស្រូវស្រាល ពោត និង ដំឡូង ពិសេសស្រូវស្រាល និង ពោត ។

កងទ័ពបដិវត្តន៍-មន្ទីរ-ក្រសួង ដែលមានចលនាធ្វើស្រែក៏បានដំណើរការខ្លាំងក្លាជាងមុនច្រើន ។

សរុបរួមទៅ ចលនារហូតដល់ថ្ងៃនេះ មានសន្ទុះល្អជាងឆ្នាំទៅ ។ ស្រូវស្រាលដើមឆ្នាំ យើងធ្វើបានច្រើនជាងឆ្នាំមុន ហើយស្រូវវស្សាក៏ចាប់ផ្តើមល្អ ។

ចលនាសស្រោកសស្រាំជាទូទៅ ។ បញ្ហាមួយទៀត ដែលយើងកក់ក្តៅ គឺភូមិភាគធំៗ ដូចពាយ័ព្យ បូព៌ា និរតី ឧត្តរ ដែលមានប្រជាជនច្រើន ដីស្រែច្រើន គេដោះស្រាយបាន ហើយចាត់តាំងកម្លាំងវាយសម្រុកបាន ខ្លាំងក្លា ។

**៣.២) តើឆ្នាំ១៩៧៦នេះ យើងបាន៣តោនមួយហិកតាឬទេ?**



កម្មាភិបាល និងយោធាខ្មែរក្រហមកំពុងប្រមូលផលស្រូវច្រកបាវ ដើម្បីយកទៅផ្គត់ផ្គង់នៅតាមសហករណ៍ និងកងទ័ពនៅសមរភូមិមុខ

យើងមិនទាន់បានស្រូវ មិនទាន់ឃើញលទ្ធផលជាក់ស្តែង ។ តែយើងឃើញចលនា ហើយឃើញលទ្ធភាព ។ ឯពូជយើងក៏មិនព្រួយបារម្ភ ។ ឧបសគ្គខ្លះ គឺគោ ក្របីឈឺ ។ ប្រជាជននៅឈឺខ្លះដែរ តែប្រៀបធៀបឆ្នាំទៅ ឈឺតិចជាង ។ ដូច្នេះ ប៉ះពាល់ដល់ការបង្កបង្កើនផលខ្លះដែរ ។ តែយើងដោះស្រាយបាន ដោយសមូហភាពជួយដោះស្រាយ ។

តាមយើងប៉ាន់ប្រមាណ នៅទូទាំងប្រទេស លទ្ធភាព៣តោន ១ហិកតា អាចសម្រេចបានពី៨០ ទៅ១០០ភាគរយ ។ ឯបញ្ហាប្រព័ន្ធភ្លឺ ប្រឡាយ ៣០ភាគរយ យើងសម្រេចបានតាំងពីខែមិថុនាមកម្ល៉េះ ។ តាមផែនការ យើងត្រូវសម្រេចក្នុងឆ្នាំ១៩៧៦ ។

### ៣.៣) ខាងបច្ចេកទេសឧស្សាហកម្មផ្សេងៗ

◆ ចំណុចមួយពិសេសនៃការកសាងសង្គមនិយមរបស់យើង គឺការគ្រប់គ្រងបច្ចេកទេស និងកសាងជួរបច្ចេកទេសជាតិយើង ។ យើងធ្វើបានល្អជាទូទៅ និងត្រឹមត្រូវតាមមាគ៌ារបស់បក្ស ។ យើងកសាងជួរបច្ចេកទេសយើងគ្រប់ផ្នែក ដោយឯករាជ្យម្ចាស់ការ ។ ប្រៀបធៀបនឹងអ្នកបច្ចេកទេស ឧស្សាហកម្មនៃរបបចាស់ យើងចម្រើនជាងឆ្ងាយ ក្នុងន័យថា យើងក្តាប់បច្ចេកទេសបាន និងផលិតបានដោយខ្លួនឯងបត្តម្ភខ្លួនកម្រិតខ្ពស់ ។ យើងច្នៃប្រឌិតធ្វើម៉ាស៊ីនបោកស្រូវធំ តូចបាន ហើយកំពុងពង្រីង និងពង្រីកលក្ខណៈសម្បត្តិដើម្បីឈានទៅមុខទៀត ។ ពីដើមកាលពីសង្គមចាស់ ខាងអគ្គិសនី និងគ្រឿងចក្រផ្សេងៗ មានតែបរទេសធ្វើ ។ ឥឡូវសុទ្ធតែកុមារយើង សស្រោកសស្រាំ ខ្លួននិងដៃ ប្រឡាក់ស្រមក ។ គេក្តាប់បច្ចេកទេសបានបម្រើចលនាបាន ។

និយាយរួម យើងចាត់ចែងបានគ្រប់ផ្នែកឧស្សាហកម្ម គ្រឿងចក្រ កៅស៊ូ ដឹកជញ្ជូន រទេះភ្លើង ។ យើងគិតគូរខ្លួនយើង ច្នៃប្រឌិតខ្លួនយើង ។ គ្រប់កន្លែង យើងដំណើរការយ៉ាងនេះ ។ យើងធ្វើតាមរបៀបបុរាណ តាមរបៀបមហាជន យើងធ្វើបាន ដូចជារោងចក្រកៅស៊ូ រោងចក្រប្រេង រោងចក្រសង់កប៉ាល់ឈើ ។ល ។

◆ បញ្ហានេះ ជាបញ្ហាយុទ្ធសាស្ត្រសំខាន់ ។ បើយើងមិនដើរតាមមាគ៌ានេះ យើងខុសពីរយ៉ាង ៖

ទី១) យើងកសាងយឺត

ទី២) យើងខុសជាមាគ៌ា ។ ត្រូវរៀនវប្បធម៌សិន រួចទើបរៀនបច្ចេកទេសក្រោយ ។ រៀន១០ឆ្នាំហើយ យើងអត់ចេះធ្វើអីទៀត ។ បើឲ្យទៅរៀននៅស្រុកគេ រឹតតែលំបាកស្មុគស្មាញ មួយគឺដាច់ពីចលនា ។ ពីរមកវិញអាចមានទំនាស់ នាំឲ្យស្មុគស្មាញខាងគោលជំហរបដិវត្តន៍ ។

យើងមិនធ្វើតាមនេះទេ ។ យើងធ្វើតាមមាគ៌ាយើង រៀនផងធ្វើផង ពិសេសធ្វើជាក់ស្តែង ។ ទាល់តែធ្វើយ៉ាងនេះ ទើបយើងបម្រើចលនាបាន ។ យើងចំណេញពេល១០ឆ្នាំ ទៅ១៥ឆ្នាំ ។

ដូច្នោះ កសាងបច្ចេកទេស ទាល់តែឈរលើមាគ៌ា ទើបមិនប្រែពណ៌សម្បុរ ទើបធានាខាងនយោបាយ ។ ខាងបច្ចេកទេស កសាងរហ័ស ទាល់តែហ៊ានធ្វើ ។ បើយន្តហោះ ទាល់តែហ៊ានបើកទើបចេះ ។ ខាងរទេះភ្លើង យើងត្រូវធ្វើខ្លួនយើង ។ ធ្វើទៅអាចខុសខ្លះ តែមិនសំខាន់ទេ យើងដកពិសោធន៍ ។ ទាល់តែធ្វើខ្លួនយើង ទើបយើងចេះ ។ បើយើងពឹងគេមិនងាយទេ ។

◆ យើងត្រូវផ្សព្វផ្សាយពិសោធន៍នេះ ។ គឺផ្សាយអំពីគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាជាតិខ្លួន ។ សព្វថ្ងៃ សកលលោកកំពុងចាំមើលយើង តើយើងធ្វើបានឬមិនបាន?

សភាពការណ៍បដិវត្តន៍យើង វិវត្តមកកាន់តែល្អ ហើយមានល្បឿនកាន់តែលឿន ។ លឿននេះ មានមូលដ្ឋានរបស់វា ដោយមានមាគ៌ាត្រឹមត្រូវ ។ មាគ៌ានេះក៏បានបំពាក់បំប៉នឲ្យបក្ស ឲ្យកងទ័ព និងឲ្យប្រជាជនបានត្រឹមត្រូវជាបន្តបន្ទាប់ ។ ដូច្នោះហើយ បានជាចេញជាចលនាសស្រោកសស្រាំ ចេញជាលទ្ធផលជាក់ស្តែង ដែលបង្ហាញយ៉ាងច្បាស់នូវសមត្ថភាពរបស់យើង ។

ទន្ទឹមនេះ ការកសាងប្រទេស ក៏មានលក្ខណៈល្អច្រើន មានទីតាំងមូលដ្ឋានជាច្រើន នាំឲ្យយើងមានលក្ខណៈសម្បត្តិពង្រីងនិងពង្រីកបានថែមទៀត ។

ឯកិច្ចការពារប្រទេស ក៏មានសភាពកាន់តែល្អប្រសើរ ។ ពិតមែនតែយើងនៅមានការប្រុងប្រយ័ត្ន និងមានវិធានការតទៅទៀត តែកិច្ចការពារប្រទេសនេះ មិនទទើសទទែងដល់បដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់យើងទេ ។ ផ្ទុយទៅវិញ សភាពការពារប្រទេសដ៏ល្អនេះ ជំរុញឲ្យយើងធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមបានកាន់តែល្អថែមទៀត ។

សភាពការណ៍ទាំងអស់នេះ មានលក្ខណៈកាន់តែល្អ នាំឲ្យយើងកាន់តែឈានទៅមុខ បានកាន់តែលឿនមួយកម្រិតទៀត ។ ឯការលំបាកក៏នៅមាន ។ ចំពោះមុខយើងនៅខ្វះខាតខាងសម្ភារៈខាងជីវភាពប្រជាជន សម្ភារបច្ចេកទេសខាងបង្កបង្កើនផល ។ ឥឡូវនៅប្រហោងខ្វះ ពិតមែនតែយើងដោះស្រាយបានជាមូលដ្ឋាន ។ តែការលំបាកនេះ ជាការលំបាកបណ្ដោះអាសន្ន ចំពោះមុខយើងដោះស្រាយបាន ។

◆ តទៅមុខទៀត តើយើងត្រូវដោះស្រាយអ្វី?

គឺត្រូវដោះស្រាយបញ្ហាបក្សដឹកនាំ ឲ្យកាន់តែរឹងប៉ឹងខាងគោលជំហរនយោបាយ អនុវត្តភារកិច្ចកសាងសង្គមនិយម និងការពារប្រទេស ។ បើកម្មាភិបាលយើងជ្រួតជ្រាបពីបញ្ហានេះហើយ ចលនាយើងនឹងរឹតតែខ្លាំងក្លា ។ ជាក់ស្ដែងកន្លែងណាមានគណៈកម្មាធិការភាគ និងតំបន់ខ្លាំង កន្លែងនោះមានចលនាខ្លាំងណាស់ សស្រាកសស្រាំដោះស្រាយបាន ។ អត់ទៅជាមាន ។ ដោះស្រាយស្បៀងក៏បានបំប៉នកម្លាំងប្រជាជនក៏បាន រៀបចំរាយសម្រុកស្រួចស្រាល ស្រូវធ្ងន់ក៏បានចលនាផុសផុល ។ ដូច្នេះភារកិច្ចយើងតទៅទៀត គឺកសាងកម្មាភិបាលដឹកនាំ ទាំងក្នុងបក្ស ទាំងក្រៅបក្ស ។

**៤) ពង្រឹងគោលជំហរ សមូហភាពនៃវណ្ណៈអធនឲ្យខ្លាំងក្លាថែមទៀត ដើម្បីឯកភាពគ្នាក្នុងការកសាងសង្គមនិយម តាមផែនការរបស់បក្ស**

ជាងមួយឆ្នាំកន្លងមកនេះ ក្រោមការដឹកនាំរបស់បក្សយើង កម្មាភិបាល បក្ខជន ប្រជាជន និងកងទ័ពបដិវត្តន៍យើងបានបំពេញភារកិច្ចការពារប្រទេស និងកសាងប្រទេសក្នុងដំណាក់កាលថ្មីនៃបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមមកដល់ថ្ងៃនេះហើយ ។ ជាមូលដ្ឋាន យើងបានទទួលលទ្ធផលល្អ មិនមានអ្វីខុសឆ្គងជាធំដុំអំពីមាគ៌ាបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមទេ ។ តែក្នុងការអនុវត្តជាក់ស្ដែង យើងមានគុណសម្បត្តិ និងគុណវិបត្តិជាធម្មតា ។

អំណោះពីនេះតរៀងទៅ ដើម្បីជំរុញកិច្ចការពារប្រទេស និងកសាងប្រទេស ឲ្យបានល្អ បានឆាប់រហ័ស សម្រេចបានតាមមាគ៌ាពី១០ទៅ១៥ឆ្នាំ ប្រែក្លាយប្រទេសយើងទៅជាប្រទេសកសិកម្មសម័យ និងពី១៥ឆ្នាំ ទៅ២០ឆ្នាំ ប្រែក្លាយទៅជាប្រទេសឧស្សាហកម្ម យើងចាំបាច់ត្រូវមានផែនការជារយៈយូរឆ្នាំ សម្រាប់បំភ្លឺផ្លូវ ឲ្យដំណើរបដិវត្តន៍សង្គមនិយមរបស់យើងដើរទៅតាមទិសរបស់បក្ស ។

បញ្ហាជាបឋម និងជាមូលដ្ឋានដែលចាំបាច់ គឺជួរបក្ស ប្រជាជន និងកងទ័ពបដិវត្តន៍ ត្រូវឯកភាពគ្នាជាធ្លុងមួយ លើទស្សនៈគោលជំហរ សតិអារម្មណ៍ អំពីផែនការជារយៈយូរឆ្នាំរបស់បក្ស ដើម្បីកសាងសង្គមនិយម ។

តើកម្ពុជាយើង ចាំបាច់ត្រូវមានផែនការយូរឆ្នាំហើយឬនៅ? តើកាលៈទេសៈពេលនេះ ល្មមធ្វើផែនការហើយឬនៅ? យើងមានលក្ខណៈសម្បត្តិហើយឬនៅ? ចំពោះបញ្ហាទាំងអស់នេះ យើងត្រូវដោះស្រាយ ដោយមានហេតុផលច្បាស់លាស់ ទើបមានជំនឿលើផែនការ លើកិច្ចដំណើរការតាមផែនការ ។ បើគ្មានជំនឿអំពីហេតុផល ថាត្រូវធ្វើផែនការពីឥឡូវនេះទេ យើងមិនឯកភាពគ្នាទេ ។ បើមិនឯកភាពគ្នា ផែនការយើងមុខជាដំណើរការទៅមិនបាន ឬដំណើរការទៅមិនចំទិសតាមបក្សកំណត់ ។ បើមិនឯកភាពគ្នាទេ ពេលជួបឧបសគ្គតូច-ធំ ប្រទាញប្រទង់គ្នា បែកបាក់គ្នា ។ ដូច្នេះត្រូវជឿជាក់លើហេតុផល ថាតើត្រូវធ្វើ ឬមិនត្រូវធ្វើ ។ ហេតុផលមានដូចតទៅ ៖

១) ហេតុផលសំខាន់បំផុត គឺយើងត្រូវកសាងប្រទេសយើងឲ្យលឿន ឲ្យរហ័ស ឲ្យលោតផ្លោះ ឲ្យមហាលោតផ្លោះទៀត ។ នេះជាហេតុផលសំខាន់មូលដ្ឋាន ។

ហេតុអ្វីបានជាត្រូវដើរឲ្យលឿន ឲ្យរហ័ស ឲ្យលោតផ្លោះមហាលោតផ្លោះ ព្រោះខ្មាំងសត្រូវ វាធ្វើទុក្ខបុកម្នេញយើងជាយុទ្ធសាស្ត្រ ។ បើយើងស្ថិតនៅក្នុងសភាពយឺតយ៉ាវ ហើយមិនខ្លាំងក្លា ខ្មាំងសត្រូវមុខជាធ្វើបាបយើងពិតប្រាកដ ។ តែបើយើងខ្លាំងមួយឆ្នាំក៏ខ្លាំងក្លា ២ឆ្នាំកាន់តែខ្លាំងក្លា ៣ឆ្នាំ ៤ឆ្នាំកាន់តែខ្លាំងក្លាឡើងៗ ជាលំដាប់នោះខ្មាំងសត្រូវវាធ្វើអ្វីយើងមិនបែកទេ ។

ផ្ទុយទៅវិញ បើពីមួយឆ្នាំទៅមួយឆ្នាំ ជីវភាពប្រជាជនមិនបានកែចម្រើន សេដ្ឋកិច្ចមិនចម្រើន ការពារប្រទេសទន់ខ្សោយ ខ្មាំងសត្រូវមុខតែវាជាន់យើងហើយ ។ នេះជាហេតុផលសំខាន់ ។ ដូច្នេះ ទោះជាស្អប់ខ្មាំងសត្រូវយ៉ាងណាក៏ដោយ មានកំហឹងពុះពោរចំពោះវាយ៉ាងណាក៏ដោយ តែបើយើងមិនខ្លាំង ខ្មាំងសត្រូវ វារុក

ក្នុនយើងបាន ។ បើវារុកក្នុនយើង គឺយើងស្ថិតក្នុងសភាពការពារ ។ យើងមិនស្ថិតក្នុងសភាពវាយសម្រុកទេ ។

តែបើយើងខ្លាំង ខ្មាំងសត្រូវវាមិនហ៊ានរុកក្នុនយើងទេ ។ យើងការពារប្រទេសក្នុងសភាពវាយសម្រុក ។ វាយសម្រុកក៏ដោយ មកពីក្នុងប្រទេសយើងខ្លាំង ។ តាមរយៈនេះ ឥទ្ធិពលយើងនៅក្រៅប្រទេសក៏ខ្លាំង ។ បើយើងស្ថិតក្នុងសភាពខ្លាំង ខ្មាំងវាមិនម្ចាស់ការក្នុងការវាយយើង ។ ដូចនេះ យើងត្រូវកសាងប្រទេសយើងឲ្យលឿន ឲ្យលោតផ្លោះ មហាលោតផ្លោះ ។ យើងមិនមែនការពារប្រទេសតែដោយយោធាទេ គឺការពារដោយកសាងប្រទេសឲ្យខ្លាំងក្លា ។ នេះជាហេតុផលសំខាន់ ។

ក្នុងសភាពហ្នឹង យើងត្រូវរៀបចំផែនការកសាងប្រទេសយើង ដើម្បីដើរឲ្យលឿន ។ យើងដើរឲ្យលឿន ដើម្បីពង្រីង និងពង្រីកខ្លួន ។ ពង្រឹងពង្រីកខាងសេដ្ឋកិច្ច ពង្រឹងពង្រីក ខាងការពារប្រទេស ។ ធ្វើយ៉ាងនេះ ទើបយើងម្ចាស់ការ ។

២) ហេតុផលទី២ យើងត្រូវតែធ្វើផែនការ ហើយធ្វើឲ្យឆាប់រហ័ស ព្រោះត្រូវដោះស្រាយជីវភាពប្រជាជនយើងឲ្យឆាប់រហ័ស ។ បើយើងដោះស្រាយជីវភាពប្រជាជនបានរហ័ស គឺបំប៉នកម្លាំងនយោបាយរឹតតែខ្លាំងក្លា ។ បើជីវភាពប្រជាជនមិនបានដោះស្រាយ ខ្មាំងសត្រូវវាឆ្កឹះប្រជាជនឲ្យទំនាស់ជាមួយយើងបាន ដោយចង់ក្តី មិនចង់ក្តី ។

៣) ហេតុផលទី៣ គឺយើងត្រូវកសាងប្រទេស ឲ្យមានមូលដ្ឋានសេដ្ឋកិច្ច ខាងកសិកម្មឆាប់រហ័ស ខាងឧស្សាហកម្មឆាប់រហ័ស និងឲ្យមានទុនច្រើន និងឆាប់រហ័ស ដើម្បីកសាងប្រទេស ឲ្យបានឆាប់រហ័ស ហើយដោះស្រាយជីវភាពប្រជាជនឲ្យបានឆាប់រហ័ស ។ តាមរយៈនេះ ឥទ្ធិពលរបស់យើងនៅក្រៅប្រទេស ក៏រីកចម្រើនឆាប់រហ័ស ។

ហេតុផលទាំងនេះ បញ្ជាក់ថា ត្រូវតែធ្វើផែនការ ហើយត្រូវធ្វើឲ្យរហ័ស គ្មានចាំឱកាសណាទៀតទេ ។ ចាំឆ្នាំ៧៧ សឹមធ្វើ ហើយឆ្នាំ៧៨ ទើបអនុវត្ត គឺយឺតយ៉ាវណាស់ ។ ដូចនេះ យើងមិនរង់ចាំទេ ។ យើងត្រូវតែធ្វើ ទោះជាទើបចេញពីសង្គ្រាមក៏ដោយ ។

ម្យ៉ាងទៀត បើយើងរង់ចាំធ្វើផែនការ២-៣ឆ្នាំ ដើម្បីស្តាសេដ្ឋកិច្ចសិន គឺយឺតណាស់ ។ យើងមិនម្ចាស់ការក្នុងការការពារប្រទេស ការពារបក្ស ការពារបដិវត្តន៍ទេ ។ យើងត្រូវខ្លាំង ។ ខ្លាំងទាំងគោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំង ខ្លាំងទាំងខាងសេដ្ឋកិច្ច ។ ដូចនេះ ត្រូវតែធ្វើគ្មានចាំពេលណាទៀតទេ ។ បើយើងជ្រួតជ្រាបសភាពការណ៍នេះ ទោះជាមានឧបសគ្គតាមផ្លូវយ៉ាងណាក៏ដោយ ទោះជាឧបសគ្គធម្មជាតិក៏ដោយ ឧបសគ្គជាសត្រូវនុម័តិ ឬអត្តនោម័តិក៏ដោយ ក៏យើងឯកភាពគ្នា ។ តែបើមានឧបសគ្គ ហើយយើងមិនជ្រួតជ្រាបមាគ៌ាទេ នោះយើងមិនឯកភាពគ្នាទេ មុខតែមានសមាសភាពខ្លះពេលជួបឧបសគ្គ លើកបញ្ហាយ៉ាងនេះយ៉ាងនោះមករារាំង ។ តែបើថ្នាក់បក្សដឹកនាំ ឯកភាពគ្នារឹងមាំហើយ គឺមិនមានបញ្ហាអ្វីទេ ។ ដូច្នេះមិនមែនគ្រាន់តែឯកភាព ក្នុងសភាពស្រួលទេ គឺត្រូវឯកភាពក្នុងសភាពលំបាកទៀត ហើយពិសេសក្នុងសភាពលំបាក ត្រូវកាន់តែឯកភាពគ្នា ឲ្យកាន់តែរឹងមាំថែមទៀត ។ ជួបលំបាកយ៉ាងណា យើងនៅតែខំអនុវត្តផែនការតទៀត ។

ដូច្នេះក្នុងផែនការរបស់យើង មិនមែនបញ្ហាតួលេខជាបញ្ហាសំខាន់ទេ ។ បញ្ហាសំខាន់គឺទស្សនៈ និងគោលជំហរច្បាស់លាស់ម៉ោះមុតថាត្រូវតែធ្វើផែនការ ។

### តើធ្វើបាន ឬមិនបាន?

យើងឆ្លើយថា ត្រូវតែធ្វើផែនការ ទោះបីមានតែបាតដៃទទេក៏ត្រូវធ្វើ ។ តែយើងហ៊ានធ្វើ ដោយយើងមានចំណុចខ្លាំង និងចំណុចខ្សោយដូតទៅនេះ ៖

**ចំណុចខ្លាំង ៖**

១) របបសង្គមនិយមយើង មានលក្ខណៈលឿន ។ ទាំងសតិអារម្មណ៍ ទាំងចាត់តាំង ។ នេះនិយាយជារបប ។ ឯសេដ្ឋកិច្ច វាទាក់ទងនឹងរបបនយោបាយ ។ បើរបបនយោបាយគ្មានអ្វីប្រទង់ប្រទាញស្មុគស្មាញ របបសេដ្ឋកិច្ចក៏លឿន ។ តែបើរបបនយោបាយវានៅជាឯកជន វាប្រទាញឲ្យរបបសេដ្ឋកិច្ចស្មុគស្មាញ ។ ឧទាហរណ៍ៈ ធ្វើប្រព័ន្ធភ្លឺស្រែ បើឯកជនធ្វើបានឬមិនបាន? ឬរបបសង្គមនិយមដែរ តែឯកជននៅជាមូលដ្ឋាន តើធ្វើបានឬមិនបាន? ធ្វើមិនបានទេ ។ បើធ្វើបានគឺបានបន្តិចបន្តួច ។ តែបើរបបសមូហភាពរឹង ព្រែកដីកក៏ធ្វើរហ័ស ប្រព័ន្ធភ្លឺក៏ធ្វើរហ័ស ព្រោះវាគ្មានអ្វី គ្មានឯកជនណាមកប្រទាញប្រទង់ ។ ដូច្នេះ របបនយោបាយ វាជាកត្តាសម្រេច វាជំរុញការចាត់ចែងផលិតកម្ម ទៅតាមផែនការសមូហភាព ។ ផ្ទុយទៅវិញ

បើឯកជនចាត់ចែង គឺទៅមិនរួចទេ ។ មានអ្នកនិយាយថា សង់រោងចក្រ ទៅទាក់ទងអ្វីនឹងរបបនយោបាយ? ។ ការពិតគឺវាទាក់ទងនឹងរបប ។ ឧទាហរណ៍ៈ នៅបណ្តាប្រទេសដែលរក្សាកម្មសិទ្ធឯកជន មិនអាចប្រមូលកម្លាំងទៅវាយសម្រុកកសាងអ្វីឲ្យបានខ្លាំងក្លាទេ ។ ឯរបបយើង ប្រៀបធៀបនឹងគេ គេស្តុកស្តាញ១០០ យើងមាន ១-២ ប៉ុណ្ណោះ ។ និយាយរួម មិនចោទជាបញ្ហាអ្វីផងទេ ។

ដូចកាលពីសង្គមចាស់ ដែលឈរលើកម្មសិទ្ធិឯកជន ការប្រើប្រាស់ប្រេង ប្រើប្រាស់លុយកាក់ ។ល ។ គឺខុសគ្នាពីយើង ។ យើងប្រើប្រេងដើម្បីការពារប្រទេស និងកសាងប្រទេស ។ ឯកាលពីសង្គមចាស់ វាប្រើប្រេងដើម្បីការពារប្រទេស និងកសាងប្រទេសដែរ តែដើម្បីបម្រើឯកជន ហើយប្រេងមួយចំនួនសំខាន់ សម្រាប់បម្រើទៅខាងដើរលេងជាឯកជន ។ ក្នុងរបបសមូហភាព បើមានប្រាក់១លានរៀល យើងប្រើសម្រាប់ការពារប្រទេស និងកសាងប្រទេសទាំង១លានរៀល ។ ឯក្នុងរបបឯកជន បើមាន១លានរៀល គេចាយ៥សែនរៀល ទៅខាងប្រាក់ខែ៥សែនរៀលសម្រាប់ការពារប្រទេស និងកសាងប្រទេស ។ដូចនេះចាញ់យើង៥សែនរៀល ។

នេះបង្ហាញថា របបយើងវាលឿនជាង វាខ្លាំងជាង ។ យើងមានរបបល្អជាមូលដ្ឋាន ។ យើងធ្វើអ្វីក៏បាន ។ ឃើញដូចនេះ យើងមិនខ្លាចទេ ។ ម្យ៉ាងទៀត របបយើងក៏នាំឲ្យរបបបច្ចេកទេសដើរលឿនដែរ ។ ឧទាហរណ៍ ធ្វើព្រែកជីក- ប្រព័ន្ធភ្លឺ- ប្រឡាយ ។ល ។ គ្រាន់តែពាក់កណ្តាលឆ្នាំ១៩៧៦ យើងធ្វើបាន៣០ភាគរយ ។ បើកម្មសិទ្ធិឯកជន អត់ដោះស្រាយយ៉ាងនេះបានទេ ។

ចំណុចរបស់យើងមួយទៀត គឺការដែលរៀបចំបានកម្លាំងស្រួចសម្រាប់វាយសម្រុក ដែលមានលក្ខណៈសមូហភាពខ្ពស់ ហួសពីក្របខណ្ឌសហករណ៍- ស្រុក- តំបន់ ។ ការដែលរៀបចំកម្លាំងស្រួច ចល័ត ក្នុងក្របខណ្ឌធំទូលាយយ៉ាងនេះបានបញ្ជាក់ឲ្យឃើញថា ប្រជាជនយើងមានកម្រិតភ្ញាក់រឭក នយោបាយខ្ពស់ មានស្មារតីសមូហភាពខ្ពស់ ។

(២) បក្សយើងមានមាគ៌ាជាយុទ្ធសាស្ត្រ មានមាគ៌ាជាយុទ្ធវិធី ។ មានមាគ៌ាជាយុទ្ធសាស្ត្រត្រឹមត្រូវ ជាជ័យជម្នះមួយធំហើយ ។ មានមាគ៌ាជាយុទ្ធវិធីត្រឹមត្រូវ ក៏ជាជ័យជម្នះមួយទៀត ហើយជាចលនាមានពិសោធន៍ ។

(៣) ប្រជាជនយើង ស្ថិតនៅជាសមូហភាពទាំងអស់ ។ កម្លាំងសមូហភាពនេះ កាន់តែខ្លាំងក្លា ហើយរឹតតែខ្លាំងក្លាថែមទៀត ។

(៤) លក្ខណៈធម្មជាតិ អនុគ្រោះឲ្យយើងច្រើន ។ដីស្រែយើងមាន២.៤០០,០០០ហិកតា ហើយអាចលើសពីនេះ ។ ប្រជាជនយើងមានជាង៧លាននាក់ ។ យើងមិនចោទបញ្ហាភ្នំ- ថ្មទេ ។ មិនចោទបញ្ហាខ្វះដីទេ ។ បញ្ហាទឹក ក៏យើងដោះស្រាយបានងាយស្រួល ។ ឈរលើសភាពការណ៍ខាងនេះ យើងពិនិត្យការលំបាករបស់យើង ។ ឃើញមានៈ

(១) យើងទើបចេញពីសង្គ្រាមថ្មីថ្មោង ។ តែបញ្ហានេះ មិនមែនជាបញ្ហាមូលដ្ឋានទេ ។

(២) នៅខ្វះខាតខាងបច្ចេកទេស ។ បញ្ហានេះ យើងដោះស្រាយរួច ហើយដោះស្រាយបានជាបណ្តើរៗមកហើយ ។

(៣) វត្ថុធាតុដើម យើងនៅខ្វះខាតខ្លះ ត្រូវទិញពីក្រៅ តែយើងដោះស្រាយរួចជាបណ្តើរៗ ។

ការលំបាកទាំងនេះ ដោះស្រាយបាន ហើយអាចដោះស្រាយបានក្នុងរយៈពេលខ្លី ។ ទូទាត់សភាពការណ៍ស្រួល និងលំបាកទៅ តើយើងធ្វើបានឬមិនបាន? ។ យើងធ្វើបានពេញទី ។ ធ្វើបាននេះ គឺយើងមានចលនាជាក់ស្តែងជាភ័ស្តុតាង ។ ពីបីឆ្នាំទៅប្រាំឆ្នាំ លេចចេញសាច់ការ ខាងបញ្ហាទឹកច្បាស់លាស់ជាមូលដ្ឋាន ។ បញ្ហាដី យើងដោះស្រាយបាន ។ បញ្ហាថ្នាំកម្ចាត់សត្វល្អិត យើងដោះស្រាយបាន ។

តាមសភាពការណ៍នេះ យើងធ្វើបានពេញទី ហើយធ្វើបានឆាប់រហ័ស ទោះមានឧបសគ្គតាមដួរក៏ដោយ ។ ឧបសគ្គតែងមានជាធម្មតា ជួនកាលរាំង ជួនកាលជន់លិច ។ ឧបសគ្គជាចៃដន្យមួយរយៈកាល ។ តែយើងដោះស្រាយបាន ។ យើងមានជំនឿជាយុទ្ធសាស្ត្រ ព្រោះយើងមានរបបនយោបាយជារបបសមូហភាពជាបង្អែក ជាមូលដ្ឋាន ។

ទៅមានឧបសគ្គ ទៅខ្លាំងឆ្កឹះឆ្កៀល ក៏យើងមានជំនឿ ដោយយើងមានគោលជំហរ វិភាគច្បាស់លាស់យ៉ាងនេះ ។ បញ្ហានេះ យើងត្រូវឯកភាពគ្នា ។ យើងឯកភាពគ្នា ដោយឈរលើគោលជំហរសមូហភាពនៃវណ្ណៈអធនយ៉ាងរឹងមាំ ។

**ឆេង ទើង**

# ដំណើរជីវិតរបស់ មាស ផល

អ៊ំប្រុសម្នាក់ និងមានកូនជញ្ជីងតូចមួយនៅក្បែរខ្លួន កំពុងតែអង្គុយសម្រាកនៅក្រោមដើមឈើ ក្នុងទីធ្លាវត្តខណ្ឌាឡោម ។ ខ្ញុំដឹងថាគាត់ប្រកបរបរថ្លឹងគីឡូ ខ្ញុំបានចូលជួបគាត់ដើម្បីថ្លឹងគីឡូ និងឆ្លៀតពេលនោះ ខ្ញុំនិយាយលេងជាមួយគាត់បន្តិចបន្តួច ។ ស្ថិតក្នុងសម្លៀកបំពាក់រយីករយាក អាវពណ៌គគីរចាស់ និងខោខ្មៅដែលពេញដោយបំណះ ជាមួយនឹងកូនជញ្ជីងថ្លឹងគីឡូមួយនៅក្បែរខ្លួន បានប្រាប់ខ្ញុំថា គាត់ឈ្មោះ មាស ផល មានវ័យជាង៧០ឆ្នាំហើយ ។ ផល ជាកសិករដែលមកពីខេត្តព្រៃវែង ។ គាត់មានប្រពន្ធ និងកូនប្រាំមួយនាក់ ។ កូនទាំងប្រាំមួយរបស់គាត់ មានគ្រួសារអស់ហើយ និងប្រកបរបរធ្វើស្រែចម្ការដូចគ្នា ក្នុងនោះមានកូនពីរនាក់មកធ្វើការងារជាកម្មករសំណង់នៅភ្នំពេញ ។ ដោយសារតែជីវភាពគ្រួសារ ផល មានការលំបាក ហេតុនេះកូនៗរបស់គាត់មិនបានរៀនសូត្រខ្ពង់ខ្ពស់ទេ ។

ទោះបីជាមានវ័យចាស់ក៏ពិតមែន តែផល មើលទៅហាក់ដូចជាមានសុខភាពមាំមួននៅឡើយ ។ ដោយសារតែជួបបញ្ហាលំបាកនៅក្នុងជីវភាពគ្រួសារ បន្ទាប់ពីការងារស្រែចម្ការ គាត់ក៏សម្រេចចិត្តមករកប្រាក់បន្ថែមនៅភ្នំពេញ ។ គាត់មកនេះ ដោយប្រកបរបរថ្លឹងគីឡូ ដែលគាត់អាចរកចំណូលបានជាងមួយម៉ឺនរៀលទៅពីរម៉ឺនរៀលក្នុងមួយថ្ងៃ ។ គាត់ត្រូវដើរទៅមករៀងរាល់ថ្ងៃ ពីមុខព្រះបរមរាជវាំងរហូតដល់ផ្សាររាត្រី (ផ្សារចាស់) ។ នៅពេលរសៀលបន្តិចទើបគាត់ចូលមកសម្រាកនៅក្នុងវត្តខណ្ឌាឡោម ។

ផល មិនមានផ្ទះស្នាក់នៅច្បាស់លាស់ទេ ពេលសម្រាកនៅពេលយប់ គាត់ទៅសម្រាកជាមួយពួកអ្នកធាក់ស៊ីក្លូនៅជិតសារមន្ទីរជាតិ ។ ទោះបីជាកូនទាំងពីររបស់គាត់មកធ្វើជាកម្មករនៅភ្នំពេញ



រូបខាងឆ្វេង ៖ ទាវ សារៈមុនិន្ទ អ្នកសរសេរទស្សនាវដ្តីស្វែងរកការពិត ជួបសម្ភាសន៍ មាស ផល ពីជីវិតនៅក្នុងរបបខ្មែរក្រហម នៅវត្តខណ្ឌាឡោម ក្រុងភ្នំពេញ ។ រៀងរាល់ឆ្នាំ បន្ទាប់ពីប្រមូលផលស្រូវរួច ផល បានឆ្លៀតពេលមកប្រកបរបរដើរដាក់ជញ្ជីងថ្លឹងទម្ងន់មនុស្ស ដើម្បីយកប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារ ។

តែគាត់មិនដែលជួប និងដឹងថាកូនៗរបស់គាត់ធ្វើការនៅទីណានោះទេ ព្រោះមិនមានអ្វីទំនាក់ទំនងបាន។ ផល បាននិយាយ ដោយសើចញឹមៗថា “សម័យនេះទោះបីជាលំបាក ក៏មិនលំបាកដល់សម័យខ្មែរក្រហមដែរ” ហើយឆ្លៀតពេលនោះ គាត់ក៏បានរំឭកពីជីវិតគាត់ក្នុងសម័យខ្មែរក្រហមប្រាប់ខ្ញុំ។

## អំពី ផល និងគ្រួសារ

ផល ជាកូនកសិករ នៅឃុំសំរោង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង និងមានបងប្អូនប្រុសស្រីប្រាំបីនាក់។ ដោយសារតែជីវភាពគ្រួសារក្រីក្រលំបាក គាត់បានរៀនសូត្រត្រឹមថ្នាក់ទី៨ប៉ុណ្ណោះ រួចក៏ឈប់មកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ។ គាត់បានរៀបការនៅឆ្នាំ១៩៦៩ និងមានកូនពីរនាក់។ ភូមិស្រុកដែលផល រស់នៅត្រូវខ្មែរក្រហមចូលមកកាន់កាប់តាំងពីឆ្នាំ១៩៧០មកម៉្លេះ។ នៅអំឡុងពេលនោះ ខ្មែរក្រហមមិនទាន់មានការធ្វើបាបអ្វីដល់ប្រជាជននោះទេ ការងារធ្វើស្រែចម្ការ ត្រូវធ្វើជាក្រុមប្រវាស់ដៃ។ រហូតដល់ឆ្នាំ១៩៧៦ ទើបមានការហូបរួម។ ក្រោយឆ្នាំ១៩៧៥ ផល ត្រូវបានអង្គការចាត់តាំងឲ្យធ្វើមេភូមិ និងក្តាប់សហករណ៍ភូមិត្រពាំងឥដ្ឋ តែគាត់បានបដិសេធមិនធ្វើ។ ពេលនោះ អង្គការទឹងនឹងការដែលគាត់បដិសេធនេះណាស់ តែរកវិធីសម្លាប់មិនបាន។ គាត់បានឲ្យដឹងថា អ្នកដែលឡើងធ្វើមេភូមិបន្ទាប់ពីនោះ ត្រូវអង្គការយកទៅជាបន្តបន្ទាប់ មិនដឹងយកទៅណានោះទេ។

## ការជម្លៀសចេញពីភូមិ ទៅខេត្តពោធិ៍សាត់

នៅអំឡុងចុងឆ្នាំ១៩៧៦ ផល និងគ្រួសារ ជាមួយនឹងអ្នកភូមិមួយចំនួនទៀត ត្រូវខ្មែរក្រហមជម្លៀសចេញពីភូមិ។ គាត់ និងអ្នកជម្លៀសឯទៀតបានដើរមកដល់អ្នកលឿង ទើបមានឡានអង្គការមកទទួល និងដឹកបន្តមកដល់ច្បារអំពៅ។ មកដល់ភ្លាមអង្គការបានចែកក្រមាពណ៌ខៀវម្នាក់មួយ និងរៀបចំបាយឲ្យហូប។ បន្ទាប់ពីហូបបាយរួច ឡានបានដឹកអ្នកជម្លៀសទាំងអស់ទៅកាន់រ៉ារថភ្លើង ដើម្បីធ្វើដំណើរបន្តទៅកាន់ខេត្តពោធិ៍សាត់។ ពេលនោះម្នាក់ៗមានក្តីរីករាយណាស់ ដោយសង្ឃឹមថាទៅរស់នៅកន្លែងថ្មីនឹងមានអាហារហូបគ្រប់គ្រាន់ ព្រោះនៅពេលដែលអង្គការប្រកាសពេលជម្លៀសដំបូង បានប្រាប់ថា “ទៅដល់ទីនោះជាដីខ្លាញ់ សម្បូរហូបណាស់ ដើមអំពៅប៉ុនៗកដៃ រាប់សិបហិកតា ឯដំឡូងមើមធំ ទាល់តែមានអីគ្រីបឡើងទើបគាស់មើមវាបាន ហើយស្រូវអង្ករមិនខ្វះទេ”។ ការធ្វើដំណើរដោយរថភ្លើងពីភ្នំពេញទៅដល់ពោធិ៍សាត់ ត្រូវចំណាយពេលមួយយប់មួយថ្ងៃ ដែលទូរថភ្លើងនីមួយៗផ្ទុកមនុស្សណែនៗ ប្រហែលពី៣០ ទៅ៤០នាក់។

## ភូមិអូរក្រៀត

ពេលទៅដល់ពោធិ៍សាត់នៅថ្ងៃរសៀល អង្គការបានបញ្ជូនផល និងអ្នកឯទៀតទៅកាន់ភូមិមួយឈ្មោះថា ភូមិអូរក្រៀត ក្នុងស្រុកបាកាន។ ពេលទៅដល់ភូមិទើប ផល ដឹងថា អ្វីៗមិនដូចអង្គការបានប្រាប់នោះទេ។ គាត់គិតថា នេះពិតជាបញ្ជូនមកឲ្យស្លាប់មិនខាន ព្រោះទីនេះគ្មានអ្វីទាំងអស់។ តែពេលដែលទៅដល់ដំបូងពេលបាយ គឺអង្គការដាំបាយឲ្យហូបមួយឆ្អែត។ បន្ទាប់ពីបាយរួចទើបអង្គការបើកអង្គប្រជុំ ដើម្បីធ្វើការបែងចែកការងារ។ ផលត្រូវអង្គការចាត់តាំងឲ្យចូលកងចល័ត ក្រុមភ្ជួរដែលមានសមាជិកប្រហែល១០នាក់ ហើយប្រពន្ធរបស់គាត់ អង្គការចាត់តាំងឲ្យនៅកងស្ទូង។

## ការជ្រួលច្របល់នឹងព្រឹត្តិការណ៍បះបោររបស់ សោម ភឹម

ធ្វើការនៅភូមិអូរក្រៀតបានប្រហែលមួយខែ ក៏មានលេចឮដំណឹងពីព្រឹត្តិការណ៍បះបោររបស់មេភូមិភាគបូព៌ាឈ្មោះ សោ ភឹម។ ពេលនោះ នៅក្នុងភូមិមានភាពច្រួលច្របល់បន្តិច ផលសង្កេតឃើញប្រជាជនមួយចំនួនរៀបអីវ៉ាន់ យកអង្ករ គោក្របីបម្រុងភៀសខ្លួន តែបន្តិចក្រោយមក ឈ្លប ឬយោធាខ្មែរក្រហមបានមកឃាត់ និងប្រាប់ថា “មិនចាំបាច់យកអីវ៉ាន់អីទៅទេ ហើយឲ្យអ្នកដែលចង់ចាកចេញទាំងអស់មកចុះឈ្មោះ”។ បន្ទាប់មករំលងបានមួយយប់ អ្នកដែលបានកត់ឈ្មោះទាំងអស់ ត្រូវអង្គការចាប់យកទៅសម្លាប់ទាំងគ្រួសារៗតែម្តង។ អ្នកខ្លះក៏បានរត់រួចពីការសម្លាប់នេះ និងបានរត់ចេញពីភូមិទៅរស់នៅភូមិផ្សេងទៀត។

## ការចងចាំដ៏គួរឲ្យសង្វេគ

ផល ឲ្យដឹងថា នៅភូមិអូរក្រៀតនេះ មានប្រជាជនស្លាប់ជាច្រើន ដែលភាគច្រើនស្លាប់ដោយសារខ្មែរក្រហមសម្លាប់។ គាត់នៅចងចាំទិដ្ឋភាពដ៏គួរឲ្យសង្វេគមួយ គឺឃើញសាកសពនារីម្នាក់ ហើយមានកូនតូចកំពុងតែបៅដោះសាកសពម្តាយ ដោយគ្មាន

នរណាអើពើឡើយ ចំណែកនៅតាមផ្លូវ គាត់បានឃើញសាកសពជាច្រើន ខ្លះកប់មិនជិតនៅពាសពេញវាល ។ ប្រជាជនទាំងនោះស្លាប់ដោយខ្មែរក្រហមចោទថា ជាខ្មាំងយួន ខ្ជិលធ្វើការ គឺទុកក៏មិនចំនេញ ។

**ផ្លាស់ទៅព្រៃខ្លូត**

អំឡុងចុងឆ្នាំ១៩៧៨ ប្រហែលខែតុលា ផល និងគ្រួសារ និងអ្នកផ្សេងទៀត ត្រូវអង្គការផ្លាស់ឲ្យទៅនៅភូមិព្រៃខ្លូត ។ ពេលទៅដល់ដំបូង អង្គការអនុញ្ញាតឲ្យសង់ផ្ទះដោយខ្លួនឯង សម្រាប់រស់នៅជាមួយគ្រួសារ ។ ផល បានរំឭកថា ទៅដល់ទីនោះ អ្នករស់នៅចាស់ដែលដឹងថា យើងជាអ្នកជម្លៀសមកពីបូព៌ា អ្នកទាំងនោះមិនពេញចិត្តនឹងជនចំណូលថ្មីនេះទេ ។ នៅក្នុងភូមិមានអណ្តូងទឹកមួយ តែត្រូវបិទជិតមិនឲ្យអ្នកថ្មីប្រើប្រាស់ទេ អ្នកជម្លៀសថ្មីទាំងអស់ ត្រូវស្វែងរកទឹកប្រើប្រាស់ដោយខ្លួនឯង ។ ទឹកដែលអាចរកបាន គឺរកតាមថ្លុក ឬទឹកជ្រោះ ហើយយកមកដាំផឹកតែប៉ុណ្ណោះ ។ ចំពោះការហូបចុកវិញ គឺរបបបានបាយមួយកូនវែកតូច បើប្រៀបធៀបនឹងភូមិចាស់ដែលគាត់រស់នៅ គឺមានការលំបាកជាង ។ នៅព្រៃខ្លូត អង្គការចាត់តាំង ផល ឲ្យចូលកងលីស្រូវ ចំណែកឯប្រពន្ធមាននាទីក្រងស្បូវសម្រាប់ប្រក់ដំបូលផ្ទះ ។

**មរណៈភាពកូន**

រស់នៅព្រៃខ្លូត មិនបានប៉ុន្មានផង កូនរបស់ ផល បានកើតជំងឺកញ្ជ្រិល ។ ដោយសារទីនោះ មិនមានពេទ្យ និងថ្នាំព្យាបាលត្រឹមត្រូវ ទើបមួយរយៈក្រោយមក កូនរបស់គាត់បានលាចាកលោកនេះទៅ ហើយ ផល ក៏មិនអាចធ្វើអ្វីបាន គឺត្រឹមតែសោកស្តាយចំពោះការស្លាប់របស់កូនប៉ុណ្ណោះ ។

**ការមកដល់របស់កងទ័ពវៀតណាម**

ប្រហែលជាចុងឆ្នាំ១៩៧៨ ឬដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាម បានវាយចូលមក ពេលនោះ គណៈគ្រប់គ្រងភូមិឃុំបាននាំគ្នារត់ភៀសខ្លួនអស់ ហើយអ្នកភូមិក៏នាំគ្នាភៀសខ្លួនដែរ ។ អ្នកភូមិមួយចំនួន ត្រូវខ្មែរក្រហមកៀរទៅជាមួយ ហើយមួយចំនួនទៀត ត្រូវវៀតណាមរំដោះបាននៅអំឡុងពេលធ្វើដំណើរ ។ ផល និងគ្រួសារ បាននាំគ្នាធ្វើដំណើរត្រឡប់មកក្រោយវិញ ដើម្បីស្វែងរកបងប្អូន ។ ពេលធ្វើដំណើរត្រឡប់ក្រោយ គាត់បានឲ្យដឹងថា កងទ័ពវៀតណាមតែងតែធ្វើការឆែកឆេររករបស់មានតម្លៃពីប្រជាជន ហើយគ្រួសារណាដែលមានកូនស្រី គឺត្រូវឲ្យកូនៗប្រឡាក់ភក់នឹងមុខ ឬកាត់សក់ ធ្វើយ៉ាងម៉េចមើលទៅឲ្យអាក្រក់មើល ដើម្បីចៀសផុតពីការចាប់បៀតបៀនរបស់កងទ័ពវៀតណាម ។

**ការជួបជុំបងប្អូនជាថ្មី**

ផល និងគ្រួសារ បានធ្វើដំណើរមកដល់ស្រុក ហើយបានសាកសួរអ្នកភូមិ និងអ្នកដំណើរពីដំណឹងបងប្អូនរបស់គាត់ ដែលបានបែកគ្នាតាំងពីថ្ងៃជម្លៀសមកពោធិ៍សាត់នេះម៉្លេះ ។ ក្រោយពីការខិតខំស្វែងរករបស់គាត់ពីម្នាក់ទៅម្នាក់ ទីបំផុតគាត់បានរកឃើញបងប្អូនគាត់វិញ ។ ក្រោយមក ផល និងក្រុមគ្រួសារ បានធ្វើដំណើរអស់ជាច្រើនថ្ងៃទើបមកដល់ភ្នំពេញ ។ អំឡុងពេលធ្វើដំណើរ ផល ប្រាប់ថា ពេលយើងមកដល់កន្លែងសម្រាកពេលយប់ ត្រូវរកកន្លែងណាដែលមានកងទ័ពវៀតណាមឈរជើង ព្រោះដើម្បីចៀសវាងពីការចាប់កៀររបស់ខ្មែរក្រហម ។

មកដល់ភ្នំពេញ ផល និងគ្រួសារ បានសម្រេចចិត្តធ្វើដំណើរបន្តទៅកាន់ស្រុកកំណើតនៅខេត្តព្រៃវែង ។ ពេលនោះ មានរថយន្តកងទ័ពវៀតណាម សម្រាប់ដឹកប្រជាជនដែលមានបំណងទៅខេត្ត និងបានជូនទៅដល់ត្រឹមកំពង់ចម្លងអ្នកលឿង ដោយមិនមានយកកម្រៃ ។ ក្រោយពីបានត្រឡប់មកដល់ស្រុកកំណើត ផល និងគ្រួសារ ចាប់ផ្តើមកសាងជីវិតជាថ្មី ដោយប្រកបរបរធ្វើស្រែ និងដាំដំណាំរហូតមកដល់បច្ចុប្បន្ន ។

**ធាវ សារៈមុនិន្ទ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០ ១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀននិងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល : truthmpechet@dccam.org ។

**◆ទីកន្លែង : អគារ "ក" ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិន សុធីតា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truththida.s@dccam.org ។




















# គេហទំព័រទស្សនាវដ្តីស្វែងរកការពិតជាភាសាខ្មែរ

# www.truthcambodia.com

ទស្សនាវដ្តីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។

គេហទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្តីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភ័ស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។

គេហទំព័រ www.truthcambodia.com បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។

អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើង ដោយស្មេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រឹតទ្បើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្តល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្តិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យដើម្បីសេចក្តីសុខក្នុងខ្លួនជាអមតៈដែរ ។

សរុបសេចក្តីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ធ្វើសេចក្តីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទ មុនការចេញផ្សាយ ។

គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។

# ហៀបនឹងស្លាប់ដោយសារច្រឡំ




អ៊ុំច ង៉ែត មានអាយុ៩៧ ឆ្នាំរស់នៅវត្តខណ្ឌាឡោម ក្រុងភ្នំពេញ ។ ង៉ែត មានស្រុកកំណើតនៅឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ ។ ង៉ែត បានរៀបការនៅក្នុងឆ្នាំ ១៩៤១ ជាមួយប្តី ដែលក្រោយមកធ្វើជាទំទប់លេខ ១ នៅឃុំបត់រការ ស្រុកសំរោង ខេត្តតាកែវ ។ នៅសម័យនោះ ង៉ែត មានជីវភាពធូធារ ព្រោះគ្រួសារគាត់មានដីស្រែច្រើន ម្យ៉ាងទៀត គាត់មានជីតាឈ្មោះ គង់ ធ្វើជាអាជ្ញាហ្លួង (ផ្នែកខាងប្រមូលពន្ធ) នៅក្នុងព្រះបរមរាជវាំង ក្នុងរជ្ជកាល ព្រះបាទសុរាម្រឹត ។

រៀងរាល់ឆ្នាំ គ្រួសារ ង៉ែត ប្រមូលផលស្រូវបានយ៉ាងច្រើន តែត្រូវទុកស្រូវមួយចំនួនបង់ពន្ធជូនទៅរាជការវិញ ។ ក្រោយមក ដើម្បីគេចពីការបង់ពន្ធនេះ គ្រួសារគាត់បានយកស្រូវមួយចំនួនទៅកប់ក្នុងរណ្តៅ មុនពេលរាជការចុះមកត្រួតពិនិត្យ និងកត់ត្រាពីចំនួនស្រូវដែលប្រមូលបាន ។

ប្តីរបស់ ង៉ែត បានធ្វើជាជំទប់ឃុំរហូតដល់ចុងទសវត្សរ៍ ឆ្នាំ ១៩៦០ ។ ក្រោយមក ខ្មែរក្រហមបានតាមរកចាប់ប្តីរបស់គាត់ ដោយសារអ្នកធ្វើការក្នុងឃុំជាមួយប្រណែន និងបានរាយការណ៍ទៅខ្មែរក្រហម ។ នៅពេលនោះ ប្តីរបស់ ង៉ែត បានរត់ពួននៅក្នុងពំនូកចំបើង ទើបបានរួចខ្លួន ។ ង៉ែត និងប្តី ព្រមទាំងកូនចំនួន៨នាក់ បានរត់គេចមករស់នៅភ្នំពេញ ដោយបានមិត្តភក្តិ និងបងប្អូនដែលធ្លាប់ធ្វើការនៅព្រះបរមរាជវាំងជួយឧបត្ថម្ភ និងរកកន្លែងឲ្យស្នាក់នៅបណ្តោះអាសន្ន ។ ចំណែកផ្ទះរបស់គាត់ឈើប្រក់ក្បឿងបីខ្នង នៅឯឃុំបត់រការ ស្រុកសំរោង ខេត្តតាកែវ ត្រូវខ្មែរក្រហមដុតបំផ្លាញចោលអស់គ្មានសល់ ។

ង៉ែត បានមកជួលផ្ទះស្នាក់នៅមុំផ្សារមិស ស្ថិតនៅខាងក្រោយមន្ទីរពេទ្យ (ព្រះសង្ឃ) ដោយប្តីរបស់គាត់ធ្វើជាគូលីនៅតាមផ្ទះ ចំណែកកូនប្រុសរបស់គាត់៣នាក់ចូលធ្វើការនៅហាងទំប៉ុង នៅកសិដ្ឋានចិញ្ចឹមមាន់ និងលក់ថ្នាំពេទ្យ ។ គ្រួសារ ង៉ែត នៅពេលនោះក៏ទទួលបានរបបឧបត្ថម្ភជាអង្ករពីអង្គការជួយជនភៀសខ្លួនដែលរត់គេចពីសង្គ្រាមរបស់អាមេរិកដែរ ។ ក្រោយមក ង៉ែត សន្សំប្រាក់បាន និងទិញផ្ទះបានចំនួនបីល្វែង ។ ង៉ែត បានជួលផ្ទះរបស់គាត់ពីរល្វែងយកប្រាក់ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ដោយទុកមួយល្វែងសម្រាប់រស់នៅខ្លួនឯង ។

នៅពេលខ្មែរក្រហមវាយចូលក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥ ង៉ែត និងគ្រួសារបានធ្វើដំណើរសំដៅទៅស្រុកកំណើតនៅឃុំបត់រការ ស្រុកសំរោង ខេត្តតាកែវវិញ ។ ប៉ុន្តែនៅតាមផ្លូវ យោធាខ្មែរក្រហម បានដកហូតយកម៉ូតូ និងសម្ភារៈមួយចំនួនពីគ្រួសារគាត់ ។ ង៉ែត និងគ្រួសារ មកដល់ឃុំបត់រការ បានមួយរយៈ ក៏ត្រូវកម្មាភិបាលភូមិឲ្យគ្រួសារគាត់ទៅរស់នៅភូមិតាពោនវិញ ។

គ្រួសារ ង៉ែត ដែលពេលនោះមានកូនចំនួន៨នាក់ ត្រូវបានអង្គការជម្លៀសតាមរថភ្លើងឲ្យទៅស្វាយស៊ីសូផុន ទើបអង្គការយករទេះគោមកទទួលបន្តយកទៅរស់នៅសង្កាត់ទឹកជោរ ក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ ង៉ែត និងប្តី ត្រូវខ្មែរក្រហមចាត់តាំងឲ្យដកស្ទូង និងភ្ជួរស្រែ ។ ចំណែកកូនរបស់គាត់៧នាក់ត្រូវបានចាត់តាំងឲ្យនៅកងលើកទំនប់ គឺនៅសល់តែកូនពៅម្នាក់ប៉ុណ្ណោះរស់នៅជាមួយគាត់ ។

ក្រោយមក អង្គការបានជ្រើសរើសប្តីរបស់ ង៉ែត ឲ្យមកធ្វើធ្មេញឈើសម្រាប់កង្ហាញ សារុង និងហូលវិញ ។ ចំណែក ង៉ែត នៅស្ទូងដដែល ហើយនៅពេលស្ទូងម្តងៗ គាត់តែងតែស្រែកយំ និងរត់ឡើងលើភ្លឺស្រែ ដោយសារតែគាត់ខ្លាចឈ្លើងទាម ។ ឃើញដូច្នេះ មិត្ត រ៉ង់ ប្រធានកងចល័តបានឲ្យ ង៉ែត មកនៅកងតម្បាញវិញ ។ ប៉ុន្តែមុននឹងមក មិត្ត រ៉ង់ ឲ្យ ង៉ែត ប្រលងសិន ហើយប្រសិនបើ ង៉ែត ធ្លាក់ ត្រូវនៅស្ទូងក្នុងកងដដែល ។

ង៉ែត បានចូលរួមប្រលងជាមួយសមាជិកកងចល័ត៣នាក់ផ្សេងទៀត មានឈ្មោះ គង់, យ៉ុន និង ហំ ដោយត្រូវប្រលងត្បាញក្រមា ។ ង៉ែត មិនដែលធ្លាប់ធ្វើការងារត្បាញនេះពីមុនមកទេ តែនៅពេលនោះ គាត់បានឲ្យប្តីរបស់គាត់ធ្វើធ្មេញឈើឲ្យ និងត្បាញទៅតាមអ្វីដែលគាត់សង្កេតឃើញកងត្បាញធ្វើពីមុនមក ។ នៅពេលបញ្ចប់ ង៉ែត បានឈ្នះដោយត្បាញមិនទាក់ ហើយអង្គការបានលើកចិត្ត ដោយបើកអង្ករ៣កំប៉ុងឲ្យគាត់ថែមទៀត ។

ចាប់តាំងពីពេលនោះមក ង៉ែត នៅធ្វើការក្នុងកងត្បាញសង្កាត់ទឹកជោរ និងទទួលបានរបបអង្ករមួយកំប៉ុងកន្លះក្នុងមួយថ្ងៃ ។ ដោយសារហូបមិនគ្រប់គ្រាន់ ង៉ែត បានយកមាសទៅដូរយកអង្ករជាមួយប្រជាជនមូលដ្ឋានទុកឲ្យកូនៗរបស់គាត់ហូប ។ ថ្ងៃមួយមានអ្នកលួចអង្ករពីរោងម៉ាស៊ីនស្រូវ ពេលនោះប្រធានកងឈ្លបសង្កាត់ឈ្មោះ ឆយ បានចោទ ង៉ែត ថាជាអ្នកលួចព្រោះរកឃើញអង្ករដូរជាមួយអ្នកមូលដ្ឋាន នៅក្នុងផ្ទះរបស់ ង៉ែត ។ ឆយ បានចងដៃ ង៉ែត ទាំងពីរទៅក្រោយ រួចបណ្តើរទៅសួរចម្លើយនៅសាលាឃុំ ទោះបី ង៉ែត បានឆ្លើយបដិសេធយ៉ាងណាក៏ដោយ ។ ចំណែកប្តីរបស់ ង៉ែត មិនហ៊ានតវ៉ាទេ គឺគាត់បានត្រឹមតែឈរសម្រក់ទឹកភ្នែកដោយអស់សង្ឃឹម ។

ដំណឹងចាប់ខ្លួន ង៉ែត នៅថ្ងៃនោះបានលេចឮទៅដល់ វ៉ង់ ប្រធានកងចល័តសង្កាត់ ។ វ៉ង់ បាន មកជួប ឆយ និងបានតវ៉ាថា "ពុក1 សូមពិនិត្យមើលឲ្យជាក់ម្តងទៀត អង្ករបស់ ង៉ែត គឺជាអង្ករបស់អង្គការចែកឲ្យ មិនមែនអង្ករលួចពីរោងម៉ាស៊ីនស្រូវទេ" ។ បន្ទាប់ពីមានការតវ៉ាខ្លាំងៗយ៉ាងនេះ ទើបប្រធានឈ្លបបានយល់ព្រមដោះលែង ង៉ែត ឲ្យមានសេរីភាពវិញ ។

នៅឆ្នាំ១៩៧៩ ង៉ែត និង ប្តី ព្រមទាំងកូនរបស់គាត់ទាំង៨នាក់បានត្រឡប់មកភ្នំពេញវិញ ។ ក្រោយមក ង៉ែត និង ប្តីបានសម្រេចចិត្តមករស់នៅ និងរៀនសូត្រធម៌អាចារ្យនៅវត្តខណ្ឌាឡោម ចំណែកកូនៗរបស់គាត់ទាំងអស់បានរៀបការ និងបានចូលធ្វើការងារនៅតាមក្រសួង និង មន្ទីរផ្សេងៗ នៅក្នុងរដ្ឋាភិបាល ។

ង៉ែត មានប្រសាសន៍ថា គ្រួសារគាត់មានសំណាងដោយមិនសមាជិកណាម្នាក់ស្លាប់ ប៉ុន្តែគាត់ក៏មិនភ្លេចដែរនូវការលំបាក ការអត់ឃ្លាន និងភាពភ័យរន្ធត់ក្នុងរបបខ្មែរក្រហម ។ **សោម ប៊ុនថន**



កងនារីនៅក្នុងរោងចក្រតម្បាញ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥-១៩៧៩

# ចូលខ្មែរក្រហមដោយសារកំហឹង


ចាន់ វិចិត្រ

ដោយសារតែការគាបសង្កត់ និងការរឹបអូសយកស្រូវអង្ករ ចាន់ វិចិត្រ បានសម្រេចចិត្តចូលខ្មែរក្រហម ដើម្បីសងសឹកចំពោះអ្នកដែលបានប្រព្រឹត្តមកលើក្រុមគ្រួសារគាត់ ។

វិចិត្រ មានអាយុ៦២ឆ្នាំ មានស្រុកកំណើតនៅភូមិអង្គឃ្លៃ ឃុំត្រមែង ស្រុកឈូក ខេត្តកំពត ។ វិចិត្រ មានឪពុកឈ្មោះ ចាន់ ចន និងម្តាយឈ្មោះ ខៀប ទន ។

វិចិត្រ បានរៀនដល់ថ្នាក់ទី២ (ពីសង្គមចាស់) នៅវិទ្យាល័យឈូក ។ នៅឆ្នាំ១៩៧០ វិចិត្រ បានឈប់រៀន ដោយសារតែរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ហើយម្យ៉ាងទៀត នៅពេលនោះក្រុមខ្មែរក្រហមបានកេណ្ឌ និងប្រមូលសិស្សនៅតាមសាលាឲ្យធ្វើការតវ៉ាប្រឆាំងទៅនឹងរដ្ឋប្រហារនេះ ។ មានសិស្សជាច្រើនបានចូលរួមការតវ៉ានេះ ។ ចំណែក វិចិត្រ មិនបានចូលរួមទេនៅពេលនោះ គឺគាត់ត្រឡប់មកជួយធ្វើការងារស្រែចម្ការឪពុកម្តាយវិញ ។

នៅសម័យនោះ ឪពុកម្តាយ វិចិត្រ មានស្រូវច្រើនជាងគេនៅក្នុងភូមិ ។ ក្រោយមក ខ្មែរក្រហមបានរៀបចំរចនាសម្ព័ន្ធដឹកនាំនៅតាមភូមិ ឃុំ ស្រុក ចុះមកកើបយកស្រូវពីផ្ទះរបស់ វិចិត្រ មួយលើកជាពីរលើក តែឪពុកម្តាយរបស់ វិចិត្រ មិនបានជំទាស់ទេ ។ នៅលើកទីបី ដោយសារមិនពេញចិត្តនឹងទង្វើនេះ ឪពុករបស់ វិចិត្រ បានចូលទៅវាយអ្នកមកកើបស្រូវរបស់គាត់នៅក្នុងជង្រុក ចំណែក វិចិត្រ បានចាំវាយនៅច្រកចូលជង្រុក ។

រឿងរ៉ាវទាំងនេះ បានដឹងដល់ តាកុត ដែលជាកម្មាភិបាលខ្មែរក្រហមថ្នាក់ស្រុក ទើប តាកុត បានកោះហៅ វិចិត្រ និង ឪពុកទៅជួប ជាហេតុធ្វើឲ្យឪពុក និងកូនមានការភិតភ័យយ៉ាងខ្លាំង ។ ប៉ុន្តែ មេភូមិបានមកប្រាប់ឪពុក វិចិត្រ ថា «បើសិនជាមានកម្មាភិបាលខ្មែរក្រហមមកពីស្រុករកចាប់អ៊ីឯង ខ្ញុំនឹងផ្តល់សញ្ញាឲ្យអ៊ីឯងដឹង» ដូចជា ដេញគោ-ក្របីបង្អើល នោះអ៊ីរត់គេចខ្លួនចុះ ។ ខណៈនោះ ហេតុការណ៍បានកើតឡើង ឪពុករបស់ វិចិត្រ និង វិចិត្រ បានរត់ចូលព្រៃគេចខ្លួន ។ មួយសន្ទុះក្រោយមក ក៏ឃើញកម្មាភិបាលខ្មែរក្រហមមកពីស្រុកដើរចូលមកភូមិ ។ ក្រោយមក វិចិត្រ បានទទួលដំណឹងថា អង្គការបានរៀបចំផែនការសម្លាប់ឪពុកគាត់ ទើបឪពុករបស់គាត់បានសម្រេចចិត្តលេបថ្នាំសម្លាប់ខ្លួន ព្រោះមិនចង់ឲ្យខ្មែរក្រហមចាប់ខ្លួន ។

ដោយគ្មានវិធីរត់គេចខ្លួន វិចិត្រ ក៏បានសម្រេចចិត្តសម្លាប់ជ្រូកយកសាច់ឧបត្ថម្ភដល់កងទ័ព និងសុំអង្គការចូលធ្វើយោធា ហើយនៅពេលគាត់ទទួលបានកាំភ្លើង គាត់នឹងត្រឡប់មកបាញ់សម្លាប់អ្នកដែលមកកើបស្រូវរបស់គាត់ចោលទាំងអស់ ។ ប៉ុន្តែ នៅពេលមកដល់ខ្សែត្រៀម អង្គការមិនព្រមទទួលឲ្យគាត់ចូលធ្វើយោធាទេ ព្រោះគាត់ស្ថិតក្នុងវណ្ណៈអនុជនសិស្ស ។ ដូច្នេះ វិចិត្រ ក៏សុំកងទ័ពស្នាក់នៅមួយរយៈ ។

នៅឆ្នាំ១៩៧៣ វិចិត្រ បានស្នាក់នៅជាមួយយោធាខ្មែរក្រហម នៅខ្សែត្រៀមវត្តស្វែង (ខាងត្បូងភ្នំពេញ) ហើយនៅពេលនោះ អង្គការក៏ចាត់តាំងឲ្យ តាអឿន ចុះទៅស្រាវជ្រាវពីប្រវត្តិរូបរបស់ វិចិត្រ នៅមូលដ្ឋានថែមទៀតដែរ ។

ក្រោយមក កងទ័ព លន់ នល់ បានវាយយោធាខ្មែរក្រហមរហូតបាក់ទ័ព រត់ចោលសមរភូមិអស់ជាច្រើន ។ ពេលនោះ មេបញ្ជាការបានសួរ វិចិត្រ ថា តើឯងចេះបាញ់ទេ? ឮដូច្នេះ វិចិត្រ ក៏ឆ្លើយថាចេះ ទើបមេបញ្ជាប្រគល់បេមកឲ្យគាត់កាន់ ។ ចំណែក កងទ័ព លន់ នល់ រួមជាមួយរថក្រោះក៏សម្រុកចូលមកដែរ ។ មេបញ្ជាការបានបញ្ជាឲ្យ វិចិត្រ បាញ់ឆេះរថក្រោះអស់ពីរគ្រឿង ។ បន្ទាប់មក នីរសារបាននាំ វិចិត្រ រត់គេចខ្លួនមកទីបញ្ជាការកងទ័ពទាំងភិតភ័យ ។ នៅទីនោះ អង្គការបានបញ្ជាយោធាឲ្យនាំ វិចិត្រ ទៅ

*សាកសួរពីការបាញ់រថក្រោះ ធ្វើឲ្យគាត់កាន់តែមានការភិតភ័យ ព្រោះគាត់នៅសង្ស័យថា កងទ័ព លន់ នល់ បើករថក្រោះមកប្រគល់ឲ្យខ្មែរក្រហម ។ វិចិត្រ បានឆ្លើយរៀបរាប់ប្រាប់អង្គការនូវហេតុការណ៍នៃការបាញ់រថក្រោះនោះទាំងញាប់ញ័រ ក្រោយពីបានស្តាប់រួចហើយទើបអង្គការ ប្រគល់សាក់កាដូ និងខោអាវ និងជ្រើសរើសឲ្យគាត់ចូលជាយោធានៅពេលនោះ ។ ចាប់តាំងពីពេលនោះមក គំនុំគំគួនរបស់គាត់ជាមួយកម្មាភិបាលខ្មែរក្រហមនៅស្រុកកំណើតបានរសាយអស់ ។*

*វិចិត្រ បានចូលជាយុទ្ធជន ដែលមានឈ្មោះ វ៉ែន ជាមេបញ្ជាការវរសេនាធំ និងឈ្មោះ ប៊ិត ជាប្រធានកងពល ។ នៅខែធ្នូ ឆ្នាំ១៩៧៤ ខ្មែរក្រហមបានរៀបចំ និងប្រជុំទ័ពនៅត្រាំខ្នារ ដើម្បីកំណត់ទិសដៅវាយចូលភ្នំពេញ រហូតដល់រំដោះនៅឆ្នាំ១៩៧៥ ។ ស្របពេលនេះ វិចិត្រ ក៏ត្រូវអង្គការចាត់តាំងឲ្យចូលធ្វើជានីរសារកងវរសេនាតូចលេខ៣១០ ដែលមានតាភា ជាមេបញ្ជាការដែរ ។ ក្រៅពីការងារជានីរសារ វិចិត្រ មានតួនាទីសរសេរសេចក្តីជូនដំណឹង និងរបាយការណ៍ចែកអង្ករ និងម្ហូបអាហារដល់យោធា ដោយសារគាត់សរសេរអក្សរស្អាត ។*

*កងវរសេនាតូចលេខ៣១០របស់ វិចិត្រ ត្រូវបានអង្គការឲ្យមកបោះទីតាំងនៅវត្តត្រកៀតឃុំទួលកី ស្រុកអង្គស្នួល ខេត្តកណ្តាល ចំណែកកងផ្សេងទៀតត្រូវបានអង្គការបញ្ជូនឲ្យទៅជួសជុលផ្លូវរថភ្លើងនៅខេត្តតាកែវ ។ ក្រោយមក វិចិត្រ បានមកនៅក្នុងវរសេនាធំលេខ១១ ជាមួយ តាភា នៅពេលដែល តាភា ត្រូវបានអង្គការដំឡើងឋានៈជាប្រធានវរសេនាធំជំនួស វ៉ែន ដែលត្រូវបានដំឡើងជាប្រធានកងពល ។ មូលហេតុដែល វិចិត្រ មករស់នៅជាប់ជាមួយ តាភា ព្រោះ វិចិត្រ ធ្លាប់បានសរសេរសំបុត្រទាក់ទងនារីដែលធ្វើការនៅក្នុងកងនារីរបស់កងពលឲ្យ តាភា ធ្វើប្រពន្ធ កាលពីនៅទួលកី ។*

*នៅឆ្នាំ១៩៧៦ កងរបស់ វិចិត្រ ត្រូវអង្គការដកទៅការពារព្រំដែន នៅក្នុងខេត្តតាកែវវិញ ។ កងវរសេនាធំរបស់ វិចិត្រ បានបោះទីតាំងក្នុងឃុំកំពង់អំពិល ស្រុកកោះអណ្តែត ជាប់ព្រំប្រទល់វៀតណាម ។*

*ក្រៅពីតួនាទីការពារព្រំដែន គាត់ត្រូវចុះធ្វើស្រែជាមួយកងទ័ព ។ បន្ទាប់ពីច្រូត និងប្រមូលផលស្រូវ ឆ្នាំ១៩៧៧ រួចរាល់កងទ័ពវៀតណាមបានវាយសម្រុកចូលមកដល់ទីរួមខេត្តតាកែវ ធ្វើឲ្យកងយោធាខ្មែរក្រហមបាក់ទ័ពរត់ចោលសមរភូមិជាច្រើន ។ ដូច្នេះហើយ ទើបអង្គការប្រមូលកម្មករ នៅភ្នំពេញមកបំពាក់អាវុធ រួចបញ្ជូនទៅវាយរហូតដល់កងទ័ពវៀតណាមដកទ័ពត្រឡប់ទៅវិញ ។*

*ក្រោយមក តាម៉ុក បានដក វិចិត្រ ឲ្យទៅឈរជើងនៅខេត្តស្វាយរៀងវិញ និងបានចាត់តាំងសមាសភាពដឹកនាំថ្មី ដោយ អៀង ផាន ឡើងជាប្រធានវរសេនាធំ (ក្នុងកងពលលេខ៣៤០) ឈាង អនុប្រធាន ហើយគាត់ (វិចិត្រ) ជាសមាជិក ។ ចំណែក តាភា បានឡើងទៅកាន់កងពលប្រចាំនៅព្រំដែនតាកែវ ។ កងរបស់ វិចិត្រ បានបោះទីតាំងនៅស្ពានតាហោ ក្នុងទីរួមខេត្តស្វាយរៀង និងឡើងទៅវាយនៅស្រុកប្រសូត្រ ។ វិចិត្រ ទៅដល់ខេត្តស្វាយរៀង បានរយៈពេលប្រមាណពីរខែក៏ត្រូវរបួស ដោយសារវៀតណាមផ្លោងគ្រាប់ត្រូវ ។ វិចិត្រ ត្រូវបានបញ្ជូនមកព្យាបាលនៅពេទ្យព-១៧ (ពេទ្យរុស្ស៊ី) រហូតដល់ទ័ពវៀតណាមវាយចូលមកនៅឆ្នាំ១៩៧៩ ។*

*វិចិត្រ បានភៀសខ្លួនតាមរថភ្លើងទៅខេត្តបាត់ដំបង ដោយពេលនោះមានយោធាដែលបាក់ទ័ពប្រមាណ៣០០នាក់ រួមដំណើរជាមួយផង ។ វិចត្រ បាននាំទ័ពទាំងនោះទៅបោះទីតាំងនៅក្នុងព្រៃ ។ ក្រោយមក អង្គការបានប្រមូលយោធាដើម្បីធ្វើសន្និបាតនៅស្រុកកំរៀង និងស្នើសុំដកកងទ័ពពី វិចិត្រ ទៅឲ្យ តាជៀម (ត្រូវជាអង្គរក្សរបស់ ប៉ុល ពត) គ្រប់គ្រង រួចហើយឲ្យ វិចិត្រ ទៅរៀនសូត្រវិញ ។ ប៉ុន្តែការស្នើសុំនេះ ត្រូវបាន វិចិត្រ បដិសេធ រួចដឹកនាំកងយោធារបស់គាត់ទាំង អស់មកបោះទីតាំងនៅម្តុំកូនដំរី ក្នុងស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យវិញ ។*

*ក្រោយមក អង្គការបាន បញ្ជាឲ្យ តាបៃ មេបញ្ជាការកងទ័ពខ្មែរក្រហម ដឹកនាំទ័ពមកវាយ វិចិត្រ ។ ហេតុនេះហើយទើប វិចិត្រ បាននាំទ័ពមកចុះចូលជាមួយវៀតណាមវិញ ។*

*វិចិត្រ បានត្រឡប់មករស់នៅស្រុកកំណើតរបស់ខ្លួនមួយរយៈ ទើបគាត់និងគ្រួសារផ្លាស់មករស់នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ រហូតមកដល់សព្វថ្ងៃ ។*

**សោម ប៊ុនថន**

# កន្លែងមួយដែលស្ទើរតែត្រូវបានបំភ្លេច

សម័យដែលធ្វើឲ្យប្រទេសកម្ពុជាខ្ទេចខ្ទីបានកើតមានឡើង តាំងពីអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយក៏ជាពេលប្រទេសជាតិទាំងមូលធ្លាក់ដល់ចំនុចសូន្យដែរ ដោយសារតែធនធានមនុស្សត្រូវបានខ្មែរក្រហមសម្លាប់រង្គាល ។ ប៉ុល ពត គិតថា ប្រជាជនទាំងនោះគឺជាសត្រូវដែលត្រូវតែកម្ទេចចោលជាដាច់ខាត ។ ដោយសារតែហេតុនេះហើយ បានជា ប៉ុល ពត បង្កើតឲ្យមានមន្ទីរសន្តិសុខជាច្រើនក្នុងសម័យនោះ ក្នុងគោលបំណងដើម្បីធ្វើបន្សុទ្ធកម្មនិងអប់រំដល់អ្នកទោសជាប់ឃុំឃាំងទាំងនោះ ។ ដោយបានរងទុកវេទនា ជាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខរបស់ ប៉ុល ពត ប្រជាជនកម្ពុជាស្លូតត្រង់ប្រមាណជិតពីរលាននាក់បានស្លាប់ និងបានបន្សល់ទុកអ្នករស់រានមានជីវិតដែលសុទ្ធសឹងជាជនរងគ្រោះដែលទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរផ្នែកផ្លូវចិត្ត ។ ក្រោយរបបខ្មែរក្រហម មានគ្រោងឆ្អឹង លលាដ៏ក្បាលរបស់ជនរងគ្រោះទាំងនោះ និងមន្ទីរសន្តិសុខរបស់ខ្មែរក្រហមនៅរាយពាសពេញប្រទេសកម្ពុជា ។ ប៉ុន្តែឆ្អឹង និងលលាដ៏ក្បាល រួមទាំងមន្ទីរសន្តិសុខមួយចំនួនមិនត្រូវបានយកចិត្តទុកដាក់ថែរក្សាទេ ។

ក្នុងភូមិដាច់ស្រយ៉ាលមួយ គឺភូមិត្រពាំងវែង ឃុំប្រទៀង ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានអតីតមន្ទីរសន្តិសុខខ្មែរក្រហមមួយមានចម្ងាយប្រមាណពីរគីឡូម៉ែត្រ ពីបណ្តោយផ្លូវជាតិលេខ៦ និងជាអតីតកន្លែងសម្លាប់មនុស្ស ដែលប្រជាជនទូទៅស្គាល់ថា ជាមន្ទីរ



អតីតមន្ទីរសន្តិសុខ វត្តកណ្តាល ក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ ក្នុងរបបកម្ពុជាប្រជាធិតេយ្យ ពីឆ្នាំ១៩៧៥ - ១៩៧៩


ទិដ្ឋភាពខាងក្នុងមន្ទីរសុខ ក្នុងពេលបច្ចុប្បន្ន


កន្លែងតម្កល់អដ្ឋិធាតុជនរងគ្រោះក្នុងរបបខ្មែរក្រហម ក្នុងវត្តកណ្ដាល

សន្តិសុខ "វត្តកណ្ដាល" ឬ "វត្តល្វាកណ្ដាល" ទីនេះ គឺជាអតីតគុកសម្រាប់ឃុំឃាំង និងធ្វើទារុណកម្មអ្នកទោស ដោយអ្នកទាំងនោះភាគច្រើនត្រូវបានឈ្លបចាប់មកពីភូមិជិតៗ ដូចជា ភូមិរស្មី ភូមិប្រទាង និងភូមិស្វាយោង ។ អតីតមន្ទីរសន្តិសុខវត្តកណ្ដាលខុសពីអតីតមន្ទីរសន្តិសុខផ្សេងៗទៀត មានដូចជា មន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង និងវាលពិឃាដជើងឯក ដោយសារតែកន្លែងទាំងនោះត្រូវបានទទួលការយកចិត្តទុកដាក់ពីរដ្ឋាភិបាល និងបណ្ដាអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ។ ក្រោយទសវត្សរ៍ឆ្នាំ៩០ ចំនួនអ្នកទោសនៅក្នុងមន្ទីរសន្តិសុខវត្តកណ្ដាលសរុប ត្រូវបានផ្ដល់ជាមួយតួរលេខមិនផ្លូវការតាមរយៈអ្នកស្រុកដែលបានប្រាប់ថា មានអ្នកស្លាប់រហូតដល់ទៅ១០.០០០នាក់ ។ ការគណនាមិនផ្លូវការបែបនេះនៅតែមាន ហើយរហូតមកដល់ពេលឥឡូវនេះក៏មិនមានកម្មវិធី ឬគម្រោងណាមួយជួយអភិរក្ស និងសិក្សាឲ្យបានត្រឹមត្រូវលើទីតាំងគុកនេះនៅឡើយដែរ ។

ក្រោយពេលរបបខ្មែរក្រហមដួលរលំ គ្រោងឆ្អឹងសាកសពលលាដ៍ក្បាល និងឧបករណ៍ធ្វើទារុណកម្មជាច្រើននៅក្នុងបរិវេណវត្តកណ្ដាល និងនៅក្នុងវាលស្រែជុំវិញវត្តនេះ នៅរាយប៉ាយ និងមិនបានទុកដាក់ឲ្យបានត្រឹមត្រូវនោះទេ ។ រហូតមកដល់បច្ចុប្បន្នឧបករណ៍ដូចជា ខ្នោះដៃ ខ្នោះជើង និងឆ្អឹងនៅអតីតមន្ទីរសន្តិសុខវត្តកណ្ដាលបានបាត់បង់ស្ទើរតែទាំងអស់ទៅហើយ ដែលឧបករណ៍ទាំងនេះសុទ្ធសឹងជាប្រយោជន៍សម្រាប់ទុកជាភស្តុតាងដែលបន្សល់ទុកពីរបបខ្មែរក្រហម ។

គំនរឆ្អឹងជាច្រើនស្ថិតនៅរាយប៉ាយរណ្ដៅដែលពេញវាលស្រែក្រោមកម្ដៅថ្ងៃ ព្រមទាំងទទួលរងនូវសំណើកដោយសារខ្យល់ និងភ្លៀងអស់រយៈពេលជាច្រើនឆ្នាំមក ។ គំនរឆ្អឹង និងលលាដ៍ក្បាលរបស់ជនរងគ្រោះទាំងនេះ នៅតែដាក់តាំងដោយមិនមានសណ្ដាប់ធ្នាប់ និងមិនបានរៀបចំដាក់ក្នុងកន្លែងត្រឹមត្រូវនៅឡើយ ។ អ្នកស្លាប់ទាំងនោះប្រហែលជាក្ដៅ និងហត់នឿយ និងប្រហែលជាឆ្ងល់ថា ហេតុអ្វីបានជាគ្មាននណាអើពើនឹងគាត់ ។ ទោះបីជាកាលនៅរស់ អ្នកស្លាប់ទាំងនោះត្រូវបានខ្មែរក្រហមធ្វើបាប បង្អត់បាយ

និងកាប់សម្លាប់យ៉ាងណាក៏ដោយ ក៏ក្រោយមក គ្រោងឆ្អឹងរបស់គាត់នៅតែមិនទាន់ទទួលបានការថែរក្សាឲ្យបានត្រឹមត្រូវ ។ដូចនេះ វាហាក់ដូចជាអយុត្តិធម៌ចំពោះអ្នកស្លាប់ទាំងនោះ ព្រោះក្តីរំពឹងចុងក្រោយរបស់គាត់គឺគ្រាន់តែចង់ឲ្យលលាដ៍ក្បាល និងគ្រោងឆ្អឹងរបស់គាត់ត្រូវបានរៀបចំដាក់ក្នុងចេតិយឲ្យបានត្រឹមត្រូវ ឬបូជា និងធ្វើបុណ្យតាមបែបសាសនា ឬបង្កើនឲ្យមានការយល់ដឹងជាសាធារណដល់ក្មេងជំនាន់ក្រោយ ។

រហូតមកដល់ទសវត្សរ៍ឆ្នាំ៩០ ឡោ ឡៅ ជាជនរងគ្រោះពីរបបខ្មែរក្រហម បានចំណាយថវិកាផ្ទាល់ខ្លួនសាងសង់ចេតិយរួមមួយសម្រាប់ដាក់ឆ្អឹងរបស់អ្នកស្លាប់ទាំងនោះ ប៉ុន្តែមានតែឆ្អឹងបន្តិចបន្តួចប៉ុណ្ណោះដែលនៅសល់ បន្ទាប់ពីត្រូវបានបោះបង់ចោល និងសត្វឆ្កែពាំយកទៅ បូករួមទាំងកក្តារូបសាស្ត្រ និងគីមីសាស្ត្រផ្សេងៗទៀត ។ ជាសំណាង ដែលខ្ញុំ និងក្មេងៗជំនាន់ក្រោយនៅអាចមើលឃើញចេតិយនោះផ្ទាល់ភ្នែកហើយបានខន្តិសទៅដល់វិញ្ញាណក្ខន្ធរបស់អ្នកស្លាប់ដោយអយុត្តិធម៌ទាំងនោះឲ្យបានស្ងប់សុខ ។

ចេតិយនោះ ស្ថិតនៅក្រោមម្លប់ដើមឈើធំមួយ នៅពីមុខស្រះហ្លួតហែង ដែលពោរពេញដោយសំរាម និងកម្ទេចមែកឈើពុកផុយ ។ មិនត្រឹមតែប៉ុណ្ណោះកញ្ចក់បង្អួចចេតិយមានសភាពបែកបាក់ និងមានសុទ្ធតែធូលីប្រឡាក់ជាប់ជញ្ជាំងពិបាកនឹងលុបចោល ដែលកំពុងរង់ចាំការយកចិត្តទុកដាក់ពីសាធារណជន ដែលដើរឆ្លងកាត់ទីកន្លែងនោះ ។ សព្វថ្ងៃនេះ រាល់ពេលដែលមានពិធីបុណ្យបែបពុទ្ធសាសនាណាមួយ គឺមានអ្នកភូមិមួយចំនួនបានយកបាយម្ហូបទៅសែននៅចេតិយនោះ ។

ក្រៅពីចេតិយដែលមិនទាន់ត្រូវបានស្រាវជ្រាវនេះ នៅក្នុងវត្តកណ្តាលក៏មានអគារបាកបែកចំណាស់មួយ ដែលជាកន្លែងអ្នកទោសរបស់ខ្មែរក្រហមត្រូវបានឃុំឃាំងធ្វើទារុណកម្មសួរចម្លើយ និងសម្លាប់ ។ អគារចាស់មួយនោះ ស្ថិតនៅក្នុងបរិវេណវត្តតែម្តង ក៏ប៉ុន្តែមិនសូវមានអ្នកចាប់អារម្មណ៍នោះទេ ហើយក៏មិនសូវមានអ្នកណាដឹងថាវាគឺជាអតីតគុកខ្មែរក្រហមដែរ គឺមានតែចាស់ៗដែលរស់នៅម្តុំនោះប៉ុណ្ណោះដែលដឹងរឿងនេះ ។ ទន្ទឹមនោះ អ្នកភូមិចាស់ៗទាំងនោះក៏មិនសូវមានឱកាសនិយាយ និងផ្សព្វផ្សាយរឿងរ៉ាវនេះទៅកាន់ក្មេងៗជំនាន់ក្រោយនោះដែរ ហើយអ្នកភូមិទាំងនោះក៏មិនសូវចាប់អារម្មណ៍ដែរ ។

អគារនេះមិនត្រឹមតែមិនត្រូវបានថែរក្សាឲ្យបានត្រឹមត្រូវទេ តែបែរជាយកទៅប្រើប្រាស់សម្រាប់ដាក់របស់របរចាស់ៗ និងពោរពេញដោយសំរាម និងស្នាមគូសលើជញ្ជាំងទៅវិញ ជាជាងអភិរក្សកន្លែងនោះទៅជារមណីយដ្ឋានប្រវត្តិសាស្ត្រ ដើម្បីទាក់ទាញភ្ញៀវទេសចរ ។ ជាការពិត វាមិនមែនជារឿងចម្លែកទេ ដែលថាមានមនុស្សមកព្យាយាមរុះរើវាយកម្ទេចអគារចំណាស់មួយនេះ ក៏ប៉ុន្តែព្រះសង្ឃរាជក្នុងវត្តនេះ បានធ្វើការហាមឃាត់មិនឲ្យរុះរើ ព្រោះព្រះអង្គចង់ទុកអគារនេះជាភស្តុតាងប្រវត្តិសាស្ត្រដែលសេសសល់ពីរបបខ្មែរក្រហម ។ អ្នកភូមិម្នាក់ឈ្មោះ ឯល សុមេធា ដែលបច្ចុប្បន្នធ្វើជាគ្រូបង្រៀន បានផ្តល់ព័ត៌មាន រួមជាមួយក្តីព្រួយបារម្ភថា «គ្មាននរណាម្នាក់មកស្រាវជ្រាវ និងសិក្សាពីអំពីអគារប្រវត្តិសាស្ត្រនេះទេ ។ អគារនេះក៏មិនខុសអ្វីពីគុកទួលស្លែងដែរ» ។

សព្វថ្ងៃនេះ វត្ថុដែលនៅសេសសល់ពីសម័យនោះ ដូចជាខ្នោះដៃត្រូវបានបាត់បង់អស់ទៅហើយ ។ បើតាមការចង់បានរបស់សុមេធា អគារនេះ ក៏ដូចជាចេតិយដែរ គឺកំពុងតែស្នើសុំឲ្យមានការអន្តរាគមន៍ពីសំណាក់រាជរដ្ឋាភិបាល និងអង្គការនានា ដោយបង្កើតឲ្យមាននូវការអភិរក្សតំបន់នោះ ។ បើមិនអ៊ីចឹងទេ ប្រវត្តិសាស្ត្រប្រាកដជាបាត់បង់ ដោយក្មេងជំនាន់ក្រោយមិនបានដឹងពីប្រវត្តិសម័យខ្មែរក្រហម ហើយវិញ្ញាណក្ខន្ធរបស់អ្នកស្លាប់ទាំងនោះក៏ប្រាកដជាមិនបានស្ងប់ដែរ ។

ដោយផ្អែកទៅលើស្ថានភាពបច្ចុប្បន្ន នៅទីកន្លែងនេះ នឹងមិនអាចទទួលបានយុត្តិធម៌ និងការពិតសម្រាប់វិញ្ញាណក្ខន្ធជនរងគ្រោះទាំងនោះទេ ប្រសិនជាគេមិនបានបង្កើតកម្មវិធីទាក់ទងនឹងការទទួលខុសត្រូវដើម្បីជួយឲ្យទីកន្លែងនោះក្លាយជាកន្លែងប្រវត្តិសាស្ត្រ និងមានការដឹងឮពីសាធារណជនក្នុងតំបន់ ។

សព្វថ្ងៃនេះ ប្រទេសកម្ពុជាមានការផ្លាស់ប្តូរជាច្រើនវិស័យ ហើយបានឈានឆ្ពោះទៅការអភិវឌ្ឍន៍ ក៏ប៉ុន្តែអ្វីដែលកម្ពុជាមិនអាចកែប្រែបាននោះគឺ ប្រវត្តិសាស្ត្រ ។

**ខេង សៀងហៃ**

# ពិព័រណ៍ខ្មែរក្រហមនៅវត្តថ្មី សៀមរាប

មជ្ឈមណ្ឌលឯកសារកម្ពុជាបានពង្រីកការផ្សព្វផ្សាយពីប្រវត្តិសាស្ត្រដ៏ជូរចត់នៃរបបខ្មែរក្រហម តាមរូបភាព និងមធ្យោបាយផ្សេងៗ រួមទាំងការតាំងពិព័រណ៍ផង ។

វត្តថ្មី ហៅវត្ត ទេពពោធិវង្ស ដែលស្ថិតនៅកណ្តាលក្រុងសៀមរាប គឺជាទីតាំងមួយក្នុងចំណោមទីតាំងជាច្រើនដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានដាក់តាំងពិព័រណ៍ប្រវត្តិសាស្ត្រខាងលើ ។ កាលពីសប្តាហ៍មុន ខ្ញុំបានចំណាយពេល៣ម៉ោង ដើម្បីអង្កេតមើលភ្ញៀវចេញចូលទស្សនាវត្តថ្មីដោយយកចិត្តទុកដាក់ ។ លោក បូរិទ្ធ អាយុ៣៦ឆ្នាំ គឺជាអ្នកនាំភ្ញៀវដែលនិយាយភាសាអង់គ្លេស ។ លោកបាននិយាយប្រាប់ខ្ញុំថា ភ្ញៀវអឺរ៉ុបមានការចាប់អារម្មណ៍ខ្លាំងលើពិព័រណ៍ខាងលើ ដោយភ្ញៀវទាំងនោះភាគច្រើនចំណាយពេលយូរមើលពិព័រណ៍ និងអានព័ត៌មានទាំងអស់ដែលមានលើផ្ទាំងរូបភាពនីមួយៗ ។ លោកយល់ថានេះគឺដោយសារភ្ញៀវអឺរ៉ុបភាគច្រើនបានអានព័ត៌មានពីខ្មែរច្រើនមុននឹងមកលេងស្រុកខ្មែរ ។ លោកបានឲ្យដឹងថា សំណួរភាគច្រើនត្រូវបានសួរអំពីចំនួនមនុស្សស្លាប់ក្នុងរបបខ្មែរក្រហម និងអំពីការទទួលខុសត្រូវរបស់អ្នកដែលប្រព្រឹត្ត ។ លោកបន្ថែមថា ចំពោះសំណួរខាងក្រោយគឺលោកនិយាយប្រាប់ភ្ញៀវដោយផ្អែកលើពិព័រណ៍មួយផ្ទាំង ដែលនិយាយអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ការចាប់អារម្មណ៍ខ្លាំងមួយទៀតដែលខ្ញុំចង់និយាយ គឺទាក់ទងនឹងការមកទស្សនាពិព័រណ៍នៅវត្តថ្មី ដោយភ្ញៀវមកពីកូរ៉េ ។ នៅថ្ងៃនោះ ភ្ញៀវកូរ៉េចូលមកទស្សនាវត្តថ្មីជាក្រុមៗពី១៥នាក់ទៅ៣០នាក់ក្នុងមួយក្រុម និងប្រហែល៣០ក្រុមដោយឥតគិតថ្លៃ ។ អ្នកនាំភ្ញៀវប្រាប់ខ្ញុំថា នៅក្នុងកញ្ចប់ទេសចរណ៍របស់កូរ៉េគឺមាន



មគ្គុទេសក៍រៀបរាប់ពីពិព័រណ៍ខ្មែរក្រហមដែលដាក់តាំងបង្ហាញនៅ វត្តថ្មី ក្រុងសៀមរាប ប្រាប់ដល់ភ្ញៀវទេសចរ



ភ្ញៀវទេសចរណ៍ទស្សនាពិព័រណ៍ខ្មែរក្រហមនៅវត្តថ្មី ក្រុងសៀមរាប

បញ្ចូលកម្មវិធីមកទស្សនាវត្តថ្មី ។ ខ្ញុំសង្កេតឃើញថា គ្រប់ក្រុមភ្ញៀវកូរ៉េទាំងអស់តែងតែត្រូវបានអ្នកនាំភ្ញៀវជាជនជាតិកូរ៉េដូចគ្នានាំទៅមើលផ្ទាំងពិព័រណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងពណ៌នាយ៉ាងច្រើនពីកម្ពុជា និងខ្មែរក្រហម ។ ខ្ញុំអាចកាត់ន័យបានគឺតាមរយៈការឮសូរពាក្យ "ខាំបូឌៀ ខ្មែរ នួន ជា អៀង សារី" ។

ខ្ញុំកើតជាចម្ងល់មួយដែលចង់ដឹងថា ហេតុដូចម្តេចបានជាជនជាតិកូរ៉េចាប់អារម្មណ៍នឹងប្រវត្តិសាស្ត្របែបនេះ? ខ្ញុំរកមើលអ្នកនាំភ្ញៀវជាជនជាតិខ្មែរណាម្នាក់ដែលអាចនិយាយភាសាកូរ៉េបាន ដើម្បីជួយបកប្រែឲ្យខ្ញុំ នៅពេលដែលខ្ញុំសួរភ្ញៀវកូរ៉េ ។ ស្ត្រីភ្ញៀវកូរ៉េម្នាក់ អាយុ៥៩ឆ្នាំ ឈ្មោះ Son Hye Reun បានយល់ព្រមនិយាយជាមួយខ្ញុំនៅកណ្តាលថ្ងៃត្រង់ បន្ទាប់ពីបានទស្សនាពិព័រណ៍រួច ។ គាត់ចាប់អារម្មណ៍នឹងប្រវត្តិសាស្ត្រខ្មែរក្រហមគឺដោយសារ "វាជាប្រវត្តិសាស្ត្រដែលមានភាពស្រដៀងគ្នានឹងប្រវត្តិសាស្ត្រកូរ៉េដែរ គឺនៅត្រង់ថា ប្រវត្តិសាស្ត្រពោរពេញដោយការឈឺចាប់ ការសម្លាប់ និងការបែកបាក់គ្រួសារ" ។ ស្ត្រីរូបនេះនិយាយទៀតថា "ដូចប្រទេសកូរ៉េដែរ គឺនៅពេលមានបញ្ហារត់ទៅរកអាមេរិកឲ្យជួយ" ។

គាត់និយាយសំដៅដល់របបសាធារណរដ្ឋខ្មែររបស់អតីតសេនាប្រមុខ លន់ នល់ នៅពេលដែលតស៊ូជាមួយខ្មែរក្រហមគឺរត់ទៅរកអាមេរិកឲ្យជួយ ។ ខ្ញុំសួរគាត់បន្ថែមថា តើគាត់យល់យ៉ាងដូចម្តេចចំពោះបញ្ហាកម្ពុជា? គាត់ឆ្លើយថា "ខ្ញុំចង់ឃើញប្រជាជនកម្ពុជាខិតខំប្រឹងប្រែងដោយខ្លួនឯង ដើម្បីកសាងប្រទេសឲ្យបានជឿនលឿនគឺដូចកូរ៉េដែរ" ។

ខ្ញុំរិតតែចាប់អារម្មណ៍រឿងមួយទៀត គឺក្រុមគ្រួសារកូរ៉េប្តីប្រពន្ធ និងកូនប្រុសស្រី២នាក់អាយុក្រោម១០ឆ្នាំ ជិះរ៉ឺម៉កកង់បីចូលទស្សនាវត្តថ្មីដោយពុំមានអ្នកនាំភ្ញៀវ ។ ប្តីប្រពន្ធមួយគូនេះបាននាំកូនទៅមើលផ្ទាំងពិព័រណ៍រួចហើយបន្តទៅមើលស្តូបរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនៃសម័យខ្មែរក្រហម នៅក្បែរផ្ទាំងពិព័រណ៍ដែលផ្ទុកពេញទៅដោយលលាដ៍ក្បាលជនរងគ្រោះ ដែលធ្វើឲ្យខ្ញុំប្តូរពីការចាប់អារម្មណ៍មកជាការបារម្ភវិញ ។ ខ្ញុំដឹងតាមរយៈអ្នករត់រ៉ឺម៉កកង់បីថា ប្តីប្រពន្ធមួយគូនេះចេះនិយាយភាសាអង់គ្លេស ។ ខ្ញុំចាប់ផ្តើមដើរទៅរកគាត់ និងសុំការអនុញ្ញាតសួរនាំមួយ ឬពីរសំណួរ ។ បុរសជាប្តីឈ្មោះ Seung Wook Kang និយាយប្រាប់ខ្ញុំថា គាត់នាំប្រពន្ធ និងកូនមកមើលបែបនេះគឺដោយសារគាត់បានមើលខ្សែភាពយន្តដែលមានចំណងជើងថា "វាលពិឃាដ" កាលនៅប្រទេសរបស់គាត់ ហើយកូនរបស់គាត់អត់ជឿរឿងហ្នឹង ។ គាត់ចង់ឲ្យកូនរបស់គាត់យល់ដឹងពីអ្វីដែលបានកើតឡើងនៅក្នុងស្រុកខ្មែរ ។ គាត់ចង់ឲ្យកូនរបស់គាត់មានអារម្មណ៍ចេះអាណិតអាសូរចំពោះរឿងរ៉ាវដែលកើតឡើងបែបនេះ ។

ជាចុងក្រោយ ខ្ញុំក្រឡេកឃើញកូនសិស្សនិយាយគ្នាសើចនៅជាប់នឹងកន្លែងលក់កាហ្វេក្នុងបរិវេណវត្តថ្មី ។ តាមពិតទៅ កូនសិស្សនេះមកលក់កាហ្វេជារៀងរាល់ថ្ងៃឲ្យក្រុមហ៊ុន SOWAT ។ ខ្ញុំចង់ដឹងថា តើកូនសិស្សដែលឃើញទិដ្ឋភាពភ្ញៀវទេសចរបែបនេះយល់ឃើញយ៉ាងដូចម្តេច? សិស្សឈ្មោះ កន សុភា អាយុ២០ឆ្នាំ រៀនថ្នាក់ទី១២ យល់ឃើញទាក់ទិននឹងការផ្សព្វផ្សាយដោយនិយាយថា "ពេលគេត្រឡប់ទៅវិញ គេនឹងជួយផ្សព្វផ្សាយឲ្យបានទូលំទូលាយ គឺផ្សព្វផ្សាយដើម្បីឲ្យពិភពលោកស្គាល់ប្រទេសកម្ពុជាឲ្យបានច្រើន" ។

**ឆាន់ថាន់ ពៅដារ៉ា**

# ការប៉ះទង្គិចរវាងយោធាខ្មែរក្រហម និងកងទ័ពវៀតណាមនៅបណ្តោយព្រំដែនខេត្តរតនគិរី

បើតាមការលើកឡើងរបស់ ម៉ៅ ផេន អតីតយោធាខ្មែរក្រហមប្រចាំការនៅព្រំដែនខេត្តរតនគិរី ជម្លោះប្រដាប់អាវុធរវាងកងទ័ពបដិវត្តន៍កម្ពុជា និងកងទ័ពវៀតណាមនៅតាមបណ្តោយព្រំដែនក្នុងខេត្តរតនគិរី គឺកើតឡើងតាំងពីខែមករា ឆ្នាំ១៩៧៦ ហើយបានបន្តពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងឆ្នាំ ១៩៧៦ ការប្រយុទ្ធគ្នានៅមានទ្រង់ទ្រាយតូចនៅឡើយ ។ ភាគីទាំងពីរនៅអនុវត្តសង្គ្រាមឈ្លប ដោយលួចស្ទាក់បាញ់គ្នា និងលបលួចយកការណ៍គ្នាទៅវិញទៅមក ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៧ រហូតដល់ដើមខែមករា ឆ្នាំ១៩៧៩ ស្ថានការណ៍សម្រាប់កងទ័ពបដិវត្តន៍កម្ពុជាមានភាពអាក្រក់ខ្លាំង បន្ទាប់ពីកងទ័ពវៀតណាមវាយលុលចូលមកក្នុងទឹកដីខេត្តរតនគិរីកាន់តែជ្រៅ ។ តាមការបញ្ជាក់របស់ ម៉ៅ ផេន នៅឆ្នាំ១៩៧៧ កងទ័ពវៀតណាមវាយចូលមកដល់ភូមិទេន (ជិតបរកែវ) ស្ថិតនៅចម្ងាយជាង ៣០គីឡូម៉ែត្រ ពីព្រំដែន ។ បន្ទាប់ពីនោះមកកងពល៨០១ របស់កងទ័ពបដិវត្តន៍កម្ពុជាបានចំណាយពេល២ឆ្នាំពេញក្នុងការវាយទប់ និងរុញច្រានទាហានវៀតណាមឲ្យត្រឡប់ទៅវិញ ។ ប៉ុន្តែពុំទទួលបានជោគជ័យ ហើយត្រូវដកទ័ពថយរត់ចូលព្រៃលាក់ខ្លួនបន្ទាប់ពីទទួលដំណឹងថា កងទ័ពវៀតណាមវាយចូលកាន់កាប់ដល់ទីក្រុងភ្នំពេញ ។

ម៉ៅ ផេន កើតនៅភូមិបឹងទ្រា ឃុំទួលព្រិច ស្រុកអង្គស្នួល ខេត្តកណ្តាល ។ នៅឆ្នាំ១៩៧៤ ផេន ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅនៅខេត្តកំពង់ស្ពឺ បន្ទាប់មកចាប់ឲ្យធ្វើជាយោធាខ្មែរក្រហម ។ គាត់ត្រូវខ្មែរក្រហមបញ្ចូលទៅក្នុងកងទ័ពតំបន់ ហើយបានចូលរួម



កងកាំភ្លើងធំរបស់ខ្មែរក្រហមនៅសមរភូមិខេត្តស្វាយរៀង បាញ់ផ្ទៀងដាក់កងទ័ពវៀតណាម



យុទ្ធជន-យុទ្ធនារីកងចល័តប្រមូល ទុកដាក់ផលស្រូវ ដែលសេសសល់ពីការវាយប្រយុទ្ធរវាងយោធាខ្មែរក្រហម និងកងទ័ពវៀតណាម

ប្រយុទ្ធយ៉ាងសកម្មប្រឆាំងនឹងទាហាន លន់ នល់ ដែលឈរជើងនៅខត្តុង និងភ្នំបាសិត ។ បន្ទាប់ពីវាយឈ្នះទាហាន លន់ នល់ នៅខត្តុង ផេន ត្រូវបានចាត់ឲ្យដឹកជញ្ជូនគ្រាប់ពីភ្នំបាសិត ដែលជាកន្លែងឃ្លាំងគ្រាប់របស់ទាហាន លន់ នល់ យកទៅទុកនៅតំបន់រំដោះក្នុងខេត្តកំពង់ស្ពឺ ។ ផេន មានតួនាទីជាអ្នកដឹកជញ្ជូនគ្រាប់រហូតដល់ខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥ ។ ក្រោយបែកទីក្រុងភ្នំពេញ ផេន ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើស្រែនៅម្តុំអន្លង់ក្ងាន និងខត្តុង ។ ធ្វើស្រែបានមួយរយៈ អង្គការបញ្ជូន ផេន មកទីក្រុងភ្នំពេញវិញ ដើម្បីទទួលការបណ្តុះបណ្តាលបន្ថែមមុននឹងបញ្ជូនឲ្យទៅរស់នៅខេត្តរតនគិរី ។ វគ្គបណ្តុះបណ្តាលត្រូវបានធ្វើនៅក្នុងរោងកុនចេនឡា ក្បែរផ្សារដើមគរ ។ អ្នកចូលរួមពេលនោះត្រូវបានអប់រំថា មានភារកិច្ចការពារព្រំដែន និងកសាងភូមិករណ៍នៅខេត្តរតនគិរី ហើយទទួលការលើកទឹកចិត្តឲ្យយកប្រពន្ធនៅទីនោះ ។

ម៉ៅ ផេន បញ្ជាក់ថា ក្រោយពីមានវគ្គបណ្តុះបណ្តាលនេះ ក៏ចាប់ផ្តើមមានការកែសម្រួល និងរៀបចំកងទ័ពថ្មី ។ អតីតកងពល ១៨ ដែលគាត់ធ្លាប់នៅពីមុន ត្រូវបានរំលាយចោល ហើយកងពល ៨០១ ដែលត្រូវទៅការពារព្រំដែនខេត្តរតនគិរីត្រូវបានបង្កើតឡើង ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ម៉ៅ ផេន ដែលនៅក្នុងកងពល ៨០១ ដែរនោះត្រូវអង្គការបញ្ជូនទៅខេត្តរតនគិរី ហើយរហូតដល់ខែធ្នូ ទើបទៅដល់កន្លែងដែលត្រូវបោះទីតាំង គឺនៅជិតមាត់ទន្លេសេសាន ក្នុងស្រុកវឺនសៃ ។ នៅខែមករា ឆ្នាំ១៩៧៦ ម៉ៅ ផេន និងកម្លាំងពិសេស២ ២៩នាក់ទៀត (ជម្រើសមកពីគ្រប់អង្គភាពចំណុះឲ្យកងពល៨០១) ក្រោមការដឹកនាំរបស់ឈ្មោះ ណាក់ ត្រូវបានចាត់តាំងឲ្យទៅឈរជើងនៅជាប់ខ្សែបន្ទាត់ព្រំដែន ។ កងទ័ពខ្មែរក្រហមឈរជើងនៅក្នុងភូមិសោប ចំណែកកងទ័ពវៀតណាមឈរជើងនៅភូមិទទឹន ។

ម៉ៅ ផេន បញ្ជាក់ថា នៅពេលទៅដល់ភ្លាម ភាគីទាំងពីរបានជួបចាប់ដៃគ្នានៅចំណុច អូរតាយ៉ាក ដែលជាច្រកចេញចូលរវាងប្រទេសទាំងពីរ ហើយបាននិយាយគ្នាថា “កម្ពុជា-វៀតណាមសាមគ្គីគ្នា” ។ បន្ថែមលើនេះភាគីទាំងពីរសច្ចានឹងគ្នាថា “ថ្ងៃក្រោយមកចាប់ដៃគ្នាកន្លែងនេះទៀត” ។ កន្លះខែក្រោយមក ម៉ៅ ផេន នាំគ្នាមកកន្លែងនេះម្តងទៀត ។ ប៉ុន្តែត្រូវទាហានវៀតណាមដែលនៅចាំទីនោះមុនជាស្រេច ធ្វើការបាញ់រះមកលើកងកម្លាំងរបស់គាត់ស្លាប់ពីរនាក់ ។ ម៉ៅ ផេន ពុំដឹងថាហេតុអ្វីបានជាទាហានវៀតណាម

ទាំងនោះធ្វើការវាយប្រហារមកលើកម្លាំងរបស់គាត់ឡើយ ។ តាំងពីពេលនោះមក ភាគីទាំងពីរចាប់ផ្តើមធ្វើការប្រយុទ្ធគ្នាជាបន្តបន្ទាប់ តាមរយៈការពួនស្ទាក់បាញ់ និងផ្លោងដាក់គ្នាទៅវិញទៅមក ។ ម៉ៅ ដេន បញ្ជាក់ថាកងកម្លាំងរបស់គាត់ត្រូវធ្វើការចល័តទីតាំងឈរជើងរហូត ពីព្រោះតិញវៀតណាមតែងតែមកលបយកការណ៍ ឬវាយរកទីតាំងឈរជើងរបស់ពួកគាត់ជាប្រចាំ ។

នៅឆ្នាំ១៩៧៧ កងទ័ពវៀតណាមបានវាយរុលចូលមកដល់ភូមិទេន (ក្បែរបរកែវ) ស្ថិតនៅចម្ងាយប្រមាណ៣៥គីឡូម៉ែតពីព្រំដែនអូរយ៉ាដាវ ។ ដូច្នេះកម្លាំងរបស់ ម៉ៅ ដេន ចំនួន ៥នាក់ និងកម្លាំងនៅតាមកងផ្សេងៗប្រមាណ ២០០នាក់ទៀតត្រូវបានដកជាបន្ទាន់ដើម្បីឲ្យមកជួយវាយទប់ និងបណ្តេញកងទ័ពវៀតណាមចេញទៅវិញ ។ កងទ័ពខ្មែរក្រហមមួយកងវរសេនាធំដែលឈរជើងនៅអូរយ៉ាដាវ ក៏ត្រូវបានដកឲ្យមកជួយវាយទប់ដែរ ។ កងទ័ពខ្មែរក្រហមចាប់ផ្តើមវាយទប់កងទ័ពវៀតណាមទាំងនោះនៅភូមិទេន ហើយបានរុញច្រានមកដល់ព្រៃអូរតាង ។ ម៉ៅ ដេន បញ្ជាក់ថា កងទ័ពវៀតណាមនៅពាសពេញព្រៃអូរតាង ហើយបន្ទាយទ័ពវៀតណាមជាច្រើនត្រូវបានសង់នៅទីនោះ ។ កងទ័ពខ្មែរក្រហមបន្តវាយរុញច្រានបន្តិចម្តងៗពីព្រៃអូរតាងរហូតជិតទៅដល់ព្រំដែនអូរយ៉ាដាវ ។ ប៉ុន្តែកងទ័ពខ្មែរក្រហមត្រូវបានបញ្ជាឲ្យដកទ័ពថយមកវិញ បន្ទាប់ពីទទួលដំណឹងថាកងទ័ពវៀតណាមវាយចូលកាន់កាប់ទីក្រុងភ្នំពេញ ។ តាមការបញ្ជាក់របស់ ម៉ៅ ដេន កងទ័ពខ្មែរក្រហមបានចំណាយពេល២ឆ្នាំក្នុងការវាយរុញច្រានកងទ័ពវៀតណាមពីភូមិទេនរហូតជិតទៅដល់ព្រំដែនអូរយ៉ាដាវ ។

## ការរត់ភៀសខ្លួនក្រោយចាញ់វៀតណាមឆ្នាំ១៩៧៩

បន្ទាប់ពីទទួលដំណឹងថាកងទ័ពវៀតណាមចូលកាន់កាប់ទីក្រុងភ្នំពេញ និងតំបន់ផ្សេងៗទៀតក្នុងប្រទេសកម្ពុជា កងទ័ពមួយចំនួនធំក្នុងកងពល៨០១ បាននាំគ្នារត់ចូលព្រៃដើម្បីសម្ងំលាក់ខ្លួន ។ ម៉ៅ ដេន រួមជាមួយទាហាន និងប្រជាជន (ភាគច្រើនជាជនជាតិភាគតិច) រាប់ម៉ឺននាក់ផ្សេងទៀត នាំគ្នារត់ចូលព្រៃ អូរតក់ម៉ក់ ក្នុងខេត្តរតនគិរី ។ គាត់បញ្ជាក់ថា នៅពេលនោះលែងមានការចាត់តាំងត្រឹមត្រូវទៀតហើយ ។ ម្នាក់ៗប្រឹងរស់ និងដោះស្រាយជីវភាពរៀងៗខ្លួន ។ អ្នកទាំងនោះត្រូវស្វែងរកចេក ដំឡូងព្រៃ ឬក្តួច មកធ្វើជាអាហារ ។ ពេលខ្លះត្រូវប្រឈមមុខ ឬគេចខ្លួនពីការតាមស្វែងរករបស់កងទ័ពវៀតណាម ។

នៅឆ្នាំ១៩៨១ ប្រជាជន និងយោធាខ្មែរក្រហមទាំងនោះនាំគ្នាផ្លាស់មកនៅជិតទន្លេមេគង្គក្បែរព្រំដែនឡាវ ក្នុងគោលបំណងស៊ើបរកកម្លាំងខ្មែរក្រហមដទៃទៀតដែលនៅតស៊ូតាមព្រំដែនថៃ ។ ស្នាក់នៅបានមួយរយៈ អ្នកទាំងនោះសម្រេចឆ្លងទន្លេមេគង្គ មករស់នៅម្តុំមុំបី បន្ទាប់ពីស៊ើបដឹងថាមានកម្លាំងតស៊ូនៅទីនោះ ។ ទាក់ទងនឹងការឆ្លងទន្លេមេគង្គ ម៉ៅ ដេន បញ្ជាក់ថា ទឹកទន្លេមេគង្គនៅក្នុងទឹកដីខ្មែរហូរខ្លាំង មិនអាចឆ្លងបានឡើយ ដូច្នេះត្រូវលួចឆ្លងតាមប្រទេសឡាវ ។ ប៉ុន្តែត្រូវប្រឈមមុខនឹងកងទ័ពវៀតណាមដែលកំពុងឈរជើងនៅក្នុងទឹកដីឡាវ ។ ជាផលសំណាង យោធាខ្មែរក្រហម និងប្រជាជនទាំងនោះត្រូវបានឡាវស (កម្លាំងតស៊ូប្រឆាំងនឹងវៀតណាមនៅក្នុងទឹកដីឡាវ) ជួយនាំផ្លូវរហូតឆ្លងទន្លេមេគង្គបានសម្រេច ។ ម៉ៅ ដេន បានរៀបរាប់ថា «ពួកខ្ញុំប្រុងឆ្លង យួនវាល្បាតទៅឃើញផ្លូវពួកខ្ញុំចូលមកស្រុកឡាវ ។ ចូលស្រុកឡាវក៏យួនវាកាត់មកត្រៀមចាំតាមព្រៃកាត់ពួកខ្ញុំចូលមកស្រុកឡាវ ។ យួនត្រៀមតាមមាត់ទន្លេ» ។

ដល់ចឹងអា ឡាវស នេះវាថា ន៎ែ! អត់ឲ្យយួនតាមដានពួកខ្ញុំមកទេ វាអ្នកតាម ។ តែឡាវនោះ ការពិតឡាវតស៊ូទេ ។ វាតាមមកបានមកជួបពួកខ្ញុំ ។ ជួបពួកខ្ញុំទៅក៏! អត់បានបាញ់គ្នាទេ ប្រុងតែបាញ់គ្នាដែរ ដឹងវាលើកដៃទៅក៏ទាក់ទងទៅបានដឹងថាខ្សែរយៈឡាវតស៊ូដែរ ។ ដឹងចឹងវានាំផ្លូវ ។ ឡាវនឹងនាំផ្លូវមក វាអត់នាំកាត់ព្រៃទេ វានាំដើរតាមផ្លូវរហូត ព្រោះតាមព្រៃយួនត្រៀមអស់ ។ ដើរតាមផ្លូវរហូតជិតដល់បន្ទាយយួន ។ បានមកតាមមាត់ទន្លេ វាយតាមមាត់ទន្លេ! អាឡាវស នឹងវាយាមនៅមាត់ច្រកចេញចូល បន្ទាយវានឹងទៅយាមចាំនៅនឹងឯង ។ ចាំពួកខ្ញុំឆ្លងអស់ បានវាចូលបន្ទាយវា» ។

ដេន បានមកដល់មុំបី នៅដើមខែមករា ឆ្នាំ១៩៨២ ហើយត្រូវបានខ្មែរក្រហមបញ្ចូលក្នុងកងវរសេនាតូចលេខ៣១ កងពល៨០១ ។ បន្ទាប់មកត្រូវខ្មែរក្រហមបញ្ជូនមកជំរំ១០០៣ របស់តាម៉ុក ទទួលមុខសញ្ញាធ្វើសកម្មភាពនៅខាងកើតខេត្តសៀមរាប ។ នៅឆ្នាំ១៩៨៥ ដេន សម្រេចផ្តាច់ខ្លួន ហើយចូលសាវភាពជាមួយរដ្ឋាភិបាលកម្ពុជានៅខេត្តសៀមរាប ។ **ចាន ប្រាថ្នា**

# ការយល់ដឹងរបស់សិស្សពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតាមរយៈវេទិកាអប់រំសាធារណៈ

ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥-៧៩ ឬរបបខ្មែរក្រហម ត្រូវបានដាក់ឲ្យសិស្សរៀនភ្លាមៗ ក្រោយពីរបបនេះត្រូវបានវាយផ្តួលរំលំនៅឆ្នាំ១៩៧៩ ។ ប៉ុន្តែកម្មវិធីសិក្សានេះមិនមានលក្ខណៈទូលំទូលាយនោះទេ ព្រោះការសិក្សាភាគច្រើនគឺផ្តោតសំខាន់តែទៅលើការឃោសនា ផ្នែកនយោបាយប៉ុណ្ណោះ ។ នៅអំឡុងចុងទសវត្សរ៍ឆ្នាំ១៩៨០ ប្រវត្តិសាស្ត្រនេះ ត្រូវបានដកចេញពីកម្មវិធីសិក្សារបស់រដ្ឋវិញ ដោយសារតែពេលនោះ ប្រទេសកម្ពុជាកំពុងឈានទៅរកដំណោះស្រាយផ្នែកនយោបាយ (បញ្ចប់ជម្លោះ) ក្នុងចំណោមភាគីដែលពាក់ព័ន្ធ រួមទាំងក្រុមខ្មែរក្រហមដែលត្រូវបានដឹងឮជាទូទៅថា បានសម្លាប់ប្រជាជនស្លូតត្រង់ប្រមាណជិតពីរលាននាក់ ។

រយៈពេលប្រមាណជាងពីរទសវត្សរ៍ក្រោយមក គឺនៅឆ្នាំ២០១១ ទើបក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាធិបតេយ្យ (១៩៧៥-៧៩) ជាផ្លូវការឡើងវិញសម្រាប់សិស្ស និងនិស្សិត នៅតាមសាលាចំណេះទូទៅនានាទូទាំងប្រទេសកម្ពុជា ។

នៅខែមករា ឆ្នាំ២០១៦ នេះ ដោយមានការសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលធ្វើការងារផ្តោតសំខាន់ទៅលើការចងក្រង ប្រមែប្រមូល និងផ្សព្វផ្សាយពីប្រវត្តិសាស្ត្រខ្មែរក្រហម បានរៀបចំវេទិកាអប់រំស្តីអំពី «សារសំខាន់នៃការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)» រយៈពេលមួយថ្ងៃ ទៅដល់សិស្សា



សិស្សថ្នាក់ទី១២ នៅវិទ្យាល័យ ជា ស៊ីម បឹងកេងកង ចូលរួមវេទិកាអប់រំសាធារណៈស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ពីឆ្នាំ១៩៧៥-៧៩



សិស្សឆ្លើយសំណួរសាកល្បងទាក់ទងនឹងការយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម មុនពេលកម្មវិធីបង្រៀនចាប់ផ្តើម

នុសិស្សថ្នាក់ទី១២ ប្រមាណជាង១០០នាក់ នៅវិទ្យាល័យជា ស៊ីម បឹងកេងកង ។ វិទ្យាល័យនេះ ត្រូវបានកសាងឡើងនៅក្នុងសម័យសង្គមរាស្ត្រនិយម ហើយត្រូវបានបោះបង់ចោល និងលែងបានបំពេញតួនាទីរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រោយឆ្នាំ១៩៧៩ ទើបរដ្ឋជ្រើសរើសវិទ្យាល័យនេះធ្វើជាកន្លែងបណ្តុះបណ្តាលភាសាបរទេស សម្រាប់សិស្សដែលត្រៀមចេញទៅសិក្សានៅបរទេស ប៉ុន្តែមិនទាន់បានបំពេញតួនាទីជាសាលាពេញលេញនោះទេ ។ រហូតមកដល់ឆ្នាំ១៩៩២ ទើបក្រសួងអប់រំ អនុញ្ញាតជាផ្លូវការឲ្យសិស្សនៅសាលាចំណោះទូទៅចូលរៀនសាជាថ្មីឡើងវិញ ។

វេទិកានេះ នឹងជួយបំពេញបន្ថែមលើចំណេះដឹងរបស់សិស្ស និងកម្មវិធីសិក្សារបស់ក្រសួង ដែលមានស្រាប់ស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍ ។ វេទិកានេះក៏នឹងផ្តល់ឲ្យសិស្សក្នុងការបញ្ចេញមតិរបស់ខ្លួនចំពោះរឿងរ៉ាវដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ការគិតឲ្យបានស៊ីជម្រៅពីផលប៉ះពាល់នៃប្រវត្តិសាស្ត្រនេះមកលើសង្គមនាពេលបច្ចុប្បន្ន និងលើកទឹកចិត្តឲ្យសិស្សពិភាក្សាពីប្រវត្តិសាស្ត្រនេះនៅក្នុងគ្រួសារ និងសហគមន៍ ។

បើតាមលោក ផេង ពង្សរ៉ាស៊ី អ្នកសម្របសម្រួល និងរៀបចំវេទិកាស្តីពី "សារសំខាន់នៃការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)" នៃវិទ្យាស្ថានស្លឹករឹត មជ្ឈមណ្ឌលឯកសារកម្ពុជាបានឲ្យដឹងថា កម្មវិធីអប់រំនេះនឹងផ្តល់ឲ្យសិស្សសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ឲ្យបានទូលំទូលាយ និងជំរុញឲ្យសិស្សនិយាយចេញមកនូវរឿងរ៉ាវដែលខ្លួនបានដឹងតាមរយៈ ឯកសារ សាច់ញាតិ បងប្អូន ឬឪពុកម្តាយ ជាជាងសិក្សាតែតាមរយៈកម្មវិធីរបស់សាលា ឬក្រសួង ដែលដាក់មក ។

បើតាមលោក ង៉ូវ ឈុនហាក់ នាយកវិទ្យាល័យ ជា ស៊ីម បឹងកេងកង ដែលបានសហការរៀបចំឲ្យមានវេទិកានេះឡើង បានមានប្រសាសន៍ថា សិស្សតិចណាស់ដែលបានដឹងពីរបបខ្មែរក្រហម និងរឿងរ៉ាវឪពុកម្តាយរបស់គេ ។ ដូច្នេះ ការរៀបចំឲ្យមានវេទិកានេះឡើង គឺដើម្បីឲ្យសិស្សចេះឆ្ងល់ ចេះស្រាវជ្រាវបន្ថែមទៀត ហើយក៏ជាមុខវិជ្ជាដែលមាននៅក្នុងវិញ្ញាសារប្រលងសម្រាប់សិស្សមធ្យមសិក្សាចំណេះទូទៅ ។

គីម ស្រីណែត សិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ជា ស៊ីម បឹងកេងកង បាននិយាយថា "វេទិកានេះអាចជួយខ្ញុំយល់ដឹងកាន់តែច្រើនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយក៏បានផ្តល់ឲ្យសិស្សបញ្ចេញគំនិត បកស្រាយ និងសាកសួរគ្នាទៅវិញទៅមក ។ វេទិកានេះ ក៏ធ្វើឲ្យខ្ញុំយល់ដឹង កាន់តែច្បាស់ពីរបបមួយដែលខ្ញុំមានមន្ទិលសង្ស័យពីមុនមក" ។

ឌិប ចាន់សុភក្រ្ត សិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ជា ស៊ីម បឹងកេងកង បានឲ្យដឹងថា "វេទិកានេះជួយឲ្យខ្ញុំយល់ដឹងបន្ថែមទៅលើការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូនៅក្នុងថ្នាក់ ហើយអាចឲ្យខ្ញុំយកការចងចាំទាំងនេះទៅប្រាប់ក្មេងៗដទៃទៀត ។

ឈុន ស៊ីផៃ សិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ជា ស៊ីម បឹងកេងកង បានរៀបរាប់ថា "វេទិកានេះអាចឲ្យខ្ញុំដឹងពីប្រវត្តិសាស្ត្រខ្មែរ និងរបបកម្ពុជាប្រជាធិបតេយ្យដែលខ្ញុំមិនដែលស្គាល់ពីមុនមក ។ វេទិកាអប់រំអំពីរបបកម្ពុជាប្រជាធិបតេយ្យនេះ ក៏បានផ្តល់នូវបទពិសោធន៍ និងចំណេះដឹងដល់ខ្ញុំដែរ" ។

វេទិកាអប់រំស្តីអំពី "សារសំខាន់នៃការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)" មានប្រយោជន៍មិនត្រឹមតែផ្តល់ចំណេះដឹងដល់សិស្សប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ប្រទេសជាតិទាំងមូលដែលបានឆ្លងកាត់របបខ្មែរក្រហម ។ **សោម ប៊ុនថន**

# ប្រវត្តិសាស្ត្រខ្មែរក្រហម នៅតែសំខាន់សម្រាប់មនុស្សជំនាន់ក្រោយ

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជា និងប្រជាជនកម្ពុជា ត្រូវបានរំដោះចេញពីគុកឥតជញ្ជាំងរបស់ខ្មែរក្រហម ។ ប្រជាជនខ្មែរជាងពីរលាននាក់ត្រូវបានស្លាប់ដោយសារការអត់ឃ្លាន ការធ្វើការហួសកម្លាំង ជំងឺ និងការសម្លាប់ ។ ទោះបីជារបបនេះ ត្រូវបានដួលរលំ ប៉ុន្តែមិនត្រូវបានបញ្ចប់នៅឡើយទេ ។ ខ្មែរក្រហមនៅបន្តសកម្មភាពរបស់ខ្លួនតាមតំបន់ព្រំដែនកម្ពុជា-ថៃ និងមានមូលដ្ឋានរឹងមាំចុងក្រោយរបស់ខ្លួននៅអន្លង់វែង រហូតដល់ឆ្នាំ១៩៩៨ បន្ទាប់ពីការធ្វើសមាហរណកម្មចុងក្រោយ ចុះចូលជាមួយរដ្ឋាភិបាល ទើបប្រទេសមានសុខសន្តិភាពទូទាំងប្រទេស ។ សម្រាប់អ្នកដែលរួចរស់ជីវិតពីរបបខ្មែរក្រហម គឺចងចាំមិនភ្លេចទេ ចំពោះរឿងរ៉ាវទាំងឡាយ ដែលបានកើតឡើងចំពោះខ្លួន និងក្រុមគ្រួសារ ។ ម្នាក់ៗរស់នៅក្នុងសុបិន្តអាក្រក់ ហើយអ្នកខ្លះជាញឹកញយតែងតែសុបិន្តអាក្រក់ និងភ្ញាក់ដឹងខ្លួនទាំងកណ្តាលយប់ ដោយក្តីរន្ធត់ភ័យខ្លាច ។ ប៉ុន្តែសម្រាប់ក្មេងៗជំនាន់ក្រោយវិញ ការយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមានកម្រិតនៅឡើយ ។ អ្នកទាំងនោះបានដឹង និងឮពីរបបខ្មែរក្រហមតាមរយៈការប្រាប់ពីឪពុកម្តាយ ចាស់ទុំ ដែលធ្លាប់ឆ្លងកាត់ប៉ុណ្ណោះ តែមិនបានយល់ដឹងឲ្យស៊ីជម្រៅពីរបបនេះឡើយ ។ តាមរយៈការនិយាយប្រាប់ពីអ្នកដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម អ្នកខ្លះក៏ជឿថា មានរបបនេះមែន ហើយអ្នកខ្លះទៀត ក៏មិនសូវជឿថា មានរបបខ្មែរក្រហមទេ ហើយគិតថា វាគ្រាន់ជារឿងនិទានរបស់មនុស្សចាស់ក្នុងការអប់រំក្មេងៗប៉ុណ្ណោះ ។

“ខ្ញុំស្អប់ខ្មែរក្រហម ព្រោះអ្នកទាំងនោះជាមនុស្សគួរឲ្យស្អប់ខ្ពើមបំផុត ដោយសារតែពួកគេធ្វើបាបមនុស្សស្លូតត្រង់ ហើយក៏


សិស្សថ្នាក់ទី១២ វិទ្យាល័យ ជា ស៊ីម ប៊ឹងកេងកង រៀបរាប់ពីប្រវត្តិសាស្ត្រខ្មែរក្រហមប្រាប់ដល់សាស្ត្រាចារ្យ ដាត កុសល និងសិស្ស មកពីសាកលវិទ្យាល័យប្រ៊ូកលីន ក្រុងញូវយ៉ក សហរដ្ឋអាមេរិក

ចាត់ទុកកូនរបស់អតីតខ្មែរក្រហមទាំងនោះ ជាមនុស្សប្លែកពីអ្នកដទៃដែរ ព្រោះក្មេងនោះអាចមានចរិតមិនល្អដូចឪពុកម្តាយរបស់ខ្លួន» ។ «ខ្ញុំស្អប់ខ្មែរក្រហម ព្រោះខ្មែរក្រហមបានសម្លាប់ប្រជាជនស្លូតត្រង់ជាច្រើន ហើយខ្ញុំចាត់ទុកកូនរបស់អតីតខ្មែរក្រហមទាំងនោះជាក្មេងខុសពីអ្នកដទៃ ព្រោះខ្ញុំយល់ថា ឪពុកម្តាយរបស់គេយ៉ាងម៉េច កូនក៏អ៊ីចឹងដែរ» ។

នេះជាការលើកឡើងរបស់សិស្សានុសិស្សថ្នាក់ទី១២ នៃវិទ្យាល័យទួលស្វាយព្រៃ ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាធិបតេយ្យ នាខែមករា ឆ្នាំ២០១៦នេះ ក្រោមកិច្ចសហប្រតិបត្តិការរវាង វិទ្យាស្ថានស្លឹករឹតដែលជាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ និងក្រសួងអប់រំយុវជន និងកីឡា កន្លងមកនេះ ។ សិស្សានុសិស្សមួយចំនួនទៀត ក៏បានលើកឡើងស្រដៀងនឹងគ្នានេះដែរ ។ ពេលដែលសិស្សានុសិស្សទាំងនេះឮពាក្យថា «ខ្មែរក្រហម» គឺនឹកឃើញ និងសំដៅដល់បុគ្គលដែលកាចសាហាវ ព្រៃផ្សៃ សម្លាប់ជាតិសាសន៍ខ្លួនឯង ព្រោះអ្នកទាំងអស់គ្នាបានដឹង និងឮរឿងទុក្ខវេទនា ការបង្អត់អាហារ ការសម្លាប់ទាំងឡាយ ដែលចាស់ទុំ អ្នកធ្លាប់ឆ្លងកាត់របបនេះ និយាយប្រាប់ ហេតុនេះ អ្នកទាំងនោះតែងតែមានអារម្មណ៍មិនល្អ ពេលដែលដឹងថាបុគ្គលម្នាក់នោះ ជាអតីត ឬជាកូនរបស់ខ្មែរក្រហម ។ ដូច្នេះ វគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធបិតេយ្យ ពិតជាមានសារសំខាន់ណាស់សម្រាប់អ្នកជំនាន់ក្រោយ ព្រោះថា បើអ្នកទាំងអស់គ្នាមិនបានសិក្សាស្រាវជ្រាវឲ្យបានយល់ច្បាស់ពីប្រវត្តិសាស្ត្រដ៏ជូរចត់មួយនេះទេ នោះការរើសអើង ការគុំគួន ប្រាកដជានៅតែកើតមានឡើងមិនខាននៅក្នុងសង្គមរបស់យើង ជាពិសេសការផ្សះផ្សារវាងអតីតខ្មែរក្រហម និងជនរងគ្រោះក្នុងរបបនេះក៏មិនអាចទៅរួចដែរ ។

ផ្ទុយពីទស្សនៈអវិជ្ជមានដែលសិស្សានុសិស្សលើកឡើងក្នុងវគ្គបណ្តុះបណ្តាល យុវសិស្សម្នាក់ បានលើកឡើងថា «ខ្ញុំមិនរើសអើងចំពោះអតីតខ្មែរក្រហម ឬកូនរបស់ពួកគេឡើយ ព្រោះថារឿងទាំងអស់នេះវាកន្លងហួសអស់ហើយ បើយើងរើសអើងគឺជាការបំផ្លាញប្រទេសជាតិ ។ យើងគួរតែរួបរួមគ្នាអភិវឌ្ឍន៍ប្រទេសជាតិ» ។ សិស្សម្នាក់ទៀត ក៏បានលើកឡើងស្រដៀងគ្នាថា «ប្រសិនបើខ្ញុំស្គាល់ក្មេងម្នាក់ជាកូនរបស់អតីតកម្មាភិបាលខ្មែរក្រហម ខ្ញុំចាត់ទុកក្មេងម្នាក់នោះដូចក្មេងដទៃដែរ ព្រោះក្មេងម្នាក់នោះមិនបានដឹងរឿងអ្វី ហើយក៏មិនបានធ្វើអ្វីខុស ដូចឪពុកម្តាយខ្លួនបានធ្វើឡើយ» ។ ទាំងអស់នេះ គឺជាការយល់ឃើញរបស់សិស្សានុសិស្សអំពីខ្មែរក្រហម និងយកមកចែករំលែកគំនិតយោបល់គ្នា នៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ ។

សំណួរចម្លើយ កិច្ចពិភាក្សាជាច្រើន បានធ្វើឡើង ក្នុងអំឡុងវគ្គបណ្តុះបណ្តាល ដោយមានលោក ដេង ពង្សរ៉ាស៊ី ប្រធានគម្រោងអប់រំអំពីអំពើប្រល័យពូជសាសន៍ នៃវិទ្យាស្ថានស្លឹករឹត ជាអ្នកធ្វើបទបង្ហាញអំពីប្រវត្តិសាវតាររបស់ខ្មែរក្រហម ចាប់តាំងពីថ្ងៃកកើតនៃចលនាតស៊ូ រហូតដល់ថ្ងៃដួលរលំនៃរបបខ្មែរក្រហម ។

ដោយសារការផ្សព្វផ្សាយ និងអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមមានសារសំខាន់សម្រាប់អ្នកជំនាន់ក្រោយ ទើបនៅឆ្នាំ២០១១ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចដាក់បញ្ចូលមេរៀន ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមក្នុងកម្មវិធីសិក្សាសម្រាប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ។ ក្នុងនោះដែរ វិទ្យាស្ថានស្លឹករឹត ដែលជាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ ក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ អំពីវិធីសាស្ត្រក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទូទាំងប្រទេស ។ ជាមួយគ្នានេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានធ្វើការផ្សព្វផ្សាយអប់រំអំពីរបបខ្មែរក្រហម ដើម្បីជំរុញឲ្យមានការចងចាំ និងយុត្តិធម៌ តាមរយៈការធ្វើវេទិកាសាធារណៈតាមភូមិ សកលវិទ្យាល័យ និងវិទ្យាល័យទូទាំងប្រទេស ។

ចាប់ពីខែមករា ឆ្នាំ២០១៦ វិទ្យាស្ថានស្លឹករឹត ដែលជាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំវគ្គបណ្តុះបណ្តាលអំពីប្រវត្តិសាស្ត្រប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យចំនួន១៥ ក្នុងរាជធានីភ្នំពេញ ។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តឡើងក្នុងគោលបំណងឲ្យសិស្សានុសិស្ស សិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ការគិតពិចារណាឲ្យបានស៊ីជម្រៅ ពិភាក្សា និងការឆ្លុះបញ្ចាំងពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

**ទាវ សារៈមុនិន្ទ**

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

*(តពីលេខមុន)*

## *៤) ការអប់រំបែបសាសនា និង បែបវិទ្យាសាស្ត្រ*

*នៅពេលដែលការអប់រំមានសារសំខាន់សម្រាប់ប្រជាជាតិកម្ពុជាជាទូទៅ ការអប់រំគឺជាគន្លឹះសម្រាប់ការរស់ឡើងវិញនៃសាសនាអ៊ីស្លាម បង្កើនជីវភាពរស់នៅទូទៅរបស់សជនជាតិចាម និងពង្រឹងនូវអត្តសញ្ញាណត្រឹមត្រូវសម្រាប់ក្រុម ។ ភាគច្រើននៃគោលការណ៍អភិវឌ្ឍន៍វិស័យអប់រំរបស់ជនជាតិចាម ត្រូវបានចម្លងចេញពីប្រព័ន្ធអនុវត្តនៅប្រទេសម៉ាឡេស៊ី និងប្រទេសផ្សេងទៀតនៅតំបន់អាស៊ីអាគ្នេយ៍ ។ដូច្នេះ បរិបទសំខាន់មួយសម្រាប់ការយល់ដឹងអំពីសាលាអ៊ីស្លាមនៅកម្ពុជា គឺការវិវឌ្ឍន៍ និងប្រព័ន្ធអប់រំអ៊ីស្លាមរបស់ប្រទេសម៉ាឡេស៊ី ។*

*កាលពីសម័យមុនអាណានិគម ការណែនាំសាសនានៅក្នុងឧបទ្វីបម៉ាឡេ ត្រូវបានធ្វើឡើងនៅក្នុងសាលាគួរ៉ានដែលមានទីតាំងនៅក្នុងព្រះវិហារសាសនាអ៊ីស្លាម ផ្ទះថ្វាយបង្គំ និងផ្ទះរបស់អ្នកជំនាញសាសនា ។ សាលាក្រៅផ្លូវការទាំងនេះ បានផ្តល់ឲ្យនូវការអប់រំបែបសាសនាអ៊ីស្លាមថ្នាក់មូលដ្ឋានទៅឲ្យក្មេងៗ ជាពិសេសផ្នែកសូត្រ និងទន្ទេញរត់មាត់ ។ សាលាគួរអាន ត្រូវបានយកតម្រាប់តាមដោយសាលាប៉ុនដុក (Pondok School) ។ សាលានេះគឺហួសមួយកម្រិតពីការអប់រំបែបសាសនាអ៊ីស្លាម លើសពីការទន្ទេញគម្ពីរគួរ៉ាន ។ សាលានេះមានប្រជាប្រិយភាពរហូតដល់សង្គ្រាម លោកលើកទី១ ដែលក្រោយពីនោះមក សាលានេះបានចាប់ផ្តើមជួបឱនភាពដោយសារមូលហេតុមួយចំនួន ។ បន្ទាប់ពីសង្គ្រាមលោកលើកទី១*



*សាលាបឋមសិក្សាដែលបង្រៀនតាមបែបសាសនារបស់ជនជាតិចាម នៅខេត្តកំពត*

ការអប់រំបែបទំនើបដែលផ្តល់ជូនដោយចក្រភពអង់គ្លេស មានលក្ខណៈសមស្របជាងសម្រាប់ទីផ្សារការងារ នៅក្នុងរដ្ឋាភិបាលអាណានិគម និងការរីកចម្រើននូវចំណេះដឹងនៅក្នុងសម័យអាណានិគម ។ សិស្សក៏បានស្វះស្វែងរកការហ្វឹកហ្វឺនផ្សេងៗជាភាសាអង់គ្លេស ។ ការរួមចំណែកផ្សេងៗពីសហគមន៍សាសនាដើម្បីឧបត្ថម្ភសាលាប៉ុនដុក បានធ្លាក់ចុះ ។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩២០ សាលាប៉ុនដុកបានធ្លាក់ចុះខ្សោយបន្ថែមទៀត និងបានបើកផ្លូវឲ្យ ម៉ាដ្រាស់សារ ចូលមកប្រទេសម៉ាឡេស៊ីតាមរយៈអ្នកបញ្ចប់ការសិក្សាផ្នែកសាសនាអ៊ីស្លាមពីក្រុងម៉ាកាស ក្រុងមេឌីណា និងក្រុងកៃរ៉ូ ដែលទទួលបានការអប់រំពីគំនិតអ៊ីស្លាម"ទំនើប" និងប្រព័ន្ធអប់រំ ដែលមានបញ្ចូលចម្រុះនូវការអប់រំបែបសាសនាជាមួយនឹងមុខវិជ្ជាវិទ្យាសាស្ត្រនៅក្នុងសាលាតែមួយ ។ ម៉ាដ្រាស់សារ បានរីកចម្រើនយ៉ាងទៀងទាត់រហូតដល់ទសវត្សរ៍ឆ្នាំ១៩៥០ នៅពេលដែលការផ្តោតអារម្មណ៍ច្រើនជាងមុន ត្រូវបានដាក់ទៅលើការកសាងអត្តសញ្ញាណម៉ាឡេទំនើបនៅជិតចុងបញ្ចប់នៃរបបគ្រប់គ្រងអាណានិគម ។ ការធ្វើបែបនេះបានបង្វែរចំណាប់អារម្មណ៍ពីការពង្រឹងជាបន្តនូវស្ថាប័នអ៊ីស្លាម ។ ម៉ាដ្រាស់សារ បានចាប់ផ្តើមធ្លាក់ចុះ ។ នៅចុងទសវត្សរ៍១៩៦០ នៅពេលដែលស្ថាប័នអ៊ីស្លាមម៉ាឡេ បានបញ្ចូលគ្នាជាមួយស្ថាប័នជាតិ ម៉ាដ្រាស់សារបានចាប់ផ្តើមបញ្ចូលជាមួយប្រព័ន្ធសាលារៀនសាធារណៈ ដើម្បីផ្តល់ជូននូវការអប់រំទាំងខាងសាសនាអ៊ីស្លាម និងមុខវិជ្ជាវិទ្យាសាស្ត្រទំនើប ។ ប្រព័ន្ធសាលារៀនសាធារណៈ ក៏បានទាក់ទាញគ្រូបង្រៀនសាសនាអ៊ីស្លាមឲ្យចេញឆ្ងាយពី ម៉ាដ្រាស់សារ ដែលបាននាំទៅដល់ការធ្លាក់ចុះជាបន្តនូវ ម៉ាដ្រាស់សារ ។

អង្គការក្រៅរដ្ឋាភិបាលកម្ពុជាមួយចំនួន បានចម្លងយកប្រព័ន្ធអប់រំពីប្រទេសម៉ាឡេស៊ីសម្រាប់សាលាអ៊ីស្លាមរបស់ពួកគេ ដែលរួមមានទាំង មូលនិធិអភិវឌ្ឍន៍ខ្មែរអ៊ីស្លាម (CMDF) និងសមាគមនិស្សិតខ្មែរអ៊ីស្លាម (CAMSA) ។ ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសកម្ពុជាឃើញមានការរីកចម្រើននូវស្ថាប័នអប់រំឯកជន ចាប់ផ្តើមពីសាលាភាសាអង់គ្លេសឯកជន ទៅសាកលវិទ្យាល័យដែលមានផ្តល់ថ្នាក់សញ្ញាប័ត្រថ្នាក់ឧត្តមសិក្សា ។ ជាងនេះទៅទៀត រដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឲ្យមានការបង្កើតសាលារៀនកម្មវិធីអប់រំអ៊ីស្លាម និងកម្មវិធីអប់រំចម្រុះ ។ មជ្ឈមណ្ឌលអ៊ីស្លាមកម្ពុជា (Cambodian Islamic Center) បានផ្តល់ជូនទាំងការអប់រំសាធារណៈសម្រាប់សិស្សថ្នាក់វិទ្យាល័យ និងការហ្វឹកហ្វឺនផ្នែកសាសនា និងភាសាអារ៉ាប់ ។ សិស្សពីសាលានេះប្រលងថ្នាក់ជាតិដូចគ្នានឹងសិស្សពីសាលាសាធារណៈ មិនពាក់ព័ន្ធនឹងសាសនាអ៊ីស្លាមដែរ ។ អ្នកបញ្ចប់ការសិក្សាពីមជ្ឈមណ្ឌលអ៊ីស្លាមកម្ពុជា អាចចូលសកលវិទ្យាល័យដូចសិស្សដទៃទៀតដែរ ។ ប្រព័ន្ធនេះត្រូវបានគេមើលឃើញថា ជាប្រព័ន្ធស្របគ្នា ដែលរៀបចំសម្រាប់សិស្សចាមដែលត្រូវការវគ្គហ្វឹកហ្វឺនបែបវិទ្យាសាស្ត្រ ក៏ដូចជាបែបសាសនា ។ ប៉ុន្តែដោយសារកម្ពុជាជាប្រទេសកាន់ព្រះពុទ្ធសាសនា ហើយជនជាតិចាមជាជនជាតិភាគតិច យើងមិនរំពឹងថានឹងមានការបង្កើតសកលវិទ្យាល័យអ៊ីស្លាម ឬប្រព័ន្ធជាតិមួយដែលមានផ្តល់នូវសញ្ញាបត្រជាន់ខ្ពស់ខាងសាសនា អ៊ីស្លាមដូចនៅម៉ាឡេស៊ីទេ ។ សម្រាប់ការអប់រំបែបនេះ ជនជាតិចាម អាចរៀននៅសាកលវិទ្យាល័យ នៅអារ៉ាប់ ប៉ាគីស្ថាន និងម៉ាឡេស៊ី ។

នៅប្រទេសហ្វីលីពីន សាលាអ៊ីស្លាម ជាទូទៅ ត្រូវបានបែងចែកជាបីប្រភេទ និងមានប្រព័ន្ធចម្រុះពីរបីនៅចន្លោះនោះ ។ សាលាសហគមន៍ គឺជាសាលានៅតាមភូមិតូចៗ ដែលត្រូវបានបង្កើតឡើងដោយមេដឹកនាំសហគមន៍តាមមូលដ្ឋាន ។ ជាទូទៅ សាលានេះត្រូវបានបង្កើតឡើងដើម្បីបំពេញ បន្ថែមពីលើការអប់រំរបស់រដ្ឋសម្រាប់ឲ្យក្មេងៗ និងជាធម្មតា ត្រូវបានរៀបចំឡើងដើម្បីឲ្យស្របទៅតាមកម្មវិធីនៅក្នុងសាលារៀនរដ្ឋ ។ សាលាបែបនេះបើកនៅចុងសប្តាហ៍ និងមានចំនួនសិស្សតិចជាង១០០នាក់ ។ កម្រិតនៃការអប់រំបែបអ៊ីស្លាម គឺថ្នាក់មូលដ្ឋាន ។ ម៉ាដ្រាស់សារសហគមន៍ជាទូទៅ មានទីតាំងនៅក្នុងអគារទំនេរនៅក្នុងសហគមន៍ ដូចជា មជ្ឈមណ្ឌលសហគមន៍ ផ្ទះទំនេរធំៗ កន្លែងសម្រាប់ថ្វាយបង្គំនៅខាងក្រៅព្រះវិហារសាសនាអ៊ីស្លាម និង ព្រះវិហារសាសនាអ៊ីស្លាម ។ ក្រុមសាលាប្រភេទនេះ មានរួមបញ្ចូលទាំងសាលារៀនអ៊ីស្លាមធំៗ ដែលបង្កើតឡើងដោយអ្នកនយោបាយ មានអំណាច និងមានទ្រព្យស្តុកស្តម្ភនៅតាមស្រុក ។

ប្រភេទសាលាបន្ទាប់ទៀត នៅហ្វីលីពីន គឺសាលាអានគម្ពីរគួរ៉ាន ។ សាលានេះ ត្រូវបានរៀបចំសម្រាប់តែគោលបំណងបង្រៀនសិស្សឲ្យអាន និងទន្ទេញគម្ពីរគួរ៉ាន វិភាគអត្ថន័យយល់

អំពីអ្វីដែលបានសរសេរនៅក្នុងនោះ និងរៀនស៊ុនណា ចំណែកឯហាឌីត (*Hadith*) ត្រូវបានប្រគល់ទៅឲ្យសាលារៀនខ្ពស់ជាងនោះ ។ សាលាប្រភេទនេះ ផ្តល់ឲ្យនូវការអប់រំថ្នាក់មូលដ្ឋានទៅឲ្យអ្នកកាន់សាសនាអ៊ីស្លាមក្មេងៗ និងជាស្ថាប័នតាមប្រពៃណីនៅក្នុងចំណោមជនជាតិហ្វីលីពីនកាន់សាសនាអ៊ីស្លាម ។

ប្រភេទសាលាអ៊ីស្លាមចុងក្រោយនៅក្នុងចំណោមអ្នកកាន់សាសនាអ៊ីស្លាមនៅហ្វីលីពីន គឺបណ្ឌិតសភាអ៊ីស្លាមទូលំទូលាយ ដែលផ្តល់ការអប់រំអ៊ីស្លាមជាប្រព័ន្ធ និងទូលំទូលាយ ។ សិស្សអាចមានចំនួនដល់១ពាន់នាក់ ចូលរៀននៅក្នុងសាលាប្រភេទនេះ ដែលមានផ្តល់មុខវិជ្ជាតាំងពីការសិក្សាអំពីសាសនាអ៊ីស្លាម ទៅដល់មុខវិជ្ជាវិទ្យាសាស្ត្រ ជំនាញកុំព្យូទ័រ និងវគ្គហ្វឹកហ្វឺនភាសាអង់គ្លេស ។ សិស្សសាលានេះមកពីខេត្តផ្សេងៗ ជាជាងមកពីសហគមន៍ដដែល ដូចដែលមានឃើញនៅក្នុងសាលាសហគមន៍ម៉ាដ្រាស់សារ និងសាលារៀនអានគម្ពីរគួរ៉ាន ។

ការរៀបចំសាលាអ៊ីស្លាមនៅក្នុងចំណោមអ្នកកាន់សាសនាអ៊ីស្លាមនៅហ្វីលីពីន បានផ្តល់នូវគំនិតយ៉ាងគួរឲ្យចាប់អារម្មណ៍ នៅពេលពិនិត្យមើលអំពីការអភិវឌ្ឍន៍ការអប់រំអ៊ីស្លាមនៅកម្ពុជា ។ នៅទីនេះ យើងអាចមើលឃើញស្ថាប័នស្រដៀងគ្នានេះ ត្រូវបានបង្កើតឡើងនៅតាមថ្នាក់ភូមិ ឧទាហរណ៍ ការបង្រៀននៅផ្ទះទួន ប្សុរ៉ាវ (នៅតាមភូមិ) នៅថ្នាក់ស្រុក ឧទាហរណ៍ ម៉ាដ្រាស់សារ នៅកំពង់ឆ្នាំង ដែលមានអគារសាលាសម្រាប់គោលបំណងជាក់លាក់ និងនៅថ្នាក់ជាតិ ដូចជា មជ្ឈមណ្ឌអ៊ីស្លាមកម្ពុជា ដែលត្រូវបានរៀបចំជាថ្មី នៅក្នុងខេត្តកណ្តាល និងសាលារបស់អង្គការ ការរស់ឡើងវិញនៃសង្គមកេរដំណែលអ៊ីស្លាម (**Revival of Islamic Heritage Society**) នៅទីក្រុងភ្នំពេញ ដែលមានសិស្សជិតមួយពាន់នាក់ ។

មុនពេលពិនិត្យមើលប្រព័ន្ធសាលាអ៊ីស្លាមនៅកម្ពុជា វាមានសារសំខាន់ណាស់ដែលត្រូវក្រឡេកមើលទៅការអភិវឌ្ឍន៍នៃសាលាសាសនាដែលត្រូវបាននាំមកពីម៉ាឡេស៊ី ប្រទេសថៃភាគខាងត្បូង និងប្រទេសផ្សេងទៀត ។ ជាពិសេស លី មូសា គឺជាឧទាហរណ៍យ៉ាងច្បាស់នៃឥទ្ធិពលរបស់ការអប់រំ អ៊ីស្លាម និងគំនិតពីប្រទេសជិតខាង ដែលបន្តមានឥទ្ធិពលលើការសិក្សាសាសនានៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ ។



សិស្សអនុវិទ្យាល័យជនជាតិចាម នៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ចូលរួមវេទិកាអប់រំស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម

## ការអប់រំបែប លី មូសា និង បែបក្រុមថ្មី

*រឿងរ៉ាវរបស់ការអប់រំសាសនាអ៊ីស្លាមនៅកម្ពុជា ចាប់ផ្តើមនៅក្នុងទសវត្សរ៍១៩៥០ នៅពេលដែល លី មូសា បាននាំយកមកកម្ពុជានូវការអប់រំសាសនាអ៊ីស្លាមដែលមានប្រើប្រាស់ពាសពេញប្រទេសម៉ាឡេស៊ី និងប្រទេសថៃភាគខាងត្បូង ។ លី មូសា គឺជាបញ្ញវន្តជនជាតិចាមល្បីឈ្មោះម្នាក់ កាលពីមុនរបបខ្មែរក្រហម ។ គាត់បានចាប់ផ្តើមអាជីពសាសនារបស់គាត់នៅកម្ពុជា បន្ទាប់ពីគាត់បានត្រឡប់ពីប្រទេសម៉ាឡេស៊ី នៅចន្លោះឆ្នាំ១៩៤៥ និង១៩៥០ ។*

*លី មូសា មានកំណើតនៅក្នុង គ្រួសារចាមក្រីក្រមួយ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩១៨ នៅភូមិអំពិល ឃុំប៊ឺស១ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។ គាត់ជាកូនបងបង្អស់ ។ នៅត្រឹមតែអាយុ១២ឆ្នាំ គាត់បានចាកចេញពីភូមិរបស់គាត់ ជាមួយនឹងមនុស្សពេញវ័យមិនស្គាល់ឈ្មោះ ទៅកាន់ប៉ោយប៉ែត នៅតាមព្រំដែន ប្រហែលជាទៅធ្វើការងារពលកម្មនៅត្រង់ចំណុចឆ្លងព្រំដែនដែលរវល់នេះ ។ មិនយូរប៉ុន្មាន បុរសជនជាតិថៃសប្បុរសម្នាក់ បានយកគាត់មកចិញ្ចឹម យកគាត់ទៅកាន់ក្រុងបាងកក និងបានផ្តល់ដល់គាត់នូវការអប់រំត្រឹមត្រូវ ។ ឥទ្ធិពលនៃបទពិសោធន៍របស់គាត់នៅបាងកក ប្រហែលជាបានរួមចំណែកយ៉ាងសំខាន់ទៅដល់ការអភិវឌ្ឍន៍ផ្នែកចំណេះដឹង ដែលជាមូលដ្ឋានសម្រាប់ការសិក្សាសាសនាអ៊ីស្លាម នៅប្រទេសម៉ាឡេស៊ី និងប្រទេសថៃភាគខាងត្បូង ។ ឥទ្ធិពលមួយក្នុងចំណោមឥទ្ធិពលទាំងនោះ គឺថា លី មូសា និយាយ អាន និង សរសេរភាសាថៃយ៉ាងស្ទាត់ជំនាញ ។ គាត់ប្រហែលជារៀនការរកស៊ីជំនួញ ពីឪពុកចិញ្ចឹមរបស់គាត់ដែរ ។ នៅពេលដែលគាត់នៅប្រទេសថៃភាគខាងត្បូង លី មូសា បានធ្វើជំនួញតូចមួយ នាំចូល និងនាំចេញសម្ភារៈសាងសង់រវាងខេត្តកូតាបារូ និងប៉ាតានី ។*

*លី មូសា បានក្លាយជាបញ្ញវន្តអ៊ីស្លាមមួយរូប នៅពេលគាត់នៅប្រទេសម៉ាឡេស៊ី ។ នៅឯ កូតាបារូ គាត់បានសិក្សានៅ នីក សាឡេ ប៉ុនដុក (Nik Saleh Pondok) ដែលនៅទីនោះ គាត់បានជួបជាមួយអនាគតមិត្តរួមការងារសាសនារបស់គាត់ ឈ្មោះ សុន អាម៉ាត់ (Son Ahmad) មកពីខេត្តកំពង់ចាម ។ ខុសពី សុន អាម៉ាត់ ដែលបន្តការអប់រំសាសនាអ៊ីស្លាមថ្នាក់ខ្ពស់របស់គាត់ នៅឥណ្ឌា លី មូសា ទទួលការសិក្សានៅតែប្រទេសម៉ាឡេស៊ីតែមួយគត់ ។ សុន អាម៉ាត់ ក្រោយមក ត្រូវបានគេស្គាល់ថាជាអ៊ីមាំអាម៉ាត់ឥណ្ឌា និងជាដៃគូជិតរបស់ លី មូសា នៅកម្ពុជា ។ ដូចសមាជិកមួយចំនួនរបស់ចលនាកុម្មុយនីស្តកម្ពុជាដែរ នៅពេលនោះ ដែលទទួលឥទ្ធិពលនៅពេលបំពេញការសិក្សានៅបរទេស លី មូសា ទទួលឥទ្ធិពលពីចលនាធ្វើឲ្យសាសនារស់ឡើងវិញនៅប្រទេសម៉ាឡេស៊ី ដែលមានឈ្មោះថា ចលនាអ៊ីសឡា (Islah movement) ដែលព្យាយាមធ្វើឲ្យមានការផ្លាស់ប្តូរចំពោះរបៀបដែលអ្នកកាន់សាសនាអ៊ីស្លាមនៅម៉ាឡេស៊ី បកស្រាយ និងប្រតិបត្តិសាសនាអ៊ីស្លាម ។ ថ្នាក់ដឹកនាំចលនានេះ ទទួលបានការអប់រំនៅមជ្ឈិមបូព៌ា ។ ចលនានេះ បាននាំឲ្យមានការបែកបាក់សហគមន៍អ៊ីស្លាមនៅម៉ាឡេស៊ីជាក្រុមថ្មី (kaum muda) និងក្រុមចាស់ (kaum tua) ។ ក្រុមចាស់ ទទួលបានការការពារពីមនុស្សវ័យចំណាស់ និងអាជ្ញាធរម៉ាឡេ ដែលប្រតិបត្តិការបង្រៀនអ៊ីស្លាមលាយឡំ ជាមួយការបួងសួងដូនតា និងជំនឿលើព្រលឹង ។ ក្រុមថ្មីព្យាយាមលុបបំបាត់ការប្រត្តិបត្តិបែបនេះ ។ ក្រុមថ្មីនេះទទួលបានជោគជ័យ ហើយ លី មូសា ចង់នាំយកគំនិតរបស់ក្រុមថ្មីនេះទៅឲ្យជនជាតិចាមរបស់គាត់នៅកម្ពុជា ។ គាត់ប្រហែលជាគិតថា ការប្តូរបែបនេះគឺមានភាពងាយស្រួលដោយសារថា អ៊ីស្លាមនៅម៉ាឡេស៊ី និងកម្ពុជា ត្រូវបានគេមើលឃើញថាស្រដៀងគ្នា ។*

*នៅពេលដែល លី មូសា បាននាំយកភាពទំនើបរបស់សាសនាអ៊ីស្លាមមកកម្ពុជា ការបង្រៀនរបស់គាត់ត្រូវបានគេមើលឃើញថាមានលក្ខណៈដើម និងងាយអនុវត្ត ដោយសារថាការបង្រៀននេះបានផ្អែកទៅលើការបកស្រាយមានហេតុផលនៃគម្ពីរគួរ៉ាន និងស៊ុនណា ។ លី មូសា មានជំនឿចិត្ត នៅក្នុងចំណេះដឹងរបស់គាត់អំពីអ៊ីស្លាម និងមុខវិជ្ជាទំនើប និងនៅក្នុងភាពប្រសើរលើសគេនៃការប្រតិបត្តិសាសនាបែបនេះ នៅក្នុងចំណោមការអនុវត្តសាសនាអ៊ីស្លាមនៅតាមមូលដ្ឋាននៅកម្ពុជា ដែលគាត់បានសម្តែងការជំទាស់យ៉ាងខ្លាំងក្លាម១ ទៅនឹងការបង្រៀនតាមរបៀបចាស់គំរិល ។ លី មូសា រស់នៅក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម បន្ទាប់ពីត្រឡប់ពីប្រទេសម៉ាឡេស៊ី ។ គាត់ជាអ្នកកាន់សាសនា ប៉ុន្តែជាមនុស្សសាសនាទំនើបម្នាក់ដែលខុសប្លែកពីគេ ។ នៅពេលដែលអ្នកភូមិស្លៀកសារុង លី មូសា ស្លៀកខោ ឬខោខ្លី ។ ខណៈពេលដែលរបៀបស្លៀកពាក់បញ្ជាក់ប្រាប់អំពីការគោរព ស្រលាញ់សាសនា និងបញ្ញវន្តភាព មុនដំបូង លី*

មូសា ត្រូវបានគេគិតថាជាបុរសក្មេងម្នាក់ ដែលទទួលឥទ្ធិពលអាក្រក់ ដែលបានចំណាយពេលច្រើនពេករស់នៅក្រៅប្រទេស ។ លី មូសា ក៏មានចិញ្ចឹមឆ្កែនៅក្នុងផ្ទះ ។ សត្វឆ្កែត្រូវបានគេគិតថាជាសត្វមិនស្អាត នៅក្នុងផ្ទះរបស់ជនជាតិចាម ។ សព្វថ្ងៃនេះ គ្រប់គ្នាអាចអង្កេតបានថា នៅតាមផ្ទះរបស់ជនជាតិចាមខ្លះ មានចិញ្ចឹមសត្វឆ្កែ ។ នេះប្រហែលជាកេរដំណែល បើទោះបីជាតិចតួចក្តី របស់ លី មូសា ។ លី មូសា ក៏បានបង្ហាញនូវភាពខុសប្លែកដែរនៅពេលថ្វាយបង្គំ ។

ដោយគ្មានការពន្យារពេល លី មូសា បានចាប់ផ្តើមបង្រៀនអំពីការបកស្រាយ និងប្រតិបត្តិសាសនាបែបថ្មីរបស់គាត់ ទៅឲ្យសមាជិកសហគមន៍របស់គាត់ ។ គាត់បង្រៀនអ្នកភូមិ ដែលរួមមានមនុស្សជំទង់ និងក្មេងៗ នៅពេលល្ងាច ចន្លោះការថ្វាយបង្គំលើកទី៤ (Maghrib prayer) និងការថ្វាយបង្គំលើកចុងក្រោយនៅពេលយប់ (Isha prayer) ឲ្យរៀនទន្ទេញគម្ពីរគួរ៉ាន និងបកស្រាយគម្ពីរគួរ៉ាន និងស៊ុនណា ។ មានថ្នាក់សម្រាប់អ្នកដែលមានចំណេះដឹងជ្រៅជ្រះអំពីអ៊ីស្លាមដែរ ។ សិស្សបានសាកល្បងជាមួយគាត់ ហើយគាត់អាចបង្ហាញនូវចំណេះដឹងខុសប្លែក ប៉ុន្តែសមហេតុសមផលទៅឲ្យសិស្ស ។ គាត់អាចបង្រៀនសិស្សអំពីមុខវិជ្ជាមិនពាក់ព័ន្ធនឹងសាសនា ដូចជាប្រវត្តិសាស្ត្រ សេដ្ឋកិច្ច នយោបាយ និងភូមិវិទ្យា ដែលមានរួមទាំងការរៀនមើលផែនទី ។ ចំណេះដឹងរបស់គាត់អំពីពិភពលោក និងចំណេះដឹងជ្រៅជ្រះអំពីសាសនាអ៊ីស្លាម បានក្លាយជាការសម្តែងឲ្យឃើញច្បាស់មួយទៅកាន់សិស្ស និងអ្នកគាំទ្ររបស់គាត់ ។ ការនេះបានបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ជោគជ័យ និងការពង្រីកអំពីការបកស្រាយថ្មីនូវសាសនាអ៊ីស្លាម ដែលក្រោយមកបានបង្កើតជាក្រុមថ្មីនៅកម្ពុជា ។ ការអប់រំសាសនាក្រៅផ្លូវការរបស់គាត់ បានរីកសាយភាយនៅពាសពេញសហគមន៍ ។ ថ្នាក់រៀនត្រូវបានបង្កើតនៅតាមផ្ទះទំនេរតាមភូមិ ព្រះវិហារសាសនាអ៊ីស្លាម សុរ៉ាវ និងមជ្ឈមណ្ឌលសហគមន៍ ។ សាលារៀនដំបូងគេបង្អស់របស់ក្រុមថ្មី ត្រូវបានកសាងឡើងនៅក្នុងឆ្នាំ១៩៧៣ នៅភូមិស្វាយឃ្លាំង ។ ជារួម គាត់បានកសាងសាលារៀនចំនួន៥ នៅខេត្តកំពង់ចាម និងក្រចេះ : ៣នៅក្នុងស្រុកក្រូចឆ្មារ និង២នៅក្នុងស្រុកឆ្លូង ។ សៀវភៅសាសនា ត្រូវបាននាំយកមកពីខេឡានតាន ។ ខ្លះត្រូវបានចម្លងដោយដៃ ។ កូនសិស្សម្នាក់របស់អ៊ីមាំ មូសា គឺ ហ្សាការី យ៉ា អាដាម ដែលជារដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ។

ប៉ុន្តែ ជាអកុសលសម្រាប់អ៊ីមាំ មូសា ការបង្កើតក្រុមថ្មីនេះ បាននាំឲ្យមានការបែកបាក់នៅក្នុងសហគមន៍ចាម និងបន្ទាប់មកអំពើហិង្សា ។ លី មូសា មិនបានរំពឹងថានឹងមានការប្រឆាំងទៅនឹងការផ្លាស់ប្តូរនេះ ពីសំណាក់ជនជាតិចាមវ័យចំណាស់ៗទេ ។ គាត់បានសន្មតថា ការពិចារណាដែលមានហេតុផល នឹងទទួលបានជ័យជម្នះលើទំនៀមទម្លាប់ថ្នាក់មូលដ្ឋាន និងថា ការអនុវត្តនឹងមានការផ្លាស់ប្តូរ ។ គាត់គិតខុស ។ អ៊ីមាំ មូសា ត្រូវបានចោទប្រកាន់ពីការប្រតិបត្តិសាសនាអ៊ីស្លាមមិនត្រឹមត្រូវ និងទំនងជាជ្រុលនិយម ។ ការពិភាក្សាធំមួយរវាងក្រុមថ្មី និងក្រុមចាស់ បានធ្វើឡើងនៅក្នុងឆ្នាំ១៩៥៥ ។ ក្រុមថ្មីដឹកនាំដោយ អ៊ីមាំ មូសា ចំណែកក្រុមចាស់ដឹកនាំដោយទួន ហាជ អាលី មកពីខេត្តមាត់ជ្រូក ប្រទេសវៀតណាម ដែលមានជំនួយពីទួន កាដឹក ពីភូមិជីទីក ខេត្តកំពង់ចាម ។ ដោយសារតែក្រុមថ្មី បានផ្អែកចំណេះដឹងរបស់ខ្លួនលើគម្ពីរគួរ៉ាន និង ស៊ុនណា និងការបកស្រាយត្រង់ៗនៃសៀវភៅទាំងពីរនេះបញ្ចូលជាមួយគំនិតមានហេតុផលបែបទំនើប ក្រុមថ្មី ទទួលបានជោគជ័យនៅក្នុងការពិភាក្សានេះ ។ ក្រុមចាស់ អាចពន្យល់នូវការបកស្រាយ និងការប្រតិបត្តិជាច្រើនរបស់ខ្លួន ដែលមានពាក់ព័ន្ធជាមួយនឹងជំនឿលើព្រលឹង និងទំនៀមទម្លាប់ ។

អ៊ីមាំ មូសា មិនត្រឹមតែបង្រៀនសាសនាទេ គាត់បានព្យាយាមបង្កឲ្យមានចល័តសង្គម និងលើកតម្កើងសហគមន៍ចាម តាមរយៈការអប់រំមិនពាក់ព័ន្ធនឹងសាសនា ។ នៅក្នុងឆ្នាំ១៩៥៣ អ៊ីមាំ មូសា និងសិស្សជិតនិតរបស់គាត់ បានបង្កើតជាសង្គមលីមូសា នៅពីរឆ្នាំមុនពេលព្រះបាទនរោត្តម សីហនុ បង្កើតសង្គមរាស្ត្រនិយម (សហគមន៍សង្គមនិយមរបស់ប្រជាជន) ។ សង្គមលីមូសានេះ បានកសាងសាលាបឋមសិក្សាជាច្រើនសម្រាប់ការអប់រំផ្លូវរដ្ឋ រៃអង្គាសថវិកា និងព្យាយាមបង្កើនស្ថានភាពរស់នៅជាទូទៅរបស់សហគមន៍ចាម ។ គ្រូបង្រៀនរបស់សាលារៀន គឺជាជនជាតិចាមដែលទទួលប្រាក់ពីរដ្ឋ ។ កម្មវិធីសិក្សាគឺជារបស់រដ្ឋាភិបាលកម្ពុជា ។ ការបង្កើតការអប់រំបែបវិទ្យាសាស្ត្រ របស់ លី មូសា នៅក្នុងសហគមន៍ចាម គឺជាការឆ្លើយតបទៅនឹងជំនឿរបស់ចាស់ៗជនជាតិចាមដែលថាការបញ្ជូនកូនទៅសិក្សានៅសាលារដ្ឋនឹងធ្វើឲ្យបាត់បង់អត្តសញ្ញាណ

ជាតិពន្ធុ ។ ការគិតបែបនេះ ជាក់ស្តែងបានចូលរួមចំណែកចំពោះភាពក្រីក្រនិងភាពមិនចេះអក្សរនៅក្នុងសហគមន៍ចាមដែលអ៊ីមាំ មូសា បានមើលឃើញនិងព្យាយាមដោះស្រាយ ។ ប៉ុន្តែសព្វថ្ងៃនេះ ភាពចេះភាសាខ្មែរ នៅក្នុងចំណោមចាមនៅតែមានកម្រិតទាបនៅឡើយ ។

នៅមុនពេលសម្រេចបាននូវទស្សនវិស័យរបស់គាត់ លី មូសា បានបាត់បង់ជីវិតនៅដើម ឆ្នាំ១៩៧៦ នៅក្នុងមន្ទីរឃុំឃាំងមួយរបស់ខ្មែរក្រហម ។ ការរួមចំណែករបស់គាត់ទៅក្នុងសហគមន៍ចាមគឺធំធេងណាស់ ។ គាត់ព្យាយាមដោះស្រាយការដើរថយក្រោយនៃសហគមន៍របស់គាត់តាមរយៈការអប់រំសាសនា និងការអប់រំបែបវិទ្យាសាស្ត្រ ។ បើទោះបីជាគាត់ស្លាប់ជិត៤០ឆ្នាំហើយ ក៏ដោយ ឥទ្ធិពលរបស់គាត់លើសហគមន៍ចាមគឺនៅមាននៅឡើយ ។ សាលារៀនរបស់គាត់នៅមាននៅឡើយ ។ អ្នកគាំទ្រសាលាហ៊ូថ្មីៗមួយរូបនៃសាលាគរុកោសល្យនៅភ្នំពេញបាននិយាយថា ៖ «អ៊ីមាំ មូសា មកពីប្រទេសថៃមកកាន់កម្ពុជានៅឆ្នាំ១៩៨៣ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរមកប្រតិបត្តិសាសនាដែលត្រឹមត្រូវ ។ នៅពេលនោះ ជនជាតិចាមទាំងអស់បានជំទាស់នឹង មូសា ប៉ុន្តែ សព្វថ្ងៃនេះ ចាមស្ទើរតែទាំងអស់បានប្រតិបត្តិតាមការបង្រៀនរបស់គាត់ ។ មូសា ធ្វើការងារតាមវិធីល្អ ។ គាត់ថែមទាំងបានបង្កើតសាលារៀនថ្មីៗ សម្រាប់ការអប់រំសាសនាត្រឹមត្រូវ ។ អ្នកប្រតិបត្តិតាមប្រពៃណីមិនចូលចិត្ត ជម្លោះផ្ទៃក្នុងនៅក្នុងចំណោមជនជាតិចាមទេ ហើយអ្នកទាំងនោះបានត្អូញត្អែរប្រាប់រដ្ឋាភិបាលថា ការបង្រៀនរបស់ មូសា បានធ្វើឲ្យមានការបែកបាក់នៅក្នុងចំណោមគ្រួសារ និងភូមិ» ។ គ្រូបង្រៀន បានចាត់ទុក អ៊ីមាំ មូសា ថាជាគំរូល្អសម្រាប់ការព្យាយាមរបស់ក្រុមគាត់ដើម្បីបន្សុទ្ធ អ៊ីស្លាមកម្ពុជា តាមរយៈទស្សនៈវិជ្ជាអ៊ីស្លាមដែលចេញមកពីមជ្ឈិមបូព៌ា ។ បើទោះបីជាអ៊ីមាំ មូសា មិនដែលសារភាពក៏ដោយ ការបកស្រាយត្រង់ៗនៃគម្ពីរគួរ៉ាន និងស៊ុនណា និងគោលជំហរប្រឆាំងនឹងការរួមបញ្ចូលគ្នា បានធ្វើឲ្យគាត់ជាអ្នកកាន់សាសនាអ៊ីស្លាមសាលាហ៊ូ ។

## ក្រុមថ្មី និងភាពនិយមឆ្លងប្រទេស

ពេលវេលាដែល អ៊ីមាំមូសា បានចាកចេញពីកម្ពុជាទៅកាន់ប្រទេសថៃភាគខាងត្បូង និងបន្ទាប់មកទៅប្រទេសម៉ាឡេស៊ី



ការរៀបចំប្រារព្ធពិធីបុណ្យម៉ាឡុតរបស់ជនជាតិចាម នៅវិហារកែវស ភូមិស្រែប្រិយ ឃុំស្រែប្រិយ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

គឺនៅដើមពេលនៃការអភិវឌ្ឍន៍ផ្នែកគមនាគមន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលនាំមកពីអឺរ៉ុប តាមរយៈអាណានិគមនិយមអង់គ្លេស ។ បារាំង ក៏បានកសាងនូវហេដ្ឋារចនាសម្ព័ន្ធ ផ្លូវសមដែរនៅក្នុងប្រទេសកម្ពុជា នៅអំឡុងពេលនោះ ។ ការនេះបានអនុញ្ញាតឲ្យ អ៊ីម៉ាំមូសា និងអ្នកកាន់សាសនាអ៊ីស្លាមគ្រាច់ចរ បានធ្វើដំណើរពីកម្ពុជា ថៃ ខេត្តទីបម៉ាឡេ អាស៊ីខាងត្បូង និងរហូតទៅដល់ទីក្រុងម៉ាកាស នៅមជ្ឈិមបូព៌ា ។ អ្នកសង្កេតការណ៍ជនជាតិបារាំងម្នាក់បានរាយការណ៍ថា គិតត្រឹមឆ្នាំ១៩៤០ ជនជាតិចាមរហូតដល់៥០០នាក់ បានធ្វើធម្មយាត្រាទៅកាន់ក្រុងម៉ាកាស ។ អ្នកស្រាវជ្រាវជនជាតិបារាំងម្នាក់ទៀត បានអះអាងថា នៅក្នុងទសវត្សរ៍ឆ្នាំ១៩៣០ សិស្សជនជាតិចាម មួយចំនួនធំ ស្ថិតនៅក្នុងប្រទេសថៃភាគខាងត្បូង និងម៉ាឡេស៊ី សិក្សាសាសនា និងរកការងារ ។ អ្នកដែលសិក្សានៅសាលាសាសនា បានទទួលការរៀនសូត្រពីអ្នកចេះដឹងម៉ាឡេស៊ីសំខាន់ៗ ដូចជា អ៊ីម៉ាំណា វ៉ាវី ដែលបានសរសេរជាច្រើនអំពីការពន្យល់បកស្រាយគម្ពីរគួរ៉ាន និង ពីមហាម៉ាត់ ប៊ីន ឌូដ (Mohammad bin Daud) ពីប៉ាតានី ។ អ្នកទាំងនេះគឺជាអ្នកនាំមុខដំបូងៗនៃចលនាក្រុមថ្មីនៅ ប្រទេសម៉ាឡេស៊ី និងប្រទេសថៃភាគខាងត្បូងដែលបានរីករាលដាលមកដល់ប្រទេសកម្ពុជា តាមរយៈសិស្សរបស់ខ្លួនគេ ដូចជា ហាជី សម ស៊ូ (Haji Sam Sou), អ៊ីម៉ាំ មូសា និង អ៊ីម៉ាំ អាម៉ាត់ ឥណ្ឌា (Imam Ahmad India) ។

ហាជី សម ស៊ូ អាចអះអាងបានថា ជាអ្នកបង្កើតសាលាសាសនាផ្លូវការដំបូងនៅកម្ពុជា ។ គាត់បានចម្លងយកកម្មវិធីសិក្សា និងបានទិញសម្ភារពីសាលាប៉ុនដុកម៉ាឡេស៊ី ដែលសិស្សរៀន និងស្នាក់នៅក្នុងសាលា នៅក្នុងឆ្នាំ១៩៤៨ ។ នៅពេលនោះបរទេស អ្នកចេះដឹងទាំងនេះ មិនត្រឹមតែសិក្សាអំពីការបកស្រាយគម្ពីរគួរ៉ានម៉ាឡេ និងអារ៉ាប់ប៉ុណ្ណោះទេ ថែមទាំងសិក្សាអំពីប្រព័ន្ធយុត្តិសាស្ត្រអ៊ីស្លាម (fiqh), ហាឌីត (Hadith) និងជំនឿខាងអធិធម្មជាតិរបស់អ៊ីស្លាម ។ ជនជាតិកម្ពុជាទាំងនេះ បានសិក្សាភាសាម៉ាឡេ និងអារ៉ាប់ ដោយសារតែជនជាតិចាមកម្ពុជា មិនមានប្រព័ន្ធសរសេរអក្សរចាមត្រឹមត្រូវ ។ ភាសាចាម បើទោះបីជាត្រូវបាននិយាយជាទូទៅ មិនអនុញ្ញាតឲ្យគេប្រើប្រាស់បាននៅក្នុងការសិក្សាស្រាវជ្រាវទេ ។ ភាសាម៉ាឡេ និងអារ៉ាប់ បានបំពេញតួនាទីនេះ ។ សព្វថ្ងៃនេះ ការណ៍នេះនៅតែមានស្ថានភាពដដែលនៅឡើយ ដែលសិស្សសាសនារៀនទាំងភាសាអារ៉ាប់ និងម៉ាឡេ ។

ចលនាក្រុមថ្មី មិនមែនមានប្រភពពីខេត្តទីបម៉ាឡេទេ ប៉ុន្តែពីប្រទេសអេហ្ស៊ីប តាមរយៈស្នាដៃរបស់អ្នកចេះដឹងខាងសាសនាអ៊ីស្លាមជនជាតិអេហ្ស៊ីបឈ្មោះ មហាម៉ាត់ អាប់ឌូ (Mohammad Abduh) និងអ្នកកំណែទម្រង់ដែលជាសិស្សរបស់គាត់ ជាការឆ្លើយតបទៅនឹងឥទ្ធិពលគ្របដណ្តប់ខាងផ្នែកវប្បធម៌ និងសេដ្ឋកិច្ច ពីលោកខាងលិច ។ មូហាម៉ាត់ អាប់ឌូ បានមើលឃើញការដើរថយក្រោយរបស់អេហ្ស៊ីប ដោយសារតែជំនឿដែលពុលស្អុយរលួយនៅក្នុងសាសនាអ៊ីស្លាម និងបានព្យាយាមបន្សុទ្ធការប្រតិបត្តិរបស់វា ។ គាត់បានរិះគន់ពិធីសាសនាអ៊ីស្លាមតាមតំបន់ និងការបកស្រាយ និងពិធីទាក់ទងទៅនឹងការចាប់កំណើតអាពាហ៍ពិពាហ៍ និងការស្លាប់ ។ គាត់ក៏បានព្យាយាមលុបបំបាត់ ការគោរពព្រលឹង និងដូនតា ដែលមានរីករាលដាលយ៉ាងខ្លាំងនៅក្នុងប្រទេសរបស់គាត់ ។ ជំនឿមិនបរិសុទ្ធទាំងនេះ រីករាលដាលនៅក្នុងទម្រង់ផ្សេងៗ នៅក្នុងចំណោមអ្នកកាន់សាសនាអ៊ីស្លាមនៅអាស៊ីអាគ្នេយ៍ ។ ជនជាតិចាម មានការប្រតិបត្តិបែបនេះយ៉ាងច្រើន ។ ប្រសិនបើចលនាកំណែទម្រង់នេះបានទទួលចំណាប់អារម្មណ៍ នៅអេហ្ស៊ីប ម៉ាឡេស៊ី និងប្រទេសថៃភាគខាងត្បូង និងផ្នែកផ្សេងៗទៀត នៅក្នុងពិភពលោក វានឹងក្លាយជាកម្លាំងផ្លាស់ប្តូរធំមួយនៅក្នុងសាសនាអ៊ីស្លាមកម្ពុជា ។ សិស្សជនជាតិកម្ពុជារបស់ក្រុមថ្មី បានបង្កសិស្សមួយចំនួនធំ នៅមុនពេលការផ្លាស់ប្តូរឲ្យប្រតិបត្តិថ្មីនេះត្រូវបានបញ្ចប់ នៅឆ្នាំ១៩៧៥ នៅពេលខ្មែរក្រហមបានចូលមកដល់ ។

នៅមុនពេលគាត់ស្លាប់នៅក្នុងរបបខ្មែរក្រហម រាជាធិបតី រេះ ឡា (Res Lah) ដែលជាមុ៉វទី កម្ពុជាទទួលការតែងតាំងនៅក្នុងឆ្នាំ១៩៦០ ដោយព្រះបាទនរោត្តមសីហនុ បានរិះគន់ក្រុមថ្មីដែលបានបង្កការចលាចលសង្គម និងធ្វើឲ្យបែកបាក់សហគមន៍ចាម ។ ការរិះគន់នេះ មានភាពទាក់ទងយ៉ាងពិសេសនៅក្នុងប្រទេសមួយដែលកំពុងធ្លាក់ទៅក្នុងសង្គ្រាមស៊ីវិលនៅក្នុងឆ្នាំ១៩៧០ និងបែកបាក់នយោបាយ ដែលត្រូវការជាចាំបាច់នូវសាមគ្គីភាព ។

## ប្រព័ន្ធសាលារៀនអ៊ីស្លាមកម្ពុជាបច្ចុប្បន្ន

បើទោះបីជាមានការកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សា

ជាន់ខ្ពស់ទទួលបន្ទុកកិច្ចការសាសនាអ៊ីស្លាម ក្នុងការគ្រប់គ្រងការអប់រំសាសនាអ៊ីស្លាម មិនមានប្រព័ន្ធអប់រំសាសនាអ៊ីស្លាមមជ្ឈការ ប្រព័ន្ធគ្រប់គ្រងគុណភាព ស្តង់ដារ ការរៀបចំកម្មវិធីសិក្សា ឬគរុកោសល្យ ដូចដែលមាននៅក្នុងប្រព័ន្ធអប់រំរដ្ឋរបស់កម្ពុជាទេ ។ សព្វថ្ងៃនេះ មានបណ្តាញសាលារៀនអ៊ីស្លាមចំនួនបីបួននៅកម្ពុជា គ្រប់គ្រងសាលារៀនសាសនាអ៊ីស្លាម មានចំនួន១០០ នៅជុំវិញប្រទេស ។ សាលាទាំងនេះរួមមានៈ សាលាម៉ាឡេស៊ី សាលាអារ៉ាប់ សាលាដាក់វ៉ះ និងសាលាឯករាជ្យ ។

បណ្តាញសាលារៀនម៉ាឡេស៊ី ត្រូវបានគេស្គាល់ជាទូទៅថាជា *SMU Annikmah Al Islamia* ។ សព្វថ្ងៃ បណ្តាញនេះមានសាលាច្រើនជាង១៥ នៅទូទាំងប្រទេសកម្ពុជា ។ សាលារៀនដំបូងនៃសាលារៀននេះ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៦ ។ មុនដំបូង សាលាទាំងនេះបង្រៀនតែការអប់រំអ៊ីស្លាម ជាមួយនឹងការសិក្សាភាសាម៉ាឡេប៉ុណ្ណោះ ។ សព្វថ្ងៃនេះ សាលាទាំងនេះមានបង្រៀនទាំងការអប់រំសាសនា និងការអប់រំបែបវិទ្យាសាស្ត្រ និងបានចម្លងកម្មវិធីសិក្សាពីម៉ាឡេស៊ីដែលចម្លងតពីប្រទេសអេហ្ស៊ីប ។ អ្នកបញ្ចប់ការសិក្សាពីប្រទេសទាំងនេះ អាចបន្តការសិក្សានៅសាលា *SMU* នៅប្រទេសម៉ាឡេស៊ី ។ ក្នុងឆ្នាំ២០០៥ មានសិស្សរហូតដល់ទៅ៥៧នាក់ពីសាលារៀនទាំងនេះ ដែលបានបន្តការសិក្សារបស់ខ្លួននៅម៉ាឡេស៊ី ។ គ្រូបង្រៀននៅសាលា *SMU* ជាទូទៅ ទទួលបានការអប់រំនៅម៉ាឡេស៊ី ថៃ និងឥណ្ឌូនេស៊ី ។ បណ្តាញសាលា *SMU* ទទួលបានថវិកាពីម្ចាស់ជំនួយជាច្រើន ដែលរួមមានទាំងជនជាតិចាមរស់នៅបរទេស ប៉ុន្តែទទួលបានជំនួយយ៉ាងគួរឲ្យកត់សម្គាល់ពី យ៉ាយ៉ាសាន់ អ៊ីស្លាម ខេឡាតាន *(Yayasan Islam Kelantan)* ។

បណ្តាញសាលាអារ៉ាប់ជាទូទៅមានឥទ្ធិពលគ្របដណ្តប់ដោយអង្គការចំនួនពីរគឺ *RIHS* និង អ៊ុមអាល់គូរ៉ា *(Umm al-Qura)* ។ នៅពេលអ៊ុមអាល់គូរ៉ា ត្រូវបានហាមឃាត់នៅកម្ពុជា បន្ទាប់ពីមានការចោទប្រកាន់ថាមានសកម្មភាពពាក់ព័ន្ធនឹងអំពើភេរវកម្មនៅក្នុងឆ្នាំ២០០៣ *RIHS* នៅតែជាអ្នកដឹកនាំតែមួយគត់នៅក្នុងបណ្តាញនេះ ។ នៅមុនពេលបិទទ្វារ សាលាអ៊ុមអាល់គូរ៉ា នៅខេត្តកណ្តាល គឺជាមជ្ឈមណ្ឌលអប់រំដ៏រវល់ដែលមានបុគ្គលិកបង្រៀនពីប្រទេសកាន់សាសនាអ៊ីស្លាមបីបួន ដែលទទួលជំនួយថវិកាពីប្រទេសអារ៉ាប៊ីសាអូឌីត ។ ទាំង *RIHS* និង អ៊ុមអាល់គូរ៉ា ប្រតិបត្តិសាសនាអ៊ីស្លាមសាលាហ្វី ។ ការបង្រៀនរបស់សាលាអារ៉ាប់ ត្រូវបានគេមើលឃើញថាៈ «ប្រឆាំងនឹងការរួមបញ្ចូលគ្នា និងធ្វើឲ្យលែងមានលក្ខណៈតាមតំបន់» ។

សិស្សរបស់និកាយសាលាហ្វី ជឿជាក់ថា ការបកស្រាយអ៊ីស្លាមរបស់អ៊ីម៉ាំសាន់ ដែលថា អ៊ីស្លាមគួរតែអនុវត្តទៅតាមតម្រូវការរបស់ប្រជាជន គឺមិនមែនជាការពិតទេ ។ ចំពោះអ្នកកាន់សាលាហ្វី អ្នកកាន់សាសនាអ៊ីស្លាមត្រូវតែស្តាប់គម្ពីរគួរ៉ាន និងស៊ុនណា គោរពតាមពាក្យសម្តី សុភាសិត និងសកម្មភាពរបស់ មូហាម៉ាត់ ។ សាលាហ្វី ជឿជាក់ថា ចលនា *TJ* គឺជាការកែច្នៃខាងផ្នែកសាសនា ។ ការកែច្នៃគឺត្រូវបានហាមឃាត់នៅក្នុងសាសនាអ៊ីស្លាម ។ ចលនា *TJ* បានស្នើឲ្យជនជាតិចាមធ្វើដំណើរទៅទេសនា ដោយប្រើប្រាស់មធ្យោបាយរៀងៗខ្លួន ។ ការបង្រៀនរបស់ពួកគេ គឺជាទម្រង់មួយនៃ គាក់លីម គាកលិម ឬអង្គុយជាមួយគ្នាដើម្បីពន្យល់ និងចែករំលែកចំណេះដឹង ដែលត្រូវបានធ្វើឡើងតាមរយៈការនិយាយតគ្នា ជាជាងតាមរយៈអត្ថបទសាសនាណានោះ ។ ធ្វើដំណើរទៅទេសនា បើទោះបីជាល្អ គឺជាការកែច្នៃ ។ ក្រុមសាលាហ្វីជឿជាក់ថា ចលនា *TJ* មានកំណើតពីប្រទេសឥណ្ឌាជាមួយនឹងអ្នកចេះដឹងម្នាក់ឈ្មោះ មហាម៉ាត់ អ៊ីយែស *(Mohammad Yyes)* ប៉ុន្តែ មិនមែនជាកន្លែងដែលសាសនាអ៊ីស្លាមមានប្រភពដើមនោះទេ ។

*RIHS* បង្កើតសាលាបឋមសិក្សាដំបូងនៅភ្នំពេញ នៅឆ្នាំ១៩៩៦ សម្រាប់ឲ្យក្មេងកំព្រា និងកូនអ្នកក្រីក្រ ។ សាលាបឋមសិក្សានេះ ត្រូវបានប្រែក្លាយទៅជាវិទ្យាល័យក្នុងឆ្នាំ២០០៣ ទទួលសិស្សពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ ។ សាលាបឋមសិក្សា ត្រូវបានដាក់នៅតាមសាខាខេត្តចំនួន៦ ក្នុងខេត្តតាកែវ កំពត កោះកុង បាត់ដំបង កំពង់ឆ្នាំង និងកំពង់ចាម ដំនឹក និង វាលតាច ។ មានតែសាលានៅកំពតប៉ុណ្ណោះដែលមានបង្រៀនថ្នាក់ទុតិយភូមិ ចំណែកឯសាលានៅវាលតាច ទទួលតែសិស្សស្រីប៉ុណ្ណោះ ។ សាលាទាំងអស់នេះគឺជាសាលាដែលឲ្យសិស្សស្នាក់នៅ ដែលទទួលសិស្សទាំងពីរភេទចំនួនពីរប្រភេទៈ កូនកំព្រា និងអ្នកក្រីក្រ ។ នៅក្នុងឆ្នាំ២០១២ វិទ្យាល័យរស្មីអ៊ីស្លាមកម្ពុជា មានសិស្សចំនួន៨៥០នាក់ (សិស្សស្រីចំនួន២០០នាក់) មកពីគ្រប់ទិសទីនៃប្រទេសកម្ពុជា ដែលរស់នៅ

និងសិក្សាដោយមិនបង់ថ្លៃ ។ នាយកទទួលខុសត្រូវខាងការសិក្សាសាសនាឈ្មោះ សុះ សាហ៊ីយ៉ា បានជ្រើសរើសសិស្សទាំងនេះ និងបាននិយាយថា «ជារៀងរាល់ថ្ងៃ ប្រជាជនបាននាំយកកូនៗរបស់ខ្លួនមកកាន់សាលារបស់ខ្ញុំ ប៉ុន្តែ ខ្ញុំត្រូវបង្ខំចិត្តបដិសេធ ដោយសារយើងមិនមានកន្លែងគ្រប់គ្រាន់» ។ ដើម្បីថែរក្សាគុណភាពអប់រំ និងជីវភាពរស់នៅសមរម្យនៅក្នុងសាលា សុះ សាហ៊ីយ៉ា បានសម្រេចថា គាត់មិនអាចទទួលសិស្សកំព្រា និងក្រីក្រ គ្រប់ៗគ្នាបានទេ ។

ឆ្នាំនីមួយៗ សិស្សប្រមាណជា៧០ ទៅ១០០នាក់ បានបញ្ចប់ការសិក្សាពីវិទ្យាល័យនេះ ។ ការបញ្ចប់ការសិក្សាបានអនុញ្ញាតឲ្យសិស្សទាំងនេះបន្តការសិក្សាថ្នាក់ឧត្តមសិក្សានៅកម្ពុជា និងសកលវិទ្យាល័យខ្លះទៀតនៅអារ៉ាប៊ីសាអូឌីត ម៉ាឡេស៊ី ប្រទេសថៃភាគខាងត្បូង និងឥណ្ឌូនេស៊ី ។ ផ្ទុយទៅវិញ ប្រទេសគុយវ៉ែតដែលជាប្រទេសម្ចាស់ជំនួយ កម្រនឹងទទួលសិស្ស *RIHS* ឲ្យសិក្សានៅសកលវិទ្យាល័យរបស់ប្រទេសខ្លួនណាស់ ។ សិស្សចំនួនរហូតដល់ ៥ ទៅ៦នាក់ ត្រូវបានទទួលឲ្យសិក្សានៅប្រទេសអារ៉ាប៊ីសាអូឌីតជារៀងរាល់ឆ្នាំដើម្បីសិក្សាថ្នាក់បញ្ញាបត្រ ស្ទើរតែទាំងអស់ សិក្សាភាសាអារ៉ាប់ និងសាសនាអ៊ីស្លាម ។ សកលវិទ្យាល័យដែលជាគោលដៅនៅក្នុងប្រទេសម៉ាឡេស៊ីរួមមាន *UAE* និងប៊ូការី *(Bukari)* ។ ប្រទេសឥណ្ឌូនេស៊ី ទើបតែចាប់ផ្តើមទទួលសិស្ស *RIHS* នៅពេលថ្មីៗនេះប៉ុណ្ណោះ ។

សាលា *RIHS* ដែលអនុញ្ញាតឲ្យសិស្សស្នាក់នៅទាំងអស់បង្រៀនទាំងការអប់រំសាសនា និងបែបវិទ្យាសាស្ត្រ ។ នៅក្នុងវិទ្យាល័យរស្មីអ៊ីស្លាមកម្ពុជា មុខវិជ្ជាវិទ្យាសាស្ត្រមានបង្រៀននៅពេលរសៀលពីម៉ោង១ ដល់ម៉ោង៥ល្ងាច បន្តពីកម្មវិធីរបស់ក្រសួងអប់រំ ខណៈពេលដែលមុខវិជ្ជា សាសនាត្រូវបានបង្រៀននៅពេលព្រឹកចាប់ពីម៉ោង៧ ដល់១២ ជាភាសាអារ៉ាប់ ។ ក្នុងឆ្នាំ២០១២ មានទូនចំនួន១៩ និងគ្រូចំណេះដឹងទូទៅចំនួន១៩នាក់ ។ ទូនស្ទើរតែទាំងអស់ទទួលបានការអប់រំថ្នាក់ឧត្តមសិក្សាពីប្រទេសអារ៉ាប៊ីសាអូឌីត ខណៈពេលដែលគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ត្រូវបានជ្រើសចេញពីបញ្ជីគ្រូរបស់រដ្ឋាភិបាល និងសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ ស្ទើរតែគ្រប់ករណីទាំងអស់ គ្រូបង្រៀនជាអ្នកកាន់សាសនាអ៊ីស្លាម លើកលែងតែគ្រូរូបវិទ្យាម្នាក់ដែលកាន់សាសនាព្រះពុទ្ធ ។ បើទោះបីជាគ្រូជាអ្នកកាន់សាសនាអ៊ីស្លាម គ្រូត្រូវបានស្នើឲ្យបង្រៀនសិស្សទាំងអស់ជាភាសាខ្មែរ ដើម្បីឲ្យការប្រកួតប្រជែងរបស់សិស្សចូលថ្នាក់ឧត្តមសិក្សានៅតាមសាកលវិទ្យាល័យក្នុងស្រុក នៅតែមានសភាពរឹងមាំ ។ ក្នុងឆ្នាំនីមួយៗ ប្រហែលជា៨៥ភាគរយនៃសិស្សរបស់វិទ្យាល័យរស្មីអ៊ីស្លាមកម្ពុជា បានបញ្ចប់ការសិក្សាចំណែកនៅឯមជ្ឈមណ្ឌលអ៊ីស្លាមកម្ពុជា រហូតដល់ទៅ ៩០ភាគរយ ។ នៅពេលសួរអំពីបញ្ហានេះ សែន អ៊ីម ជាអនុប្រធានបាននិយាយលេងសើចថា «នៅវិទ្យាល័យរបស់ខ្ញុំ សិស្សត្រូវបានជ្រើសរើសដោយផ្អែកលើស្ថានភាពអំពីភាពកំព្រា និងក្រីក្រ ។ នៅឯមជ្ឈមណ្ឌលអ៊ីស្លាមកម្ពុជា សិស្សត្រូវបានជ្រើសរើសដោយផ្អែកលើចំណេះដឹងហើយសិស្សត្រូវបង់លុយសម្រាប់ការរៀនសូត្រ» ។

កិច្ចខិតខំប្រឹងប្រែងរបស់ *RIHS* ដើម្បីផ្តល់ការអប់រំមិនបង់ប្រាក់សម្រាប់ក្មេងក្រីក្រ និងកំព្រា បានចូលរួមចំណែកយ៉ាងច្រើនចំពោះប្រព័ន្ធអប់រំកម្ពុជា ជាទូទៅ និងជាពិសេស ចំពោះសហគមន៍ចាម ។ ប៉ុន្តែ នៅឆ្នាំ២០០៧ មជ្ឈមណ្ឌល *RIHS* ពីរបីនៅកម្ពុជាត្រូវបានកត់សម្គាល់ដោយក្រសួងការបរទេសអាមេរិកថា មានជាប់ពាក់ព័ន្ធជាមួយអង្គការភេរវកម្ម ។ ការចោទប្រកាន់នេះមានលក្ខណៈធ្ងន់សម្រាប់អង្គការសប្បុរសធម៌ ដែលបានជួយក្មេងក្រីក្រ និងកំព្រាជាច្រើន ។ មិនមានចម្លើយតបជាផ្លូវការណាមួយពី *RIHS* នៅភ្នំពេញអំពីការចោទប្រកាន់នេះទេ ប៉ុន្តែ ដោយសារតែ *RIHS* គឺ មានលក្ខណៈជាប្រព័ន្ធបំផុតនៅក្នុងការផ្តល់ជំនួយអប់រំ ឪពុកម្តាយ និងអាណាព្យាបាលនៅតែបញ្ជូនកូនៗរបស់ខ្លួនទៅសាលា *RIHS* ។

នៅកម្ពុជា *RIHS* ត្រូវបានគេហៅថា អង្គការពិភពល្អកម្ពុជា ។ ក្រៅពីសាលាអនុញ្ញាតឲ្យសិស្សស្នាក់នៅ *RIHS* មានដំណើរការនូវមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀននៅភូមិគីឡូម៉ែត្រលេខ ៧ នៅភ្នំពេញ ។ ថ្មីៗនេះ មជ្ឈមណ្ឌលនេះត្រូវបិទដោយសារមូលហេតុ៤យ៉ាងៈ

◆ ទីមួយ សញ្ញាបត្ររយៈពេល២ឆ្នាំដែលផ្តល់ឲ្យមានគុណភាពទាបជាងសញ្ញាបត្រពីបរទេស ។

◆ ទីពីរ បន្ទាប់ពីបញ្ចប់ការសិក្សាពីថ្នាក់វិទ្យាល័យ សិស្សចង់សិក្សាសញ្ញាបត្រផ្នែកវិទ្យាសាស្ត្រជាង ដោយសិស្សជឿថាអាច

ឲ្យខ្លួនទទួលបានការងារល្អជាង និងទទួលបានប្រាក់បៀវត្សរ៍ច្រើនជាង បន្ទាប់ពីបញ្ចប់ការសិក្សា ជាជាងធ្វើជាគ្រូបង្រៀនសាសនា ។

◆ ទីបី មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន មិនបានផ្តល់បរិញ្ញាបត្រទេ ដែលសិស្សសព្វថ្ងៃនេះ រំពឹងថានឹងទទួលបាន បន្ទាប់ពីថ្នាក់វិទ្យាល័យ ។

◆ ទីបួន អំណោយសប្បុរសធម៌ឲ្យសាលាលែងមាន ដោយសារសិស្សមានវ័យធំជាងមុន និងត្រូវរំពឹងថាឲ្យបង់ប្រាក់ ។

សែន អ៊ីម បាននិយាយថា មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូនេះកំពុងត្រូវបានកែប្រែឲ្យទៅជាមហាវិទ្យាល័យវិជ្ជាជីវៈ ដែលអាចផ្តល់ទាំងសញ្ញាបត្រខាងសាសនា និងខាងវិទ្យាសាស្ត្រ ។ សិស្សត្រូវតែបង់ប្រាក់នៅក្នុងសាលានេះ ។

បណ្តាញសាលាដាក់វ៉ះ ត្រូវបានបង្កើតឡើង បន្ទាប់ពីការមកដល់នូវចលនាដាក់វ៉ះតាប្លីហ្គ (Dakwah Tabligh) នៅកម្ពុជា ក្នុងឆ្នាំ១៩៩២ ។ ស៊ូឡៃម៉ាន អ៊ីប្រាហ៊ីម បានបង្កើតសាលាដាក់វ៉ះដំបូងបំផុតនៅក្នុងឆ្នាំ១៩៩២ ។ ចាប់ពីពេលនោះមក ចលនាដាក់វ៉ះបានបង្កើតសាលាបីបួនទៀត នៅទូទាំងសហគមន៍ចាម ។ សាលានេះបង្រៀនតែការអប់រំសាសនាអ៊ីស្លាម ដោយផ្តោតជាពិសេស ទៅលើការទន្ទេញគម្ពីរគួរ៉ាន និងការបកស្រាយសាសនាអ៊ីស្លាមគន្លឹះៗ ដែលជាលក្ខណៈសម្គាល់របស់ចលនាដាក់វ៉ះ ដូចជា ភាពជាបងប្អូននៃសាសនាអ៊ីស្លាម ភាពមិនអាត្មានិយម សារសំខាន់នៃការស្លៀកពាក់ អាកប្បកិរិយាសម្រាប់ស្ត្រី គ្រោះថ្នាក់នៃសង្គមទំនើប និងសារសំខាន់នៃបេសកកម្មទេសនាដែលត្រូវតែធ្វើ ។ ជាទូទៅសិស្សមកពីសហគមន៍តាមមូលដ្ឋាន ។ សិស្សមានឱកាសដើម្បីបន្តការសិក្សាសាសនាអ៊ីស្លាមនៅប្រទេសថៃភាគខាងត្បូង និងម៉ាឡេស៊ី ។ គ្រូបង្រៀន គឺជាអតីតសិស្សរបស់សាលា ។ សិស្សខ្លះទទួលបានការហ្វឹកហ្វឺននៅប្រទេសថៃភាគខាងត្បូង និងប្រទេសម៉ាឡេស៊ី ។ មូលនិធិសម្រាប់សាលាទាំងនេះ បានមកពីសហគមន៍ចាមជនជាតិចាមនៅបរទេស អង្គការសាធារណៈ និងឯកជនថៃ និងម៉ាឡេស៊ី ។ ប៊ីជន ប្លែងស្លី (Bjorn Blengsli) បានអះអាងថា សិស្សពីរបីនាក់មកពីសាលានេះត្រូវបានបញ្ជូនទៅ "ម៉ាដ្រាស់សារ ឌីអូបាន់ឌី (Deobandi) នៅឥណ្ឌា និងប៉ាគីស្ថាន" ។

សាលាឯករាជ្យ ត្រូវបានបង្កើតឲ្យមានដោយមេដឹកនាំសហគមន៍ ។ សាលាទាំងនេះមិនស្ថិតនៅក្រោមបណ្តាញទាំងប៉ុន្មានខាងលើទេ បើទោះបីជាសាលាទាំងនេះប្រហែលជាអាចចម្លងកម្មវិធីសិក្សាពីបណ្តាញខាងលើក៏ដោយ ។ សាលាបែបនេះក៏ប្រហែលជាទទួលបានមូលនិធិខ្លះពីបណ្តាញសាលាខាងលើ ។ មជ្ឈមណ្ឌលអ៊ីស្លាមកម្ពុជា គឺជាសាលាឯករាជ្យ ។ ប៉ុន្តែកាលពីមុន វាគឺជាអតីតសាលាអ៊ុមអាល់គូរ៉ា ប៉ុន្តែនៅពេលបើកកាលពីឆ្នាំ២ ០ ០ ៤ សាលានេះត្រូវបានដឹកនាំដោយក្រុមប្រឹក្សាអ៊ីស្លាមកម្ពុជា ។ សាលាឯករាជ្យអាចជាសាលាតាមភូមិ កសាងឡើងដោយសម្ភារៈងាយស្រួលរកនៅតាមតំបន់មូលដ្ឋាន ដោយមានតែថ្នាក់រៀនតែពីរបីប៉ុណ្ណោះ ។

(តទៅលេខក្រោយ)

រអេង កុកថាយ

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# សក្ខីកម្ម និងការថ្លែងទុក្ខសោករបស់ ដួង អឿន


ដួង អឿន

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន អំពីរឿងរ៉ាវប្តីរបស់លោកស្រីដែលត្រូវបានគេសម្លាប់នៅក្នុងរបបខ្មែរក្រហម ។ ការសួរដេញដោលមានរយៈពេលជិតមួយថ្ងៃពេញ ចាប់ផ្តើមសួរដំបូងដោយក្រុមមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់មកសហព្រះរាជអាជ្ញា ហើយចុងក្រោយគឺក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និង ខៀវ សំផន ។ បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់ភាគី អង្គជំនុំជម្រះអនុញ្ញាតឲ្យ ដួង អឿន ថ្លែងអំពីទុក្ខវេទនា និងព្យសនកម្មទាំងឡាយដែលលោកស្រីបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមការបញ្ជាក់របស់ប្រធានអង្គជំនុំជម្រះ រឿងរ៉ាវរបស់ស្វាមី ដួង អឿន នឹងរួមចំណែកដល់អង្គជំនុំជម្រះក្នុងការរកឲ្យឃើញនូវអត្ថិភាព ឬនត្ថិភាពនៃអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ដួង អឿន មានអាយុ៧៥ឆ្នាំ កើតនៅភូមិពោធិ៍ចិនដាំ ឃុំពោធិ៍ចិនដាំ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ។ បច្ចុប្បន្នរស់នៅភូមិកំណើត ។ ដួង អឿន មានឪពុកឈ្មោះ ខិន ម្តាយឈ្មោះ អោ និងស្វាមី ឈ្មោះ ទេព យុន ហៅ ដុយ ។ ដុយ ជាជនជាតិវៀតណាម ។ គាត់អាចនិយាយភាសាខ្មែរបានតិចតួចប៉ុណ្ណោះ ។ ដួង អឿន រៀបការជាមួយ ដុយ នៅក្នុងរបប លន់ នល់ និងបង្កើតបានកូនស្រីម្នាក់ឈ្មោះ គីម វ៉ា ហៅ កាមាន ។ ដួង អឿន បញ្ជាក់ថា បន្ទាប់ពីខ្មែរក្រហមចូលមកកាន់កាប់ភូមិពោធិ៍ចិនដាំ ក៏មានការអំពាវនាវឲ្យជនជាតិវៀតណាមត្រឡប់ទៅប្រទេសកំណើតរបស់ខ្លួនវិញ ។ ពេលនោះមានវៀតណាមជាច្រើនគ្រួសារដែលក្នុងនោះមានទាំងបងប្អូនបង្កើត ឪពុកម្តាយ ក្មួយៗរបស់ ដុយ ក៏នាំគ្នាត្រឡប់ទៅស្រុកកំណើតវិញ ។ ប៉ុន្តែស្វាមីរបស់គាត់សម្រេចមិនត្រឡប់ទៅវិញ ដោយស្មគ្រចិត្តបន្តនៅស្លាប់រស់ក្នុងស្រុកខ្មែរ ។ ក្រៅពីនេះមានជនជាតិវៀតណាមមួយចំនួនទៀតក៏មិនត្រឡប់ទៅវិញដែរ ។

អឿន បញ្ជាក់ជូនអង្គសវនាការថា ខ្មែរក្រហមពុំបានស៊ើបរកជនជាតិវៀតណាមដែលនៅសេសសល់ ហើយក៏ពុំធ្លាប់មានការប្រជុំណែនាំថា វៀតណាមគឺជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ។

ចូលមកដល់ ខ្មែរក្រហមចាប់ផ្តើមធ្វើការរៀបចំភូមិឃុំ និងចាត់ចែងឲ្យប្រជាជនធ្វើការងារ ។ ដួង អឿន ត្រូវបានបញ្ជូនឲ្យទៅជីកដីលើកទំនប់ ធ្វើស្រែចម្ការ ហើយស្វាមីរបស់គាត់ត្រូវរែកជីដាក់ស្រែ ។ ក្រោយមក ដុយ ត្រូវបានអង្គការបញ្ជូនឲ្យទៅកាប់ព្រៃរំពាក់ ហើយបាត់ខ្លួនរហូត ។ អឿន បញ្ជាក់ថា ស្វាមីរបស់គាត់ត្រូវខ្មែរក្រហមនាំយកទៅក្នុងអំឡុងរដូវវស្សាឆ្នាំ១៩៧៧ ។ ពេលនោះគាត់គិតក្នុងចិត្តថា ស្វាមីគាត់ប្រហែលជាមិនត្រឡប់មកវិញទេ ព្រោះអ្នកដែលខ្មែរក្រហមប្រាប់ថា "ឲ្យទៅកាប់ព្រៃរំពាក់" តែងតែបាត់ខ្លួនរហូត ។ ទោះបីជាយ៉ាងណា ដួង អឿន ពុំដឹងថាស្វាមីគាត់មានជោគវាសនាបែបណានោះទេ ហើយក៏ពុំដឹងថាការបញ្ជូនទៅនេះគឺដោយសារស្វាមីគាត់ជាជនជាតិវៀតណាម ឬយ៉ាងណាដែរ ។ ប៉ុន្តែ គាត់កត់សម្គាល់ឃើញថាជនជាតិវៀតណាមមួយចំនួនដូចជា ង៉ាង និងគ្រួសាររបស់ ឡាច នី ក៏ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅកាប់ព្រៃរំពាក់ដែរ ។

ក្នុងការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និង ខៀវ សំផន មានមន្ទិលជាខ្លាំងទាក់ទងនឹងតួនាទី និងមុខរបរកស៊ីរបស់ ដុយ មុនឆ្នាំ១៩៧៥ ។ នៅចំពោះមុខអង្គជំនុំជម្រះ អឿន បញ្ជាក់ថា ស្វាមីរបស់គាត់ពុំមានរកស៊ីអ្វីផ្សេងទៀតឡើយ ក្រៅពីរបរទិញលក់មាន់និងទា ហើយជីវភាពគាត់នៅពេលនោះមានការខ្វះខាតខ្លាំង ។

ជុយពីការអះអាងនេះ មេធាវី វ៉ិចទ័រកូប៉េ និង អង់តាហ្គីសេ បានដកស្រង់ចម្លើយជាច្រើនរបស់ ដួង អឿន ដែលបានឆ្លើយជូនអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាថា ស្វាមីរបស់គាត់ធ្លាប់រកស៊ីដួញដូរអាភៀន ហើយពេលនោះគាត់មានប្រាក់ជាច្រើន ។ មេធាវីក៏ដកស្រង់ដែរនូវចម្លើយរបស់ ឌិន អៃ ប្អូនរបស់ អឿន ដែលបញ្ជាក់ថា ជុយ ធ្លាប់រត់ពន្ធថ្នាំពេទ្យមកពីវៀតណាមមកលក់នៅក្នុងទឹកដីខ្មែរ ។ ទោះបីមានការដកស្រង់មកបញ្ជាក់ដូច្នេះក្តី អឿន នៅតែអះអាងថា ស្វាមីគាត់គឺជាអ្នករកស៊ីទិញលក់មាន់ និងទា ។ គាត់ពុំដែលដឹងថា ស្វាមីគាត់រកស៊ីលក់អាភៀន ឬរត់ពន្ធថ្នាំពេទ្យនោះទេ ។ ប៉ុន្តែ អឿន ទទួលស្គាល់ថា ស្វាមីរបស់គាត់ធ្លាប់ធ្វើទាហានវៀតណាម ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់ភាគី ដួង អឿន បានថ្លែងទុក្ខសោក និងព្យសនកម្មមួយចំនួនដែលគាត់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដួង អឿន រៀបរាប់ថា នៅក្នុងរបបនោះគាត់ត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការជាទម្ងន់ និងគ្មានពេលសម្រាក ។ ក្រៅពីកិច្ចការធ្វើស្រែចម្ការគ្រប់រដូវ ខ្មែរក្រហមបានចាត់ឲ្យគាត់ទៅលើកទំនប់ និងរែកដីធ្ងន់ៗ ។ ការងារទាំងនេះបានបណ្តាលឲ្យគាត់ធ្លាក់ខ្លួនឈឺរហូតមកដល់សព្វថ្ងៃ ។ បន្ថែមលើនេះ អឿន មានការឈឺចាប់ជាខ្លាំងដោយសារកូនប្រុសរបស់គាត់ (កូនប្តីមុន) ត្រូវខ្មែរក្រហមយកទៅសម្លាប់ ហើយស្វាមីគាត់ឈ្មោះ ជុយ ត្រូវខ្មែរក្រហមនាំយកទៅបាត់រហូត ។ សព្វថ្ងៃ គាត់ត្រូវរស់នៅរងទុក្ខវេទនាជាមួយកូនស្រី ។ នៅចុងបញ្ចប់នៃការថ្លែងនេះ ដួង អឿន ស្នើសុំឲ្យមានការឧបត្ថម្ភដល់ជីវភាពរបស់គាត់ ព្រោះគាត់មានការខ្វះខាតខ្លាំង ។ **ចាន់ ប្រាថ្នា**


# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងឧបត្ថម្ភពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បង់ទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើបសហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនា រៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង អ៊ូច មករា តាមរយៈទូរស័ព្ទលេខ : ០១៧ ៦៦៥ ៦៧៥ ។ អ៊ីម៉ែល : truthmakara@dccam.org

គេហទំព័រ : www.ariverchangescourse.com





# អន្លង់វែង ៖ ទស្សនៈអ្នកខាងក្រៅ

សម្រាប់រូបខ្ញុំ ការធ្វើដំណើរតាមផ្លូវជាតិលេខ៦ ដូចនឹងបទពិសោធន៍កាលដែលខ្ញុំជិះសេះអឺចឹង ។ ការធ្វើដំណើរនេះពិតជាពិបាកជាងគេក្នុងប្រទេសកម្ពុជា ប៉ុន្តែវាក៏ជាការល្អម្យ៉ាងដែរ ។ ខ្ញុំបានធ្វើដំណើរជាមួយមិត្តរួមការងារដែលមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាទៅកាន់ស្រុកអន្លង់វែង ក្នុងគោលបំណងដើម្បីសម្រេចការរៀបចំផែនការ និងចាប់ផ្តើមការសាងសង់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។

មុនពេលដែលខ្ញុំទៅដល់ ខ្ញុំបានឮរឿងរ៉ាវមួយចំនួនអំពីស្រុកអន្លង់វែង នៅទីនោះខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើលបន្តិចនៅពេលដែលឃើញបរិយាកាសស្ងប់ស្ងាត់ក្នុងទីប្រជុំជននោះ ។ ទីនោះមើលទៅហាក់ដូចជាមិនខុសអ្វីពីកន្លែងផ្សេងៗទៀតក្នុងប្រទេសកម្ពុជាទេ ។ អ្នកស្រុកក្នុងតំបន់មានភាពស្ងប់ស្ងាត់ ចំណែកនៅតាមទីផ្សារមានសកម្មភាពមមាញឹកជាធម្មតា ។ នៅទីនោះខ្ញុំមិនឃើញមានអាវុធ ហើយក៏មិនឃើញមានសញ្ញាណាមួយដែលបង្ហាញថាកន្លែងនោះធ្លាប់ជាអតីតមូលដ្ឋានរឹងមាំចុងក្រោយរបស់ខ្មែរក្រហមនោះឡើយ ។

ជាដំបូង ខ្ញុំពិតជានឹកស្មានមិនដល់ឡើយ នៅពេលឃើញហាងលក់សម្ភារៈយោធាមួយនៅផ្លូវម្ខាងទៀតជិតព្រំដែនថៃ តែខុសពីការស្មានរបស់ខ្ញុំ ម្ចាស់ហាងនោះមិនមែនជាអតីតយុទ្ធជនខ្មែរក្រហមដែលព្យាយាមលក់ចោលនូវរបស់របរចាស់ៗសល់ពីសង្គ្រាមនោះទេ ។ តែផ្ទុយទៅវិញ ហាងដែលមានសណ្ឋានពីរជាន់ដូចជាផ្ទះ (មានក្មេងៗលេងនៅជាន់លើខាងក្រោយផ្ទះ) មើលការខុសត្រូវដោយក្មេងស្រីជំទង់ពីរនាក់ និងមានលក់ពោរពេញទៅដោយសម្ភារៈយោធាអាមេរិកក្លែងក្លាយទេ បើតាមតែខ្ញុំស្មានមើលទៅ ។ តាមមើលទៅសម្ភារៈយោធាទាំងនោះ ភាគច្រើននាំចូលមកពីប្រទេសថៃ ដែលជាប្រភពសម្រាប់ផលិតសម្ភារៈផ្សេងៗទៀត ដែលរចនាម៉ូត


ទីបញ្ចុះរបស់តាម៉ុក នៅលើខ្នងភ្នំដងរែក ស្ថិតនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ដាក់ថា (USA) (Made in America) និង (U.S Army) ពេញនៅលើសម្ភារៈទាំងនោះ ដោយពេលខ្លះនៅលើស្លាកសញ្ញាទាំងនោះមានដាក់អក្សរថា (Made in Thailand) ។ តម្រុយតែមួយគត់ដែលអាចឲ្យខ្ញុំរកឃើញពីខ្មែរក្រហម និងទំនាក់ទំនងរវាងខ្មែរក្រហមជាមួយនឹងរបស់របរអាមេរិកាំងនោះគឺជាដែកកេះបុរាណមួយចំនួនដែលមានរូបសត្វឥន្ទ្រីនៅពីមុខ ដោយលក់ក្នុងតម្លៃថ្លៃ១៥០ដុល្លារ ។ កម្រិតសន្តិសុខ ស្ថិរភាព និងពាណិជ្ជកម្ម ដែលខ្ញុំបានជួបប្រទះក្នុងស្រុកអន្លង់វែង ពិតជាមិនដូចទៅនឹងអ្វីដែលខ្ញុំបានគិតមុនពេលខ្ញុំមកដល់មូលដ្ឋានរឹងមាំចុងក្រោយរបស់ខ្មែរក្រហមនេះទេ ។ មានទីតាំងពីរកន្លែងដែលឆ្លុះបញ្ចាំងពីសង្គ្រាមស៊ីវិលក្នុងប្រទេសកម្ពុជាកាលពីអតីតកាល ម្យ៉ាងទៀតកន្លែងទាំងពីរនោះក៏ប្រហែលជាប្រភពសក្តានុពលនៃអស្ថិរភាពនាពេលអនាគតដែរ ។

យប់ដំបូងនៅស្រុកអន្លង់វែង យើងបានទៅមើលទីតាំងដំបូងនោះគឺៈ ផ្ទះតាម៉ុក ។ ផ្ទះនោះនៅក្បែរនិងកណ្តាលភូមិ ក្នុងទីតាំងមួយយ៉ាងល្អដែលអាចមើលឃើញបឹងអន្លង់វែងនៅយ៉ាងស្ងប់ស្ងាត់ ។ នៅតាមជញ្ជាំងផ្ទះពោរពេញទៅដោយរូបភាពស្នេហាជាតិ ដូចជារូបប្រាសាទអង្គរវត្ត ព្រះវិហារ និងដែនទឹកម្ពុជាចាស់ ។ សំណង់នោះមានបីជាន់ តែមិនមានអ្វីនៅក្នុងនោះទេ ក្រៅពីរូបភាព និងសសរឈើគ្រញូងដ៏មានតម្លៃ ។ នៅជាន់ក្រោមមានបន្ទប់ប្រជុំលក្ខណៈឯកជនមួយដែលមើលទៅវាត្រូវបានច្នៃឡើងដើម្បីផ្ទុកសំឡេង ។ ជាក់ស្តែង បន្ទប់នោះធ្លាប់ជាកន្លែងដែល តាម៉ុក ជួបប្រជុំជាមួយថ្នាក់ដឹកនាំខ្មែរក្រហមផ្សេងៗ ។

ក្រៅពីអ្វីជាកេរដំណែលបន្សល់ទុកពីជម្លោះស៊ីវិលនៅកម្ពុជា ផ្ទះ តាម៉ុក ក៏អាចដើរតួរយ៉ាងសំខាន់ក្នុងការបង្ហាញឲ្យឃើញពីការវិវឌ្ឍន៍ឈានទៅដល់ជម្លោះស៊ីវិលផ្សេងទៀតក្នុងពេលអនាគតខាងមុខ ។ តាមរយៈគេហទំព័រ Open Development Cambodia ផ្ទះ តាម៉ុក ស្ថិតក្នុងតំបន់មួយមានទំហំ៤៨.២០០ហិកតា ដែលក្នុងនោះមានក្រុមហ៊ុនបីបានទទួលបានលិខិតអនុញ្ញាតរុករករ៉ែលើដីសម្បទានពីរកន្លែងផ្សេងគ្នា (Krumhun Ratatanak Stone Cambodia Development, Krumhun Yum Khea Minerals Cambodia និងក្រុមហ៊ុន KD Power Group) ។

**១) ដីសម្បទានរ៉ែក្នុងស្រុកអន្លង់វែង ។ ផែនទី និងទិន្នន័យបានមកពី** opendevelopmentcambodia.net (edited in Microsoft Paint)

ដីសម្បទានទាំងពីរនេះបូកបញ្ចូលគ្នាមានទំហំស្មើនឹង២ភាគ៣នៃទំហំសរុបរបស់ក្រុងភ្នំពេញទាំងមូល ។ ទំហំនេះមានចំនួនធំធេងជ្រុលហួសហេតុលើសពីដីធម្មតាដែលអនុញ្ញាតឲ្យជីកយករ៉ែ ។ លើសពីនេះទៀត ដីសម្បទាន ទាំងនេះមានទីតាំងមិនដល់១០០ម៉ែត្រផងពីបឹងអន្លង់វែងត្រើយខាងកើតកន្លែងដែលបឹងពីរហូរកាត់ចូលគ្នាហើយមានបឹងទីបីហូរកាត់ចូលក្នុងបឹងស្រែង ។ បឹងទាំងបីនេះ ស្ថិតក្នុងដីសម្បទាន ដូចនេះ បឹងនីមួយៗ ដើរតួជាអាងធម្មជាតិសម្រាប់ផ្ទុកទឹកហូរច្រោះពីតំបន់នានា ។ មូលហេតុទាំងនេះហើយ អាចបណ្តាលឲ្យការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាដែលមានលក្ខណៈជាវិជ្ជមាននិងរយៈពេលខ្លីនេះ ក្លាយជាគ្រោះថ្នាក់សម្រាប់ជាតិដែលអាចបណ្តាលឲ្យមានផលប៉ះពាល់ផ្សេងៗដល់ក្មេងជំនាន់ក្រោយ ។ ខណៈពេលដែលក្រុមហ៊ុន Ratanak Stone ទទួលបានការអនុញ្ញាតចុះធ្វើអាជីវកម្មរ៉ែលើលោហៈម្យ៉ាងដែលមិនធ្លាប់រុករកពីមុន ក្រុមហ៊ុនពីរផ្សេងទៀតដែលទទួលបានលិខិតអនុញ្ញាតដូចគ្នាដែរនោះក៏កំពុងតែផ្តោតធ្វើការជីកយករ៉ែធ្យូងថ្មដែរ ដែលជារ៉ែម្យ៉ាងមានលក្ខណៈកខ្វក់ជាងគេ និងមានទម្រង់បញ្ចេញឥន្ធនៈកខ្វក់ជាងគេ ។ ជាធម្មតា ការបញ្ចេញអាស៊ីតរ៉ែជាផលប៉ះពាល់ បណ្តាលមកពីការបំបែករ៉ែមានតម្លៃពីរ៉ែផ្សេងៗទៀត ហើយម្យ៉ាងទៀតការបញ្ចេញអាស៊ីតទាំងនេះ ត្រូវការគ្រប់គ្រង និងរក្សាទុកជាច្រើនឆ្នាំ ក្រោយពេលអាជីវកម្មរ៉ែទាំងនោះបញ្ចប់ ។ ការបញ្ចេញអាស៊ីតរ៉ែទៅក្នុងទឹកដែលមានលក្ខខណ្ឌខ្ពស់ និងមានឧប្បត្តិហេតុកើតឡើងជារៀងរាល់ឆ្នាំ សូម្បីតែនៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ក៏ដោយ ហើយបន្តឲ្យមានមហន្តរាយដល់បរិស្ថានយ៉ាងខ្លាំងដែរ ។ សូមក្រឡេកទៅមើលគ្រោះថ្នាក់រ៉ែនៅ Mount Polley កាលឆ្នាំ២០១៤ ក្នុងប្រទេសកាណាដា ឬក៏ក្រឡេកមើលការបង្ហូរទឹកសំណល់កខ្វក់ពីរោងចក្រ Gold King Mine ក្នុងសហរដ្ឋអាមេរិក ។ សូម្បីតែបណ្តាប្រទេសអ្នកមានលើសកលលោកក៏ពិបាកទប់ទល់នឹងគ្រោះថ្នាក់ទាំងនេះដែរ ។ ប្រទេសកម្ពុជាកំពុងតែប្រឈមមុខនឹងបញ្ហាគ្រោះថ្នាក់ទាំងនេះ ។

ដូចនឹងតំបន់ប្រភពទឹកផ្សេងៗដែរ ស្រុកអន្លង់វែងកំពុង

ប្រឈមយ៉ាងខ្លាំងនឹងបញ្ហាជីករ៉ែត្បូងថ្ម ពីព្រោះតំបន់នេះនៅជិតតំបន់ភ្នំ ជាពិសេសជួរភ្នំដងរែក ។ តំបន់ខ្ពង់រាបទាំងនេះអំណោយផលដល់ប្រព័ន្ធផ្លូវទឹកក្នុងតំបន់មានបឹងស្រេងហូរចាក់ចូលក្នុងបឹងទន្លេសាប ដែលជាជម្រកស្បៀងសម្រាប់ប្រជាជនកម្ពុជា ។ ការបញ្ចេញសារធាតុអាស៊ីតឧស្សាហកម្មយ៉ាងខ្ជីខ្ជាចូលទៅក្នុងផ្លូវទឹកទាំងនេះក៏ដូចជាក្នុងបឹងស្រេងដែរ អាចបណ្តាលឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ដល់ជីវិតដែលរស់នៅដំណាក់ទឹកខាងក្រោម រួមបញ្ចូលទាំងបឹងទន្លេសាប ទន្លេមេគង្គ និងប្រទេសវៀតណាម ។ ដោយមិនមានបទបញ្ញត្តិតឹងរ៉ឹង និងមានប្រសិទ្ធភាពក្នុងការការពារប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់នោះទេ ប្រទេសកម្ពុជានឹងបរាជ័យក្នុងការការពារជីវិតសត្វព្រៃ ក៏ដូចជាប្រជាជនដែលរស់អាស្រ័យលើប្រព័ន្ធអេកូឡូស៊ីនេះដែរ ។ ដោយសារតែភ្លៀងធំ និងទឹកជំនន់នារដូវវស្សា នោះរ៉ែដែលគេទុកចោលក្នុងតំបន់ណាមួយក៏នឹងអាចបង្កគ្រោះថ្នាក់ដែរ ។

ជម្លោះរាប់ទសវត្សរ៍ជាហេតុធ្វើឲ្យសម្បត្តិរ៉ែធម្មជាតិនៅកម្ពុជាជាច្រើនមិនទាន់ត្រូវបានគេរុករក ។ ក៏ប៉ុន្តែទន្ទឹមនឹងឧស្សាហកម្មរ៉ែកម្ពុជានៅមិនទាន់អភិវឌ្ឍន៍បានល្អ អំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះមានដីសម្បទានរ៉ែជាច្រើនត្រូវបានអនុញ្ញាតឲ្យធ្វើការរុករកជាពិសេសតំបន់ភ្នំ និងទំនាបផ្លូវទឹក ។ កម្ពុជាកំពុងជួបប្រទះបញ្ហាជាច្រើនទាក់ទងនឹងដីសម្បទាន ដែលក្នុងចំណោមដីសម្បទានទាំងនោះមានមួយចំនួនបានបង្កឲ្យមានការកាប់ព្រៃឈើខុសច្បាប់ ដែលបានប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនជាច្រើន ពេលខ្លះក៏ធ្វើឲ្យប្រជាជនបង្ខំចិត្តផ្លាស់ទីលំនៅទៀតផង ។ មានរបាយការណ៍មួយចំនួននិយាយពីក្រុមហ៊ុនរ៉ែបរទេសដែលមានអំណាចមួយចំនួនបានប្រព្រឹត្តអំពើពុករលួយជាមួយមន្រ្តីរដ្ឋាភិបាលក្នុងការទទួលបានអាជ្ញាប័ណ្ណជីកយករ៉ែ ។ យើងចាំបាច់ត្រូវតែរឹតបន្តឹងឲ្យមានបទដ្ឋានអន្តរជាតិ ដែលត្រូវតែអនុវត្តលើគ្រប់ដំណើរការទាំងមូលនៃការអភិវឌ្ឍន៍យករ៉ែ តែទោះជាយ៉ាងណាក៏ដោយ ការធ្វើបែបនេះពេលខ្លះអាចទប់ស្កាត់ឧប្បត្តិហេតុទាំងអស់បានទេ ។ ដូចនេះហើយការវាយតម្លៃបរិស្ថានឲ្យសព្វជ្រុងជ្រោយពិតជាមានសារសំខាន់ត្រូវតែអនុវត្តឲ្យមានតម្លាភាព មុនពេលដែលរដ្ឋាភិបាលសម្រេចប្រគល់អាជ្ញាប័ណ្ណ ហើយរឿងសំខាន់មួយទៀតគឺថា ការវាយតម្លៃទាំងនោះត្រូវតែប្រកាសទៅដល់សាធារណជន និងបណ្តាអ្នកវាយតម្លៃបរិស្ថាន ឯករាជ្យដើម្បីធ្វើការត្រួតពិនិត្យមុនពេលធ្វើការអភិវឌ្ឍន៍ជីកយករ៉ែ ។ អំពើពុករលួយ ភាពខ្ជីខ្ជា កង្វះដំណើរការត្រឹមត្រូវ ឬក៏មិនមានការយកចិត្តទុកដាក់ពីបទដ្ឋានអន្តរជាតិក្នុងការផ្តល់អាជ្ញាប័ណ្ណជីកយករ៉ែក្នុងស្រុកអន្លង់វែង និងតំបន់ដទៃទៀត សុទ្ធសឹងតែជាកត្តាប្រឈមចម្បងដែលអាចនាំឲ្យមានជម្លោះស៊ីវិលក្នុងប្រទេសកម្ពុជា ។

យើងគួរតែថ្លឹងថ្លែងឲ្យបានម៉ត់ចត់នូវតម្លៃបាត់បង់ផ្នែកសង្គម និងបរិស្ថានជារយៈពេលវែង ដោយធៀបនឹងផលចំណេញផ្នែកសេដ្ឋកិច្ចដែលមានរយៈពេលខ្លីប៉ុណ្ណោះ នៅក្នុងគ្រប់ទីតាំងណាដែលមានការស្នើសុំអាជ្ញាប័ណ្ណជីកយករ៉ែ ជាពិសេសក្នុងតំបន់ដែលមានអំណោយផលបរិស្ថានដូចជាតំបន់អន្លង់វែងជាដើម ។

ទីតាំងទីពីរដែលយើងបានទៅទស្សនា ហើយដែលឆ្លុះបញ្ចាំងពីជម្លោះស៊ីវិលក្នុងប្រទេសកម្ពុជា នោះគឺជាបណ្តោយផ្លូវឆ្ពោះទៅកាន់ទីតាំងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដែលនឹងលេចរូបរាងនាពេលអនាគត ។ បណ្តោយផ្លូវនេះត្រូវបាន តាម៉ុក និងទាហានរបស់គាត់សាងសង់ ហើយយើងនៅតែប្រើប្រាស់ផ្លូវនេះរហូតដល់សព្វថ្ងៃ ។ យ៉ាងណាមិញ ចាប់តាំងពីខ្មែរក្រហមធ្វើសមាហរណកម្មចូលក្នុងសង្គមកម្ពុជាមក ផ្លូវនេះបានក្លាយទៅជាព្រំដែនរវាងកម្ពុជា និងថៃទៅហើយ ដោយរឿងរ៉ាវទាំងនេះមានអ្នកស្រុកម្នាក់ (សូមមិនបញ្ចេញឈ្មោះ) បានប្រាប់ខ្ញុំ ។ បើតាមកម្មវិធីផែនទីក្នុងទូរស័ព្ទរបស់ខ្ញុំ យើងត្រូវតែឆ្លងកាត់ព្រំដែនថៃពីរដង ដើម្បីទៅដល់ទីតាំងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ តាមផ្លូវទៅទីនោះ យើងបានឆ្លងកាត់សាលារៀនមួយ ។ អ្នកស្រុកម្នាក់បានប្រាប់ថា អំឡុងពេលសាងសង់សាលារៀននោះ មានកម្មករខ្មែរយើងត្រូវបានទាហានថៃមួយក្រុមមកនិយាយគំរាម និងទាមទារឲ្យមានការជួបប្រជុំមួយមុនពេលចាប់ផ្តើមសាងសង់ ។ អស្ថិរភាពបែបនេះនៅតែបន្ត ទន្ទឹមនឹងនោះតែងតែមានការរាយការណ៍ជាញឹកញាប់ស្តីពីអ្នកកាប់ឈើខ្មែរលួចចូលក្នុងប្រទេសថៃខុសច្បាប់ ក៏ដូចជារបាយការណ៍ស្តីពីទាហានថៃរំលោភចូលក្នុងទឹកដីកម្ពុជា ដូចជាករណីខាងលើ ។ អ្នកស្រុកខាងដើមនោះក៏បាននិយាយថា កាលនៅសម័យខ្មែរក្រហមកាន់កាប់ យោធាថៃបានគោរពលើព្រំដែនកម្ពុជាល្អជាង ហើយពេលនោះដែរ ទាហានថៃស្ថិតនៅក្នុងព្រំដែនថៃយ៉ាងស្ងប់ស្ងាត់ ។ ទោះជាយ៉ាងនេះក្តី អ្នកស្រុករូបនោះបានលើកឡើងថា ទាហានទាំង

នោះមិនមានមហិច្ឆតាលេបយកទឹកដីណាទេ ហើយអ្នកទាំងនោះនៅតែយល់ឃើញថា បណ្តោយផ្លូវនោះនៅតែជាព្រំដែនសីមារវាងប្រទេសទាំងពីរ ។

កម្ពុជាមានប្រវត្តិសាស្ត្រយូរអង្វែង និងស្មុគស្មាញជាមួយនឹងថៃរាប់សតវត្សរ៍មកហើយ តែអ្នកស្រុកអន្លង់វែងបញ្ជាក់ប្រាប់ខ្ញុំថា ទំនាក់ទំនងរវាងប្រជាជនទាំងពីរនៅតែល្អ ។ ជនជាតិភាគតិចខ្មែរ និងអ្នកនិយាយភាសាខ្មែរដទៃទៀតរស់នៅយ៉ាងជ្រៅក្នុងទឹកដីថៃ និងជុំវិញខេត្តថៃដូចជា ខេត្តសុរិន្ទ ខេត្តស្រីសាន និងខេត្តស៊ីសាកេត ។ មានសំណង់រាងជាប្រាសាទអង្គរវត្តជាច្រើននៅពាសពេញផ្លូវភ្នំដងរែក ចំណែកឯទាហានថៃនៅជិតព្រំដែនកម្ពុជាវិញក៏និយាយភាសាខ្មែរ ហើយអ្នកទាំងនោះភាគច្រើនគឺជាប្រជាជនខ្មែរដែរ ។ ទាំងនេះសុទ្ធតែជាមរតកពីអាណាចក្រខ្មែរ និងសរឲ្យឃើញថាព្រំដែនទាំងនេះ មិនបង្ហាញពីទីបញ្ចប់របស់ប្រជាជាតិណាមួយ ឬក៏ការចាប់ផ្តើមរបស់ប្រជាជាតិថ្មីណាមួយដែរ ទោះបីព្រំដែនទាំងនោះជាសញ្ញាព្រំប្រទល់របស់រដ្ឋក៏ដោយ ។ តែអ្វីដែលជាការព្រួយបារម្ភបំផុតនោះគឺថា ធម្មជាតិក៏មិនក្រែងញញើតនឹងវត្តមានព្រំដែនប្រទេសដែរ ។ លទ្ធភាពនៃការដឹកយកឈើមានតម្លៃដូចជាឈើមាសជាដើម ក្នុងទ្រង់ទ្រាយធំនៅតាមព្រំដែនប្រទេសទាំងពីរ អាចបណ្តាលឲ្យមានផលប៉ះពាល់ដែលបណ្តាលឲ្យស្លាប់ដល់កម្មករឈើក្នុងតំបន់នោះ ។ គួរយ៉ាងដូចជាអ្នកកាប់ឈើ ដែលឆ្លងចូលទឹកដីថៃ អ្នកទាំងនោះត្រូវបានទាហានថៃបាញ់សម្លាប់ ដោយសារល្មើសលើព្រំដែនថៃ ម្យ៉ាងទៀត ដោយសារខ្វះឱកាសរកចំណូលបានសមរម្យនោះ មនុស្សមួយចំនួនប្រាកដជាត្រឡប់ទៅប្រថុយអាយុជីវិតរបស់គេសម្រាប់ឱកាសទទួលបានប្រាក់ចំណូលច្រើន ។

ប្រជាជនដែលខ្ញុំបាននិយាយជាមួយក្នុងស្រុកអន្លង់វែងបានឲ្យយោបល់ថា សហគមន៍អន្តរជាតិគួរតែចូលរួមឲ្យច្រើនជាងមុន ក្នុងការដោះស្រាយជម្លោះព្រំដែនរវាងកម្ពុជា និងថៃ ដោយហេតុតែគាត់ខ្លាចក្រែងថា កម្ពុជាតែម្នាក់ឯងមិនអាចដោះស្រាយជាមួយភាគីថៃបាន ។ បញ្ហានេះមិនត្រឹមតែជាបញ្ហារបស់កម្ពុជា និងថៃតែប៉ុណ្ណោះទេ តែជាបញ្ហាអន្តរជាតិ ។ ធនធានធម្មជាតិ និងវប្បធម៌មិនមែនអ្វីរ៉ុបមួយចំនួនមានចំណុចពីរយ៉ាងដូចគ្នានោះគឺថា ធនធានធម្មជាតិ និងវប្បធម៌ទាំងនោះមិនអាចនិយាយអ្វីចំពោះការបង្កើតព្រំដែនអន្តរជាតិសម័យទំនើបនោះទេ ហើយចំណុចមួយទៀតគឺថា ធនធានធម្មជាតិ និងវប្បធម៌ទាំងនោះ នៅតែបែងចែកពីគ្នាដោយព្រំដែនអន្តរជាតិដដែល ។ ក៏ប៉ុន្តែអ្វីដែលខុសពីធនធានធម្មជាតិនោះគឺថា មនុស្សអាចផ្លាស់ប្តូរអនាគតរបស់ខ្លួនបានហើយអាចជម្នះលើការកេងប្រវ័ញ្ចណាមួយមកលើខ្លួនបាន លើសពីនោះមនុស្សអាចធ្វើបែបនេះបានយ៉ាងល្អនៅពេលដែលមនុស្សចេះរួបរួមគ្នា ។

សេណារីយ៉ូមួយគួរឲ្យព្រួយបារម្ភ ដែលអាចប៉ះពាល់ដល់សន្តិភាពក្នុងតំបន់នោះគឺនៅពេលដែលផលប្រយោជន៍របស់រដ្ឋ និងសាជីវកម្មកាន់តែមានទំនោរទៅកាន់ការរុករក និងការទាញយករ៉ែមានតម្លៃក្នុងទ្រង់ទ្រាយធំ នៅតាមបណ្តោយព្រំដែន ជាពិសេសនៅពេលដែលសាជីវករ និងភាគីរដ្ឋនោះមិនបានប្រាប់ដំណឹងជាមុនពីការរុករកនោះទៅកាន់ភាគីរដ្ឋាភិបាលប្រទេសម្ខាងទៀត ។ កម្ពុជា និងថៃ សព្វថ្ងៃមានជម្រើសមួយ សហការ និងពិភាក្សាដោះស្រាយជម្លោះព្រំដែនសំដៅទទួលបានប្រយោជន៍រួម ឬក៏ម្យ៉ាងទៀតមិនបាច់មានវិធានការអ្វីគឺចាំតែប្រឈមនឹងគ្រោះថ្នាក់ដែលបណ្តាលមកពីជម្លោះស៊ីវិលកាន់តែច្រើនឡើងៗនាពេលអនាគត ។

ឥឡូវជាពេលល្អបំផុតក្នុងការចាប់ផ្តើមសកម្មភាព និងជំរុញឲ្យមានការពិភាក្សាឲ្យបានស៊ីជម្រៅរវាងប្រជាជន និងបណ្តារដ្ឋាភិបាលក្នុងតំបន់អាស៊ាន និងពិភពលោកស្តីពីបទដ្ឋាន និងបញ្ញត្តិបរិស្ថានជាតិ អន្តរជាតិ ព្រមទាំងបញ្ហាព្រំដែន ក្រោយសម័យអាណានិគម ដោយបូកបញ្ចូលបញ្ហាព្រំដែនកម្ពុជា-ថៃដែរ សំដៅទៅរកការសម្រេចឲ្យបាននូវលទ្ធផលមួយដែលឆ្លងកាត់ការព្រមព្រៀងគ្នា និងមានសន្តិភាពសម្រាប់មនុស្សជាតិទាំងអស់ ។ កន្លែងសមរម្យសម្រាប់ធ្វើការពិភាក្សាបែបនេះគឺមាននៅក្នុងមជ្ឈមណ្ឌលសន្តិភាព ដែលនឹងសាងសង់ឡើងក្នុងស្រុកអន្លង់វែងនាពេលខាងមុខ ។

ខាងក្រោមនេះជាអាសយដ្ឋានអេឡិចត្រូនិចរបស់ «កម្មវិធីទស្សនកិច្ចសន្តិភាពអន្លង់វែង» ដែលជាការចាប់ផ្តើមការងាររបស់មជ្ឈមណ្ឌលសន្តិភាព ឆ្ពោះទៅរកវត្ថុបំណងជំរុញដល់សន្តិភាព ការអប់រំ និងសហគ្រាសសង្គមដោយវត្ថុបំណងទាំងនោះតែងពង្រឹងឲ្យគ្នាទៅវិញទៅមក ។

**ខ្លែតឌីស្លេខ ហ្សេដ្ឋរ៉ូខ**

# សេចក្តីតបនៃសម្តេចព្រះមហាអរិយវង្ស ទៅនឹងសំណួររបស់វិទ្យាស្ថានស្ទីភរីត

***១) ខ្ញុំសូមសួរព្រះតេជគុណអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលត្រូវបានពិភាក្សាគ្នាយ៉ាងក្តៅគគុក នាពេលបច្ចុប្បន្ន តើព្រះតេជគុណយល់ឃើញបែបណាចំពោះដំណើរការនោះ?***



រូបខាងឆ្វេង៖ សម្តេចព្រះមហាអរិយវង្ស សៅរ៍ ចន្ទថុល គង់នៅវត្តលង្កា

◆ ចំពោះអាត្មាភាពផ្ទាល់ ការរៀបចំតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ គឺត្រូវបានធ្វើឡើងស្របនឹងឆន្ទៈរបស់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស ដែលជាជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម នឹងស្របទៅតាមច្បាប់ជាតិ និងអន្តរជាតិ ។ បើទោះជាដំណើរការនោះប្រព្រឹត្តទៅជាមួយលទ្ធផលបែបណាក៏ដោយ យ៉ាងហោចណាស់ វាក៏ត្រូវបានចាត់ទុកថា ជាយន្តការមួយដ៏មានសារសំខាន់ និងជាប្រវត្តិសាស្ត្រសម្រាប់ជាតិខ្មែរ ក្នុងដំណើរការស្វែងរកការពិតមួយសម្រាប់ចងក្រងជាប្រវត្តិសាស្ត្រ ទុកជាមេរៀនសម្រាប់កូនខ្មែរជំនាន់ក្រោយ ។ ជាសរុប អាត្មាយល់ឃើញថា ការរៀបចំ និងដំណើរការប្រព្រឹត្តទៅរបស់តុលាការនេះ មានតម្លៃជាប្រវត្តិសាស្ត្រ និងមានសារសំខាន់ខ្លាំង សម្រាប់ប្រជារាស្ត្រខ្មែរ និងជនទាំងឡាយនៅក្នុងពិភពលោកនេះ ។

***២) ឈរលើគោលការណ៍ព្រះធម៌ តើតុលាការនេះសមស្របដែរឬទេ?***

◆ បើនិយាយតាមទស្សនៈ កម្ម-ផល នៅក្នុងព្រះពុទ្ធសាសនា បុគ្គលណាប្រព្រឹត្តអំពើជាកុសល នឹងឲ្យផល មកជា សុខ ហើយផ្ទុយមកវិញបុគ្គលណាប្រព្រឹត្តអំពើជាអកុសល រមែងទទួលបានផលជាទុក្ខ ពោលគឺមាន **ហេតុ** ទើបមាន **បច្ច័យ** បើយ៉ាងនេះសួរថាហេតុអ្វីបានជាមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម? ហេតុដែលនាំឲ្យកើតតុលាការនេះគឺដោយសារមានរបបខ្មែរក្រហម ដែលនៅក្នុងរបបនេះមេដឹកនាំទាំងនោះបានដឹកនាំកម្ពុជាធ្លាក់ក្នុងមហាវិនាសកម្មយ៉ាងខ្លោចផ្សា គឺការប្រល័យពូជសាសន៍ បណ្តាលឲ្យបង់ជីវិតអស់រាប់លាននាក់ ។ ដូច្នេះ បើយោងតាមទស្សនៈខាងលើនេះ ឃើញថាការបង្កើតតុលាការនេះ គឺអាស្រ័យដោយមានការប្រល័យពូជសាសន៍ ជាហេតុដែលស្របទៅនឹងគោលការណ៍ទំនាក់ទំនង **ហេតុ** និង **ផល** នៅក្នុងព្រះធម៌ដែលសម្តែងដោយព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

***៣) តើគួរមានការផ្សះផ្សាគ្នារវាងអតីតកម្មាភិបាលខ្មែរក្រហមជាមួយនឹងប្រជាជនកម្ពុជាដទៃទៀតដែរឬទេ?***

◆ អាត្មាភាពសូមឆ្លើយដោយខ្លីថា ត្រូវមានការផ្សះផ្សា ព្រោះថា ការផ្សះផ្សានេះជាគោលការណ៍ដែលនាំទៅរកការរំលត់ចោលនូវទោសៈទាំងឡាយ ដែលកំពុងកើតមាននៅក្នុងសន្តានចិត្តនៃបុគ្គលពាក់ព័ន្ធក្នុងរបបខ្មែរក្រហម ។ ការផ្សះផ្សា ជាវិធីនាំទៅរកការរស់នៅក្នុងសន្តិភាពរវាងបុគ្គលទាំងឡាយនៅក្នុងសង្គម ពោលជាការជៀសវាងនូវការសងសឹករវាងគ្នានឹងគ្នា ។ តែទោះយ៉ាងណាការផ្សះផ្សានោះត្រូវធ្វើឡើងនៅក្នុងគោលការណ៍រក្សាបាននូវស្ថិរភាពសង្គម និង អាចទទួលយកបានដោយភាគីនៃបញ្ហា ។

***៤) តើព្រះតេជគុណគិតថាអតីតមេដឹកនាំខ្មែរក្រហមទទួលរងសមនឹងអ្វីដែលខ្លួនបានប្រព្រឹត្តដែរឬទេ?***

◆ ដូចមានបញ្ជាក់នៅក្នុងចម្លើយនៃសំណួរទី៧រួចមកហើយ ដូច្នេះម្ចាស់កម្ម ត្រូវតែទទួលផលដែលកើតពីកម្មនោះ ពោលគឺអ្វីដែលអតីតមេដឹកនាំខ្មែរក្រហមកំពុងទទួលបាននាពេលនេះ គឺជាផលកើតមកពីអំពើដែលខ្លួនបានប្រព្រឹត្តនៅក្នុងអតីតកាល ។

***៥) ព្រះពុទ្ធសម្តែងធម៌អំពីកម្មវេរា ។ តើជនរងគ្រោះនៃរបបខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មានកម្មវេរាអ្វី?***

◆ បើនិយាយអំពីទស្សនៈកម្ម-ផល គឺវាមានជម្រៅជ្រៅពិបាកយល់ណាស់ វាជាវិស័យរបស់ព្រះពុទ្ធ និងព្រះអរហន្តគ្រប់ព្រះអង្គពុំមែនជាវិស័យដែលបុគ្គលធម្មតាយល់បានដោយងាយឡើយ តែទោះយ៉ាងណាប្រសិនបើយើងខិតខំបង្កើនបញ្ញាឲ្យចាស់ក្លាទៅ ប្រហែលនឹងអាចស្វែងយល់បានចំណែកខ្លះ ។ ដូច្នេះហើយអាត្មាភាពហាក់មានការលំបាកធ្វើការសន្និដ្ឋានដោយដាច់ខាតថាអ្វីដែលជនរងគ្រោះនៃរបបខ្មែរក្រហមទទួលបាននៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ជាកម្មវេរាអ្វីរបស់ពួកគេណាស់ ដ្បិតរឿងកម្មពីអតីតជាតិណាមួយនោះពុំមាននរណាម្នាក់បានឃើញ និងអាចបង្ហាញជាសាធារណៈបាន ដែលខុសពីផលដែលមេដឹកនាំខ្មែរក្រហមកំពុងទទួល គឺការកាត់ទោសនៅក្នុងតុលាការនាពេលបច្ចុប្បន្ន វាកើតដោយសារកម្មពីអតីតរបស់គេ (ប្រល័យពូជសាសន៍) ត្រូវបានមើលឃើញជាទូទៅ ។ ប៉ុន្តែអាត្មាភាពសូមបញ្ជាក់ជាថ្មីថា អ្វីៗទាំងអស់កើតដោយសារទំនាក់ទំនង **ហេតុ** និង **ផល** ។ មានរឿងខ្លះមនុស្សមើលឃើញទាំងហេតុ និងមើលឃើញទាំងផល តែមានរឿងខ្លះទៀតមនុស្សមើលឃើញតែផល មិនអាចមើលឃើញហេតុដែលនាំឲ្យកើតផលនោះបានគឺអាស្រ័យដោយបញ្ញាមានកម្រិត វាក៏នាំឲ្យក្លាយជាអបិយជំនឿដោយប្រការផ្សេងៗ ។

***៦) តើមេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តបទឧក្រិដ្ឋកម្មដោយចេតនាឬទេ? តើជាចេតនារបស់មេដឹកនាំខ្មែរក្រហមឬ?***

◆ សំណួរនេះអាត្មាភាពគ្មានចម្លើយពិតប្រាកដទេ ដ្បិតគ្មាននរណាម្នាក់ជាបថុជ្ជជន អាចមើលចិត្តបុគ្គលម្នាក់ទៀតធ្លុះបាននោះឡើយ នេះបើនិយាយតាមផ្លូវបរមត្ថ តែបើតាមគោលការណ៍នៃបទល្មើសព្រហ្មទណ្ឌវាអាចផ្សេងពីនេះ ។

***៧) តើព្រះតេជគុណជឿថា ពៀររំងាប់ដោយការមិនចងពៀរ ដែរឬទេ?***

◆ ព្រះសម្មាសម្ពុទ្ធបានប្រកាសថា ពៀររំងាប់ដោយការមិនចងពៀរ ដែលជាមូលដ្ឋានគ្រឹះយ៉ាងមាំនៅក្នុងការបញ្ចៀសបានទោស កើតឡើងពីទោសៈ ហើយជាការពិតណាស់ការមិនចងពៀរនឹងគ្នា ជាដើមហេតុនាំឲ្យពៀរមួយរលត់ទៅ ។ ជាពុទ្ធសាសនិកត្រូវស្វែងយល់ពីគោលការណ៍នេះប្រកបដោយហេតុ និងផលរួមជាមួយបញ្ញា ព្រោះរឿងពៀរវេរា នេះជាបញ្ហាស្មុគស្មាញពិបាកយល់សម្រាប់ពុទ្ធសាសនិក វាជារឿងទំនាក់ទំនងរវាងអតីត បច្ចុប្បន្ន និងអនាគតរបស់បុគ្គលគ្រប់រូប ហើយជារឿងកាន់តែពិបាកយល់ទៅទៀតត្រង់ថា ពៀរ និងការរំងាប់ពៀរគឺស្ថិតនៅត្រង់ចិត្តនៃបុគ្គល ។ តែយ៉ាងណាជាសរុបអាត្មាភាពផ្ទាល់ជាបព្វជិតនៅក្នុងសាសនានេះជឿជាក់ទាំងស្រុងទៅលើទស្សនៈនេះនៅក្នុងន័យបរមត្ថធម៌ ដោយមិននិយាយពីលោកិយធម៌ទេ ។

***៨) តើព្រះតេជគុណគិតថាការសិក្សាអំពីប្រវត្តិសាស្រ្តរបបខ្មែរក្រហមអាចរំពុកអំពីការឈឺចាប់របស់ប្រជាជនដែរឬទេ?***

◆ ការសិក្សាពីប្រវត្តិសាស្រ្តខ្មែរក្រហម ពិតណាស់នឹងផ្តល់ការឈឺចាប់ដល់ជនរងគ្រោះ ដោយសារពួកគេ បាននឹកឃើញរឿងរ៉ាវឈឺចាប់នៅក្នុងអតីតកាល ។ តែទោះជាយ៉ាងនេះក្តី ការសិក្សានេះនឹងនាំមកនូវមេរៀនជីវិតសម្រាប់ពួកគេ ពោលគឺរៀបសូត្រពីបទពិសោធន៍ យ៉ាងហោចណាស់ពួកគេអាចចងចាំទុកប្រៀបប្រដៅដល់កូនចៅជំនាន់ក្រោយឲ្យជៀសវាងផ្លូវនេះ ឬយ៉ាងហោចណាស់ជនដែលមានបញ្ញាខ្ពស់អាចនឹងកើតមាន ធម្មចក្ខុ យល់ពីរឿងរ៉ាវលោកធម៌ ដែលគ្រប់ជីវិតត្រូវតែទទួល ។ ការឈឺចាប់ គឺជាប្រភពនៃការរំលត់ការឈឺចាប់ ដូច្នេះរៀនសូត្រពីការឈឺចាប់ពួកគេអាចរៀនរំលត់សេចក្តីឈឺចាប់បាន ។

***៩) ប្រជាជនកម្ពុជាជាច្រើនដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម នៅតែរងការឈឺចាប់ដោយសារតែហេតុការណ៍ដែលបានកើតមានឡើង តើព្រះពុទ្ធសាសនាអាចចូលរួមចំណែកក្នុងការព្យាបាលការឈឺចាប់នេះដោយរបៀបណា?***

◆ សូមបញ្ជាក់ថាព្រះពុទ្ធសាសនាបង្រៀនមនុស្សឲ្យស្គាល់ច្បាស់ពី ទុក្ខ តាមមូលដ្ឋានអរិយសច្ចៈ គឺ៖

ទុក្ខសច្ចៈ ទុក្ខជាសច្ចធម៌ (កើតមានគ្រប់ជីវិតសត្វក្នុងត្រៃ

លោក)

សមុទយសច្ចៈ (ហេតុដែលនាំឲ្យកើតទុក្ខ)

និរោធសច្ចៈ (ទុក្ខទាំងឡាយរមែងអាចរំលត់បាន) និង

មគ្គសច្ចៈ (មាគ៌ាសម្រាប់រំលត់ទុក្ខ) ។

លើសពីនេះទៀត ព្រះពុទ្ធសាសនាអប់រំមនុស្សឲ្យស្គាល់ពី អនិច្ចតាធម៌ (សភាវៈទាំងឡាយមានការប្រែប្រួលជាធម្មតា) ទុក្ខតាធម៌ (សភាវៈជាទុក្ខសម្រាប់សព្វសត្វ) អនត្តាធម៌ (សភាវៈមិនមែនជារបស់ខ្លួននៃសព្វសត្វ) និងមានធម្មជាតិជាច្រើនទៀតដែលព្រះពុទ្ធសាសនាអប់រំមនុស្សដើម្បីស្វែងយល់ពីសច្ចធម៌ ។ ដូច្នេះប្រសិនបើជនរងគ្រោះទាំងអស់នៅក្នុងរបបខ្មែរក្រហម ប្រាកដជាតាំងចិត្តសិក្សាព្រះធម៌ និងប្រតិបត្តិក្នុងព្រះធម៌ នោះពួកគេប្រាកដជាកើតមានបញ្ញាជ្រះថ្លា ញុំាងទុក្ខទាំងឡាយឲ្យរសាយទៅជាលំដាប់ ។ ព្រះពុទ្ធសាសនាអាចជួយពួកគេបានក្នុងករណីដែលពួកគេមានឆន្ទៈចង់ឲ្យព្រះពុទ្ធសាសនាជួយ ពោលគឺពួកគេត្រូវរៀនស្វែងយល់ពីព្រះធម៌ និងប្រតិបត្តិក្នុងព្រះធម៌ នោះពួកគេនឹងបានសេចក្តីសុខ ព្រោះព្រះធម៌ ។

**១០) តើរាជរដ្ឋាភិបាលអាចធ្វើអ្វីបានខ្លះដើម្បីជួយព្យាបាលប្រជាជនអំពីបញ្ហាសុខភាពផ្លូវចិត្តនេះ? ចំណែកព្រះសង្ឃវិញអាចធ្វើអ្វីបានខ្លះ?**

◆ ការបង្កើតឲ្យមានការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនាពេលបច្ចុប្បន្ននេះ ត្រូវបានចាត់ទុកថា ជាការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរួមចំណែកព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនខ្មែរ ដែលជាជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ។ ក្រៅពីនេះរាជរដ្ឋាភិបាល តាមរយៈការអប់រំ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ក៏ជាវិធានការព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនដែរ ព្រោះពួកគេទទួលបានចំណេះដឹង និងស្ថានភាពរស់នៅល្អប្រសើរ យ៉ាងហោចណាស់ពួកគេក៏អាចរំសាយកំហឹងបាន ដោយការទទួលយកនូវស្ថានភាពដែលល្អប្រសើរនោះ ។ ចំណែកព្រះសង្ឃនៅក្នុងព្រះពុទ្ធសាសនាវិញ រឹតតែមានតួនាទីយ៉ាងសំខាន់នៅក្នុងការព្យាបាលជំងឺផ្លូវចិត្តរបស់ជនរងគ្រោះទាំងនោះ ដោយសារព្រះសង្ឃជាអ្នកអប់រំប្រដៅពុទ្ធបរិស័ទឲ្យស្គាល់ច្បាស់ពីជីវិត និងហេតុការណ៍ដែលកើតជុំវិញជីវិតរស់នៅ ពោលអប់រំឲ្យបរិស័ទរៀនទទួលយកនូវសច្ចធម៌នៅក្នុងធម្មជាតិនៃជីវិតនេះ រួចហើយឈានទៅដល់ការរៀនលះបង់ទុក្ខ ចាប់យកសេចក្តីសុខតាមបញ្ញាចក្ខុរបស់ខ្លួន ។ តាមរយៈការទេសនាអប់រំតែម្យ៉ាងពុំទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់នៅឡើយទេ តែការអប់រំជនទាំងឡាយឲ្យចេះប្រតិបត្តិនៅក្នុងព្រះធម៌ ប្រកបដោយបញ្ញា មានការធ្វើសមាធិជាដើម ទើបមានប្រសិទ្ធភាពខ្ពស់ នៅក្នុងការព្យាបាលជំងឺផ្លូវចិត្តរបស់ពួកគេ ។ ដូច្នេះព្រះសង្ឃមានតួនាទីសំខាន់នៅក្នុងកិច្ចការនេះ ។

**១១) តើព្រះតេជគុណគិតថាសុខភាពផ្លូវចិត្តអាចមើលឃើញជាក់ស្តែង និងទទួលយកបានដែរឬទេនៅក្នុងប្រទេសកម្ពុជា?**

◆ ជាធម្មតា **កាយ** និង **ចិត្ត** តែងមានទំនាក់ទំនងនឹងគ្នាដោយជិតស្និទ្ធមិនអាចកាត់ផ្តាច់បាន ដូចយ៉ាង ភ្លើង និងពន្លឺ បើកាលណាមានភ្លើង តែងមានពន្លឺ ដោយជៀសមិនផុត ។ ដូច្នេះសួរថាតើសុខភាពផ្លូវចិត្តអាចត្រូវបានមើលឃើញជាក់ស្តែង និងទទួលបានឬទេនៅពេលបច្ចុប្បន្ន សូមឆ្លើយថាយើងអាចមើលឃើញ គឺឃើញតាមរយៈការសម្តែងចេញដោយកាយវិការជាសឡាយតន (ការយល់ដឹងតាមរយៈវិញ្ញាណទាំង៦) ខាងក្រៅនៃជនទាំងពួង ។ សព្វថ្ងៃនេះ បើពិនិត្យលើសភាពជាក់ស្តែង ឃើញថាជំងឺផ្លូវចិត្តនៃជនរងគ្រោះក្នុងរបបខ្មែរក្រហមហាក់បានប្រសើរឡើងហើយ អាស្រ័យដោយពួកគេទទួលបាននូវស្ថានភាពរីកចម្រើននៃសង្គម និងសេដ្ឋកិច្ច ហើយនៅក្នុងនោះវត្តមាននៃព្រះ ពុទ្ធសាសនាក្រោយការដួលរលំទៅនៃរបបខ្មែរក្រហមក៏បាន និងកំពុងចូលរួមចំណែកក្នុងការលើកកម្ពស់ស្មារតីរបស់ជនរងគ្រោះ ។ សូមពិនិត្យមើលពីស្នាមញញឹម និងសកម្មភាពនៃជនទាំងឡាយ នៅគ្រប់តំបន់ទេសចរណ៍ និងក្នុងពេលមានពិធីបុណ្យទាំងឡាយ បង្ហាញឲ្យឃើញថាពួកគេមានសុខភាពផ្លូវចិត្តបានប្រសើរ និងគួរទទួលយកបានហើយ បើទោះជាមិនអាចលុបបោលនូវអនុស្សាវរីយ៍ដ៏ឈឺចាប់នាអំឡុងពេលនោះក៏ដោយ យ៉ាងហោចណាស់ក៏ពួកគេអាចរស់នៅដោយទទួលបានសុខច្រើនជាងការរងទុក្ខ ។ បើនិយាយតាមបរមត្ថធម៌ គ្រប់ជីវិតដែលមិនទាន់សម្រេចបានដល់នូវព្រះនិព្វាន គឺស្ថិតក្នុងសភាពជាទុក្ខទាំងអស់ គ្រាន់តែថាបើទុក្ខនោះបន្ថយបន្តិចទៅយើងក៏ហៅថា **សុខ** តាមពិតទៅវានៅតែជាទុក្ខដដែល ព្រោះជីវិតនៅក្រោមបរិនិព្វាន ជាជីវិតរស់នៅក្នុងអវិជ្ជា ។ **សូមអរគុណ!**

# រសាត់តាមខ្យល់

**(តពីលេខមុន)**



គ្រាន់តែបានដឹងថាអាសាឡន កូនប្រុសពៅរបស់គាត់ត្រូវបានពួកយោធានៅគុកវត្តជីនិតសម្លាប់ចោលហើយនោះ តាឡៅគាត់មានប្រតិកម្មយ៉ាងខ្លាំង គាត់ទប់ចិត្តពុំបានទេ ទោះជាប្រពន្ធកូនខំព្យាយាមអង្វរគាត់យ៉ាងណាក៏ដោយ គាត់បានសំលៀងកាំបិត ពូថៅដាក់ជាប់តាមខ្លួន ដើរវែករកមុខអ្នកណាជាអ្នករាយការណ៍ឲ្យគេយកកូនគាត់ទៅ ។

រំលងអាធ្រាត្រយប់មួយ ប្រធានភូមិឃ្លៃដែលទើបតែនឹងត្រូវបានចាត់តាំងថ្មីៗ ជាមួយនឹងពួកយោធាប្រដាប់ដោយកាំភ្លើងគ្រប់ដៃបួននាក់ទៀត បាននាំគ្នាឡើងទៅចាប់ខ្លួនតាឡៅ ពីលើផ្ទះ ពេលនោះតាឡៅ ប្រុងនឹងតដៃ តែត្រូវបានពួកយោធាគំរាមកំហែងថាៈ បើតាឯងហ៊ានតដៃ នឹងត្រូវសម្លាប់ចោលទាំងពូជ ។ វិនាទីបន្ទាប់នោះ តាឡៅ ត្រូវបានពួកយោធាចងបណ្ដើរចុះពីលើផ្ទះយកទៅសម្លាប់ចោលនៅឯក្រៅភូមិបាត់ទៅ ។

ក្រោយមកកម្លាំងយុវជន យុវនារីក្នុងអង្គភាពចល័តឃុំកំពុងថ្ម ត្រូវបានដកត្រឡប់មកវាលត្បែងកោងវិញ ។ នៅនឹងការដ្ឋានត្បែងកោងប្រយុទ្ធការងារដកស្ទូងបង្កបង្កើនផលមិនទាន់បានពីរសប្ដាហ៍ស្រួលបួលផង ស្រាប់តែយុវជនអ្នក១៧មេសាមួយចំនួនត្រូវបានចាត់តាំងបញ្ជូនទៅអង្គភាពថ្មីមួយ គឺអង្គភាពចល័តស្រុកសន្ទុក ។

រូបខ្ញុំក៏ស្ថិតក្នុងចំណោមយុវជនទាំងនោះដែរ ។ មិត្តសាយបានយកស្បែកជើងកង់ឡានជ៊ិនមួយគូរមកឲ្យខ្ញុំ ហើយបាននិយាយប្រាប់ខ្ញុំដោយកំបាំងតែពីរនាក់ថាៈ «ខ្ញុំជាអ្នកសម្រេចចាត់តាំងឲ្យមិត្តឯងទៅអង្គភាពចល័តស្រុកសន្ទុកឲ្យឆ្ងាយបន្តិចពីនេះ ព្រោះសភាពការណ៍សព្វថ្ងៃ កាន់តែមិនស្រួលឡើង ខ្ញុំនិយាយប៉ុណ្ណេះមិត្តឯងយល់ហើយ នៅអង្គភាពចល័តស្រុក ខ្ញុំជឿថា សភាពការណ៍ច្បាស់ជាប្រសើរជាងនៅទីនេះ ព្រោះជាអង្គភាពថ្មី អ្វីៗចាប់ផ្ដើមថ្មីទាំងអស់» ។ មួយថ្ងៃមុនពេលដែលពួកខ្ញុំត្រូវបានចេញពីការដ្ឋានត្បែងកោងទៅអង្គភាពចល័តស្រុកសន្ទុក មិត្តមឿន ជាប្រធានកងផ្ទាល់របស់ខ្ញុំ បានយកអាវទាហានប៉ារ៉ាជ្រលក់ម៉ាក់ក្លឿមួយមកឲ្យខ្ញុំដើម្បីទុកឲ្យខ្ញុំពាក់នៅខែធ្លាក់ខ្យល់រងារ គាត់នៅបានផ្ដាំផ្ញើខ្ញុំថា «មិត្តឯងខំប្រឹងតែធ្វើការទៅ គ្មានអ្នកណាធ្វើអីមិត្តឯងទេ» ។

ពេលដែលពួកខ្ញុំចេញទៅអង្គភាពចល័តស្រុកទៅ មិត្តមឿនក៏ឈប់នៅក្នុងអង្គភាពចល័តឃុំទៀតដែរ ដោយរូបគាត់ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅក្នុងអង្គភាពយោធាឃុំកំពង់ថ្មវិញ ។ នៅដើមឆ្នាំ១៩៧៨ វិទ្យុផ្សាយសំឡេងកម្ពុជាប្រជាធិបតេយ្យបានផ្សាយប្រកាសជាចំហនូវសង្គ្រាមដែលកើតមានឡើងនៅព្រំប្រទល់ខ្មែរ-វៀតណាម ។ គ្រប់បទវិចារណកថាដែលវិទ្យុបានប្រកាសផ្សាយរាល់ថ្ងៃ បានថ្លែងបរិយាយយ៉ាងច្បាស់ពីសភាពការណ៍សង្គ្រាមរំលោភឈ្លានពានទឹកដីពីសំណាក់ខ្មាំងយួន ដែលជាសត្រូវនឹងខ្មែរជាប្រវត្តិសាស្ត្រផង និងជាសម្ព័ន្ធមិត្តយ៉ាងរឹងមាំក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិនតែមួយជាមួយគ្នាផង ។ វិទ្យុកម្ពុជាប្រជាធិបតេយ្យនៅមានផ្សាយកម្មវិធីពិសេសមួយដែលមានចំណងជើងថាៈ «ភ័ស្តុតាងជាក់ស្ដែងមិនអាចប្រកែកបានរបស់ខ្មាំងយួនឈ្លានពានលេបទឹកដី» កម្មវិធីពិសេសនេះ បានចាក់ផ្សាយម្ដ៏ៗរាប់ដងពុំឈ្នះនូវចម្លើយសារភាពរបស់ចំណាប់ខ្មាំងយួន ដែលមានចាក់ផ្សាយទាំងស្រុងនូវសំឡេងដើម

ជាភាសាយួន និងមានបកប្រែជាភាសាខ្មែរផង ។

កាលពីចុងខែធ្នូឆ្នាំ១៩៧៧តទៅ វិទ្យុសំឡេងកម្ពុជាប្រជាធិបតេយ្យ ក៏បានប្រកាសផ្សាយផងដែរពីការផ្តាច់ទំនាក់ទំនងចំណងការទូតរវាងប្រទេសទាំងពីរកម្ពុជា-វៀតណាម ។

ជាមួយសភាពការណ៍ដ៏តានតឹងនៅព្រំដែននេះ តាមភូមិស្រុកក៏ដូចជានៅតាមអង្គភាពចល័តនានា អង្គការបានប្រកាសជ្រើសរើសរកយុវជន យុវនារីស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ព ដើម្បីពួតដៃរួមកម្លាំងគ្នាទៅវៃខ្ទាំងយួនឈ្លានពានលេបទឹកដី ។ អង្គការប្រកាសស្វាគមន៍ទាំងអស់ ទាំងប្រជាជនអ្នកមូលដ្ឋានទាំងប្រជាជនអ្នក១៧មេសា ។ ខ្ញុំបានទទួលដំណឹងពីការដ្ឋានត្បែងកោងមកថា មិត្ត ប៉ាច បានធ្វើជាគំរូដល់យុវជន យុវនារីទាំងអស់ក្នុងឃុំកំពង់ថ្ម ដោយមិត្តប៉ាច បានចុះឈ្មោះមុនគេបង្អស់ទៅវៃយួន ។ ចំណែកតែនៅក្នុងអង្គភាពចល័តស្រុកសន្ទុក ជាអង្គភាពស្វយ័តមួយដែលមានទីស្នាក់ការនៅចន្លោះភូមិខ្វែកឃុំកំពង់ថ្ម និងភូមិស្រែដង្កោរឃុំប្រាសាទតាមបណ្តោយទំនប់ទឹក១មករា មើលពីខ្នងទំនប់ទៅឃើញមានផ្ទះក្បឿងមួយខ្នងសង់កណ្តាលវាល និងឃើញដំបូលរោងប្រក់ស្លឹកជាច្រើនជួរសង់តម្រៀបគ្នា ។ យុវជនដែលត្រូវបានចាត់តាំងឲ្យមកការដ្ឋានអង្គភាពចល័តស្រុកជាមួយខ្ញុំ គឺសុទ្ធតែជាយុវជនអ្នក១៧មេសា មានអាវ៉ា កូនគ្រូបង្រៀនភាសាអង់គ្លេស ឈ្មោះ អ៊ុងស្បោង មកពីភូមិកំពង់ថ្ម អាកា ប្អូនជីដូនមួយរបស់បង ឆោម ឆារី កីឡាករប្រដាល់ជម្រើសជាតិមកពីភូមិឈើទាល អាទៀត កូនខ្មែរអ៊ីស្លាមមកពីភូមិទួលសង្កែ ដែលឪពុកម្តាយ និងបងប្អូនទាំងអស់របស់វានៅឯភូមិត្រូវបានអង្គការសម្លាប់ចោលអស់បាត់ទៅហើយ អាជ្រូក កូនមីងពងមាន់ មកពីភូមិឃ្លៃ និង សេង មកពីភូមិព្រៃភ្លូ ។

អង្គភាពចល័តស្រុកសន្ទុក មានប្រធានក្តាប់រួមឈ្មោះមិត្តពៅ ជាយោធា ។ មានកម្លាំងពលកម្មដែលសុទ្ធតែស្ថិតក្នុងវ័យយុវជនប្រមាណជិត២០០នាក់ ភាគច្រើនជាប្រជាជនថ្មីរួមនឹងយុវជនយុវនារីអ្នកមូលដ្ឋានចាស់ខ្លះ ដែលជាយោធារំសាយពីជួរមុខ ។ កម្លាំងពលកម្មទាំងអស់ ត្រូវបានបែងចែកជាច្រើនកង មានកងភ្ជួររាស់ដកស្ទូងបង្កបង្កើនផល ឧបត្ថម្ភអង្គភាពខ្លួនដោយខ្លួនឯង ។ ប្រធានកងទាំងអស់សុទ្ធតែជាយោធា ក្នុងអង្គភាពចល័តស្រុកសន្ទុកនេះ ការរស់នៅវិន័យ និងរបៀបរបបការងារជាវិន័យយោធា ។ អាវ៉ា ត្រូវបានគេបញ្ចូលទៅក្នុងកងភ្ជួរដែលមិត្តសឿង ជាប្រធាន នៅលីវមានវ័យចំណាស់ (ប្រហែលជា៤០ឆ្នាំ) រូបខ្ញុំ សេង និងអាទៀត ត្រូវបានបញ្ចូលទៅក្នុងកងទី១ ដែលមានមិត្តវៀម ជាប្រធាន មកពីខេត្តព្រះវិហារ អាយុប្រហែល១៨ ឬ១៩ឆ្នាំ សម្បុរសដូចមនុស្សភៀក ចូលបម្រើក្នុងជួរកងទ័ពតាំងពីនៅក្មេង ។ ឈ្មោះឪពុកម្តាយ (ឈ្មោះភូមិស្រុកមិនស្គាល់ច្បាស់) អាជ្រូក ទៅនៅក្នុងកងមិត្តឆាន អាកា ទៅនៅក្នុងកងមិត្តភ័ណ នៅមានប្រជាជនកងម្នាក់ទៀតឈ្មោះ វិន ធ្លាប់បួសអស់ជាច្រើនវស្សា ផង ។

ផ្ទះឈើប្រក់ក្បឿងគឺជាទីស្នាក់ការរបស់មិត្តពៅ សង់ប្រប នឹងមាត់ប្រឡាយ ដែលមានទឹកកំពុងហូរទៅស្រោចស្រពដីស្រែរាប់រយហិកតា រហូតដល់ស្រែអ្នកភូមិប្រាសាទ ឃុំប្រាសាទ ។ ទីស្នាក់ការរបស់មិត្តពៅ យប់ឡើងបំភ្លឺដោយភ្លើងអគ្គិសនី ដោយមានបញ្ចេះម៉ាស៊ីនភ្លើងរហូតដល់ជិតកណ្តាលអាធ្រាត្រ ។ តាសាំង ជាអ្នកភូមិកំពង់ថ្ម ត្រូវបានអង្គការចាត់តាំងឲ្យមកធ្វើការនៅរោងម៉ាស៊ីនភ្លើងនេះតាំងពីថ្ងៃបើកអង្គភាពចល័តស្រុកដំបូងម្ល៉េះ រហូតជាប់ឈ្មោះថា “ម៉ាស៊ីនភ្លើងតាសាំង ៗ” ។ មិត្តពៅ ស្នាក់នៅនឹងទីស្នាក់ការនេះទាំងយប់ទាំងថ្ងៃ ដោយមានទាំងកងយោធាស្រុកយាមការពារផង ។ នៅពីខាងក្រោយទីស្នាក់ការរបស់មិត្តពៅ មានខ្ទមសង់ពីកូនឈើប្រក់ស្លឹកត្នោត គ្មានជញ្ជាំង សង់ផុតពីដីក្រាលរនាបកូនឈើរដិបរដុបពីរជួរជារោងសម្រាបពួកយុវជន ។ ចំណែកពួកយុវនារីវិញ នៅនឹងរោងដែលសង់ចំពីមុខមន្ទីររបស់ មិត្តពៅ តែម្តងនៅត្រើយប្រឡាយម្ខាង ។ ហួសពីរោងយុវនារីបន្តិចទៅ មានរោងបាយរួមធំមួយសង់ទទឹងថ្ងៃ ដែលនៅចំពីមុខនោះមានឃ្លាំងអង្ករ អំបិល ប្រហុក សង់ជាពីរបន្ទប់ជាប់គ្នា ។ អង្គភាពចល័តស្រុកមានជង្រុកស្រូវធំពីរ មានម៉ាស៊ីនកិនស្រូវ ផលិតនៅសាធារណរដ្ឋប្រជាមានិតចិនមួយគ្រឿង ដោយឡែកនៅកងភ្ជួររាស់មានរទេះ នង្គ័ល រនាស់ មានគោ ក្របី ដែលជាកម្លាំងអូសទាញជាច្រើនក្បាលទៀតផង ។

យូរៗខ្ញុំបានជួបអាវ៉ា មកពីកងភ្ជួរម្តង វាមានវាសនាខ្ពស់ជាងពួកខ្ញុំ ដោយមិនសូវហត់នឿយដូចពួកខ្ញុំទេ ។ កម្លាំងកងភ្ជួរគ្រាន់តែត្រូវក្រោកចុះទៅភ្ជួររាស់ពីព្រឹកព្រលឹមបន្តិច ភ្ជួររាស់តែមួយព្រឹកមួយកំណាត់ថ្ងៃទៀត មើលថែទាំឃ្វាលគោ ។ ពេលពួកខ្ញុំហូបបបរពួកកងភ្ជួរហូបបាយរហូត ហើយដល់ពេលដែលពួកខ្ញុំត្រូវសម្រុកចុះ

ទៅដកសំណាបទាំងយប់ទៀត ពួកកងភ្លូររួចខ្លួន តែត្រូវភ្លូររាស់ឲ្យទាន់សម្រាប់កម្លាំងប្រយុទ្ធចុះស្ទូងតាមស្រែនាថ្ងៃបន្ទាប់ ។

មុខសញ្ញាប្រយុទ្ធការងាររទាំងកងយុវជន ទាំងកងយុវនារីមិនទៀងទាត់ទេ ជួនកាលកម្លាំងមួយចំនួន ត្រូវបែងចែកទៅកាប់គាស់ពង្រាបដីស្រែ កម្លាំងមួយចំនួនទៀតទៅលើកប្រព័ន្ធភ្លឺស្រែ និងចុះទៅសម្រុកដកស្ទូងតាមស្រែយ៉ាងប្រកិតៗគ្មានទីងកងភ្លូរ ។

សម្រុកការងាររអស់រយៈពេលដប់ថ្ងៃ យើងបានសម្រាកមួយថ្ងៃ មានពេលខ្លះដោយផែនការរបស់អង្គការមមាញឹកពេក មួយថ្ងៃនោះក៏មិនបានសម្រាកផង ។

ថ្ងៃសម្រាក ទាំងអស់គ្នាត្រូវមានវត្តមានក្នុងឱកាសប្រជុំរៀនសូត្រគោលមាគ៌ានយោបាយរបស់អង្គការបដិវត្តន៍រយៈពេលមួយព្រឹក ។ ថ្ងៃសម្រាកដូចជាថ្ងៃបុណ្យអ៊ីចឹង នៅអង្គភាពចល័តស្រុកមានរបបហូបបាយ ដល់ល្ងាចឡើងមានរបបបន្ថែមថែមទៀត ។ លុះផុតពីថ្ងៃសម្រាកទៅត្រូវចូលរបបបបរម្នាក់មួយវែក និងសម្លស្ងោរត្រកួនទឹកប្រហុកវិញ ។

តាំងពីមករួមរស់ប្រយុទ្ធការងារនៅទីងការដ្ឋានចល័តស្រុកបានប្រមាណជិតបីខែមកហើយនោះ អាជ្រូក ដេកជាប់ខាងស្តាំដៃខ្ញុំហើយ សេង ចងអង្រឹងកញ្ចាស់មួយដេកជាប់ខាងឆ្វេងដៃខ្ញុំ ខ្ញុំដេកកណ្តាលផ្ទាល់ និងរនាបឈើខ្លួនកម្រើកសឹងពុំរួច អាទៀត ដេកជាប់អាជ្រូក រំលងពីនោះបន្តិចមិត្តរៀមដេកនឹងអង្រឹងខាងចុងរោងដេកជាប់នឹងអង្រឹង មិត្តរៀម កូនខ្មែរអ៊ីស្លាមម្នាក់ទៀតនៅក្នុងកងជាមួយខ្ញុំដែលឈ្មោះអាហៀត មកពីឃុំប្រាសាទដែលឪពុក ម្តាយនិងបងប្អូនត្រូវបានអង្គការយកទៅសម្លាប់ចោលអស់ ។ ក្នុងអង្គភាពចល័តស្រុកទាំងមូល មានបងប្អូនខ្មែរអ៊ីស្លាមពីរនាក់ទៀត ម្នាក់ឈ្មោះអាយ៉ាមកពីឃុំកកោះ និងយុវនារីម្នាក់ឈ្មោះស្រស់ មកពីឃុំតាំងក្រសាំងដែលឪពុកម្តាយ និងបងប្អូនត្រូវបានអង្គការយកទៅសម្លាប់ចោលអស់ទៅហើយដែរ ។ ពេលនោះខ្ញុំបានសង្កេតឃើញច្បាស់ថា បន្ទាប់ពីផែនការបោសសំអាតពួកក្បត់នឹងអង្គការ និងពួករនុកក្នុងយួនបងប្អូនខ្មែរអ៊ីស្លាមដ៏ស្លូតត្រង់បានក្លាយទៅជាទិសដៅសម្លាប់បំផុតពូជរបស់អង្គការបដិវត្តន៍ដ៏មហិមា ។

ដោយដេកផ្ទាល់នឹងរនាបកូនឈើ ដែលត្រូវបានខ្ទូតស៊ីផុះសុសឡើងហុយទ្រលោមជាមួយនឹងខោអាវតែមួយបន្លាស់ហើយត្រូវសើមស្អួតៗរាល់យប់ថ្ងៃនោះ អាជ្រូក កើតចៃសាច់រមាស់អេះគ្មានបានដេកបានពួនអីទេ ។ ជាញឹកញយ អាជ្រូក បានអេះបង្ហាញខ្ញុំ មួយជីវិតរបស់ខ្ញុំមិនដែលបានឃើញទេ ទើបតែពេលនេះ កប់សើៗ នៅនឹងស្បែករបស់វា ខ្ញុំឃើញមានចៃពណ៌សតូចៗរស់រវើកមើលទៅគួរឲ្យព្រឺខ្លួន ។

ខ្ញុំខ្លួនឯងក៏កើតរមាស់ដែរ តែជំងឺរមាស់របស់ខ្ញុំគឺរមាស់ខ្ទោមុខ ខ្ញុំរមាស់ខ្លាំងណាស់ អេះដាច់សាច់ដំបៅ សព្វខ្លួនទាំងអស់ គ្មានសេសសល់កន្លែងណាទេអេះឆ្ងាញ់ដៃណាស់ ។ ជំរាបឲ្យអស់កេរ្តិ៍ខ្មាសទៅ សូម្បីតែអង្គជាតិបន្តពូជរបស់ខ្ញុំ ក៏ត្រូវបានរមាស់ខ្ទោមុខរាតត្បាតសព្វកៀនកោះទាំងអស់ ។ ក្រោយមកខ្ញុំត្រូវបានមិត្ត រៀមបញ្ជូនឲ្យទៅសម្រាកនៅមន្ទីរពេទ្យ ។

អង្គភាពចល័តស្រុកសន្ទុក មានមន្ទីរពេទ្យសម្រាប់អង្គភាពផ្ទាល់ សង់នៅកណ្តាលទ្រូងព្រៃជ្រៅឆ្ងាយពីមន្ទីរមិត្តពៅ ប្រមាណបីបួនរយម៉ែត្រ ។ អ្នកជំងឺត្រូវបានមិត្តនារីពេទ្យពីរនាក់មកព្យាបាលដល់ខ្ទម បើឈឺធ្ងន់នឹងត្រូវបានបញ្ជូនទៅសម្រាកនៅមន្ទីរពេទ្យ អ្នកជំងឺពីអង្គភាពចល័តឃុំប្រាសាទដែលនៅក្បែរនោះក៏ត្រូវបានបញ្ជូនទៅព្យាបាលជុំគ្នានៅនឹងមន្ទីរពេទ្យអង្គភាពចល័តស្រុកនេះដែរ ។

មន្ទីរពេទ្យចល័តស្រុក គ្រប់គ្រងដោយមិត្តប៊ិន ជាប្រធាន មិត្តហេន ជាអនុប្រធានមានពេទ្យនារីពីរនាក់ ដែលជាអ្នកស្រុកតាំងក្រសៅដូចគ្នា ។ មិត្តយ៉ុម ក្នុងវ័យប្រហែល២២ឆ្នាំ សម្បុរខ្មៅស្រអែម កាត់សក់ខ្លី និងនារីពេទ្យម្នាក់ទៀតឈ្មោះមិត្តសេងអាយុប្រហែល១៨ឆ្នាំ សម្បុរសស្អាតទំនងបែបជាកូនចៅកាត់ចិន ។ នៅមានកុមារពេទ្យពីរនាក់ទៀត ដែលនៅធ្វើការជាប្រចាំនៅក្នុងមន្ទីរពេទ្យនេះដែរ គឺ មិត្តខ្ញុំ អ្នកស្រុកតាំងក្រសៅ មានអាយុយ៉ាងច្រើន១៧ឆ្នាំ ធាត់ទាប សម្បុរខ្មៅរលោង និងមិត្តថន អាយុប្រហែល១៣ឆ្នាំ មានសម្បុរជ្រះជាងមិត្តខ្ញុំបន្តិច មាឌធាត់ក្រអាញរាងទាបដូចគ្នា ។

ក្នុងមន្ទីរពេទ្យ ខ្ញុំត្រូវបានសម្រាកព្យាបាលនៅនឹងរោងវែងមួយ ដែលមានអ្នកជំងឺប្រមាណជិត២០នាក់ ក្នុងនោះមានយុវជនតែបីបួននាក់ទេ ភាគច្រើនជាអ្នកជំងឺស្ថិតក្នុងវ័យកណ្តាលដែលត្រូវបានបញ្ជូនមកពីអង្គភាពចល័តឃុំប្រាសាទ ។ ចំណែកអ្នកជំងឺនារីៗវិញ សំណាក់នៅនឹងរោងមួយឆ្ងាយពីរោងយុវជនបន្តិច ហើយត្រូវ

មកហូបបបររួមនៅនឹងខ្ទមចុងភៅជាប់នឹងមាត់អូរតូចមួយ ។

តាំងពីរថ្ងៃមកដល់មន្ទីរពេទ្យដំបូង មិត្តខ្ញុំ និងមិត្តថន បានមកព្យាបាលជំងឺរបស់ខ្មៅមុខឲ្យខ្ញុំ ដោយនាំខ្ញុំដើរចូលទៅក្នុងព្រៃឆ្ងាយពីខ្ទម មកដល់កន្លែងមួយមានដុះកូនឈើល្បោះៗស្រឡះបន្តិច កូនពេទ្យទាំងពីរនាក់បានប្រាប់ខ្ញុំឲ្យដោះខោអាវចេញនៅតែខ្លួនទទេស្រាតនននល ។

មិត្តថន នៅនឹងដៃមានកាន់កូនចានជ្រៅមួយ ដែលមានថ្នាំម្សៅម្យ៉ាងពណ៌ស្វាយកូរលាយជាមួយទឹកជាស្រេច មិត្តខ្ញុំ ចាប់យកសំឡីមកគាបនឹងកន្ត្រៃពេទ្យ រួចជ្រលក់ទៅនឹងទឹកចានថ្នាំយកមកលាបសព្វអវៈយវៈខ្ញុំទាំងខាងមុខ និងខាងក្រោយ ពេលលាបមកដល់វត្ថុបុរាណខ្ញុំ មិត្តខ្ញុំ បែបមិនសូវស្និទ្ធ ក៏ប្រើមិត្តថន ឲ្យទៅកាច់មែកឈើមួយកំណាត់យកមកឆ្កឹះ ។

មិត្តថន ជាអ្នកឆ្កឹះបង្ហិលចុះឡើង ដើម្បីឲ្យមិត្តខ្ញុំ ស្រួលលាបថ្នាំ ។ ឆ្កឹះមួយជុំហើយមួយជុំទៀត លាបថ្នាំបណ្តើរអាកូនពេទ្យទាំងពីរនាំគ្នាអស់សំណើច សើចកាច់កកាច់ស្រងំបណ្តើរ ។ ខ្ញុំនឹកក្នុងចិត្តថា អាកូនពេទ្យពីរនាក់នេះអត់មានស្អីលេងយករបស់ឯងលេងជាល្បែងហើយតើ...ម្តងៗខ្ញុំនឹកចង់តែខោកក្បាលវាទាំងពីរឲ្យពក តែខ្លាចរំពាត់នៅនឹងដៃមិត្តថន បើសិនមិត្តថន វាត់តែមួយខ្វាប់មក ខ្ញុំមិនដឹងជាប្រកាច់ប្រកិនដល់ណាទេ ។

លាបថ្នាំរួច ខ្ញុំត្រូវឈរសំដិលមើលព្រៃព្រឹក្សារហូតស្ងួតថ្នាំទើបស្លៀកពាក់នាំគ្នាដើរត្រឡប់មកខ្ទមវិញ ។ លុះដល់ពេលល្ងាចឡើងខ្ញុំត្រូវចុះទៅងូតទឹកប្រឡាយ ដោយយកខ្សាច់បាតប្រឡាយមកដុះសព្វខ្លួនទាំងអស់ កន្លែងដែលរមាស់ដុះនឹងដីខ្សាច់រហូតចេញឈាម ហើយលាបថ្នាំសាជាថ្មីទៀត ។

សម្រាកព្យាបាលនៅនឹងមន្ទីរពេទ្យអស់រយៈពេលជិតពីរសប្តាហ៍នេះ ខ្ញុំបានស្គាល់ពួៗវ័យកណ្តាលជាច្រើននាក់ និងយុវជនអ្នកថ្មីម្នាក់ឈ្មោះអាពន្លក មកពីភូមិប្រាសាទ ឃុំប្រាសាទ អាពន្លកមានស្រុកកំណើតនៅភូមិចុងកោះអណ្តែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ឪពុកវាជាគ្រូបង្រៀន ខ្ញុំ និងអាពន្លក បានរាប់អានគ្នាជាមិត្ត ។

ល្ងាចៗឡើង ពេលចែករបបឲ្យអ្នកជំងឺហូបរួចហើយ មិត្តយ៉ុម និងមិត្តសេង តែងតែនាំគ្នាទៅងូតទឹកអណ្តូងដៃមួយក្បែរនោះដែលមានទឹកដ៏ថ្លាឈ្វេង ក្រោមម្លប់ដើមគគីមួយដើមយ៉ាងធំ ។

ពេលដែលបានឃើញមិត្តនារីពេទ្យទាំងពីរនាក់បណ្តើរគ្នាទៅងូតទឹក ពួៗនៅក្នុងខ្ទមចាប់ផ្តើមជ្រួលជ្រើម ប្រប៉ូកប្រប៉ល់ដូចជា "អត់របប" ខ្លាំងណាស់ ។ មិត្តយ៉ុម និងមិត្តសេង ចោមពុងងូតទឹកនឹងក្រមាអំបោះស្តើង ពេលទទឹកសើមជោគក្រមាបឺតស្អិតជាប់នឹងសាច់ត្រគាកដ៏សែនសមមូលក្បំ ជួនកាលមិត្តយ៉ុម និងមិត្តសេង បែរមុខបង្ហាញឲ្យឃើញសាច់ទ្រូងដ៏សក្បុសម៉ដ្ឋខៃដូចសំឡីលំអរដោយសុដន់ទាំងគូមូលណែនតូចប៉ុនដៃទន្លាប់ ។

កណ្តាលទ្រូងព្រៃ នាពេលសាយ័ន្តសម័យលាយឡំនឹងសំឡេងរៃយំល្វើយៗពីចុងព្រឹក្សា ពួៗប្រជ្រៀតដណ្តើមគ្នាលួចបង្ហើបជញ្ជាំងខ្ទមលបមើលដោយអារម្មណ៍រំភើបស្រើបស្រាល សម្រាប់ពួកគាត់វាហាក់ដូចជាចំណីនេត្រាយ៉ាងត្រេកត្រអាលដែលពួកគាត់បានឃើញហើយ មិនចង់ឲ្យឃ្លាតទៅណា ។

នៅនឹងមន្ទីរពេទ្យ អាពន្លក បានសូមឲ្យខ្ញុំជួយកាត់សក់ឲ្យវា ព្រោះសក់ក្បាលវាកំពុងតែត្រូវចៃរុករានសម្បើមណាស់ ខ្ញុំបានបដិសេធន៍ដោយបានប្រាប់វាវិញថា ខ្ញុំអត់ចេះកាត់សក់ទេ តែអាពន្លកនៅតែហុចកន្ត្រៃមកឲ្យខ្ញុំដោយពោលមកកាន់ខ្ញុំទៀតថា កាត់យ៉ាងម៉េចក៏បានដែរឲ្យតែខ្លីៗទៅ ។ បងប្រុសម្នាក់ដែលសម្រាកព្យាបាលដៃក្នុងមន្ទីពេទ្យនេះដែរ ដោយដៃរបស់គាត់ត្រូវរបួសដាច់ម្រាមមេដៃមួយក្នុងពេលកាប់ត្រីនៅឯស្រែ ក្រោមឈ្មោះបងនួ មានដើមកំណើតនៅភូមិកណ្តាលកោះអណ្តែត ជាអ្នកធានាសម្លៀងកន្ត្រៃ និងកាំបិទកោរឲ្យខ្ញុំ ។

កាត់សក់ឲ្យអាពន្លករួចហើយ កាត់ឲ្យពួៗបន្តបន្ទាប់គ្នាទៀតក្នុងរយៈពេលតែប៉ុន្មានថ្ងៃ អ្នកជំងឺក្នុងខ្ទមជាមួយ ត្រូវបានខ្ញុំកាត់សក់ឲ្យទាំងអស់គ្នា ចុងក្រោយខ្ញុំបានកាត់សក់ឲ្យមិត្តប៊ិន មិត្តហេន ហើយអាកូនពេទ្យទាំងពីរនាក់ក៏ត្រូវបានខ្ញុំកាត់សក់ឲ្យដែរ ។ ដោយជំងឺសើស្បែករបស់ខ្ញុំកាន់តែជិតបានជាសះស្បើយហើយនោះ ជាញឹកញយមិត្តខ្ញុំ និងមិត្តថន បានមកហៅខ្ញុំឲ្យទៅជួយសែងភស្តុភារមានអង្ករ ប្រហុក ត្រីងៀត ត្រីឆ្អើរពីទូកនៅឯមាត់ស្ទឹងដែលបានដឹកមកពីមន្ទីរភស្តុភារស្រុកតាំងក្រសាំងសម្រាបផ្គត់ផ្គង់អ្នកជំងឺនៅមន្ទីរពេទ្យ ។

ពេលសែងភស្តុភារមកមន្ទីរពេទ្យវិញ តាមបណ្តោយមាត់ប្រឡាយដែលមានព្រៃយ៉ាងក្រាសអមទាំងសងខាង មិត្តថន និងមិត្ត

ខ្ញុំ នៅបានលួចទម្លាក់ត្រីងៀត ដូនប្រហុកត្រីឆ្អើរលាក់ក្នុងគុម្ពោតព្រៃ ទុកឲ្យខ្ញុំ លុះដល់ពេលព្រលប់ទើបឲ្យខ្ញុំដើរមកយកទៅចែកគ្នាហូបនៅឯខ្ទម ។

ថ្ងៃមួយពេលហូបរបបថ្ងៃត្រង់រួច ស្រាប់តែជាចៃដន្យបំផុត ខ្ញុំបានជួបមិត្តនារីរួមថ្នាក់ខ្ញុំម្នាក់កំពុងតែឈរលាងចានស្ងាបព្រាក្នុងអូរជាប់នឹងខ្ញុំ ។ ខ្ញុំមើលនាងពុំស្គាល់ទេ ដោយនាងឃ្មុំនឹងក្រមាជិតសល់តែប្រឡោះមុខបន្តិចប៉ុនសំបុកចាប នាងឈ្មោះខ្វត បុប្ផារស្មី ជាចៅបង្កើតរបស់លោកស័ក្តិប្រាំ ខ្វត ប៊ុត ។ កាលនៅរៀនឯវិទ្យាល័យក្នុងវ័យ១៥-១៦ឆ្នាំ រស្មីបើកឡានមីនីអូស្តាំងពណ៌ប្រផេះមួយគ្រឿងទៅរៀនដោយខ្លួនឯង ។

រស្មីបានប្រាប់ខ្ញុំថា សព្វថ្ងៃនាងរស់នៅតែម្នាក់ឯងគត់នៅនឹងភូមិប្រាសាទ ឃុំប្រាសាទរំលងតែភូមិបន្ទាយយមរាជមួយ ជាប់គ្នានឹងភូមិព្រៃភ្លូ ឃុំកំពង់ថ្ម ។ ម្តាយនាងជាប់នៅឯស្រុកបារាំង ប្អូនស្រី និងប្អូនប្រុសម្នាក់ទៀត បែកគ្នាតាំងពីថ្ងៃដាច់ភ្នំពេញ ។ រស្មីបានមកសម្រាកនៅមន្ទីរពេទ្យចល័តស្រុកនេះជិតមួយខែមកហើយដូចខ្ញុំដែរ តែយើងម៉េចក៏មិនប្រទះភ្នែកឃើញគ្នាសោះ ។

រស្មី គឺជាមិត្តរួមថ្នាក់ទីពីរហើយដែលខ្ញុំបានជួបបន្ទាប់ពី អានួកនៅឯភូមិទួលសង្កែ ។ ពេលបានជួបរស្មី ខ្ញុំមានអារម្មណ៍យ៉ាងត្រេកអរ ដែលថ្ងៃបន្តបន្ទាប់ពីនោះមកទៀត បានធ្វើឲ្យខ្ញុំនឹករលឹក និងគិតដល់វាសនាមិត្តរួមថ្នាក់ និងមិត្តភក្តិរួមវិទ្យាល័យផ្សេងខ្លះទៀតដែលជាកូនមន្ត្រីថ្នាក់ខ្ពស់ៗ និងកូននាយទាហានធំៗក្នុងជួររាជរដ្ឋាភិបាល ។

រៀននៅក្នុងថ្នាក់ជាមួយខ្ញុំផ្ទាល់មានកូនប្រុសលោក ដែង ឡាវយ៉ុម ជាអគ្គមេបញ្ជាការកងទ័ពរថក្រោះ ឈ្មោះ ដែង ឡាវរិទ្ធី និងកូនស្រីម្នាក់ទៀតឈ្មោះ ដែង ឡាវវតី កូនប្រុសលោកស័ក្តិ៥ ណុប ឆុំ ឈ្មោះ ណុប អារុណរះ កូនស្រីលោកឧត្តមមន្ត្រី គុយ គង់ ឈ្មោះ គុយ សុផល្លី នាងមានបងប្អូនស្រីពីរនាក់ទៀត រៀនក្នុងវិទ្យាល័យជាមួយគ្នាដែរ នាងគុយ សុផល្លី មានសម្រស់ស្អាតណាស់ ស្អាតដាច់គេក្នុងចំណោមយុវសិស្សនារីទាំងអស់ក្នុងវិទ្យាល័យ (នាងបានជាប់ឈ្មោះជាបុប្ផាវិទ្យាល័យទួលស្វាយព្រៃ) ។

លោកឧត្តមមន្ត្រី ឧប គឹមអាង ក៏មានកូនស្រីម្នាក់រៀននៅវិទ្យាល័យជាមួយខ្ញុំដែរឈ្មោះនាង ឧប ស្រីពៅ បើកឡានមីនីកាទៅរៀនដោយខ្លួនឯង កូនស្រីពៅរបស់លោកឧត្តមសេនីយ៍ទោ កេង ឈ្មោះនាង កេង កូណាគ្រី ដែលមានកូនទាហានបើកឡានឡង់រ៉ូវែរជូនទៅមករាល់ថ្ងៃ កូនស្រីលោកវេជ្ជបណ្ឌិត យឹម យិន ឈ្មោះនាង យឹម សារ៉ូ កូនប្រុសលោកស័ក្តិ៥ ហាំ ឈួន ពីរនាក់ឈ្មោះ ហាំ ឈួនថាវរី និងម្នាក់ទៀតឈ្មោះ ហាំ ឈួនដារារិទ្ធី កូនស្រីលោកស័ក្តិ៥ ហ៊ុល ហៃល ឈ្មោះនាង ហ៊ុល សមុទ្រធីតា កូនស្រីលោកស័ក្តិ៥ ប៉េអឹម សន សាន្ត ឈ្មោះនាង សន ណារ៉ាន់ កូនប្រុសលោកទឹម សារិ ជាឧត្តមមន្ត្រីចូលនិវត្តន៍ឈ្មោះ ទឹម សេណាវុធ និងកូនស្រីលោក ឈាន ប៊ុនហៃ មេបញ្ជាការទ័ពម៉ារីនឈ្មោះនាង ឈាង បុប្ផាជាតិ ជាដើម ។

រស្មី នាងប្រហែលជាចេញពីមន្ទីរពេទ្យមុនខ្ញុំ ថ្ងៃដែលខ្ញុំបានជួបនាងជាចុងក្រោយ នៅនឹងមាត់អូរដដែល នាងបានទម្លាក់កូនសំបុត្រមួយទុកឲ្យខ្ញុំ សំបុត្រនាងមានសេចក្តីយ៉ាងខ្លីថា៖ «សូមពួកម៉ាកថែរក្សាខ្លួនឲ្យបានល្អ និងជួបតែនឹងជោគវាសនាល្អបំផុតក្នុងលោក» ។ សំបុត្ររបស់រស្មី ខ្ញុំបានរក្សាទុករហូតមក ។

ប្រហែលជាកន្លះខែក្រោយមកបន្ទាប់ពីខ្ញុំបានត្រឡប់មកកាន់ការដ្ឋានវិញ មន្ទីរពេទ្យចល័តស្រុកសន្ទុក ត្រូវបានរំសាយ ។ មិត្តប៊ិន ត្រូវបានទៅធ្វើជាប្រធានមន្ទីរពេទ្យស្រុកតាំងក្រសាំង ដែលមាននារីពេទ្យចំណាស់ម្នាក់ឈ្មោះមិត្ត សយ ជាអនុប្រធាន មិត្តហេន មិត្តយ៉ុម មិត្តសេង និងមិត្តខ្ញុំ ក៏ត្រូវទៅធ្វើការនៅមន្ទីរពេទ្យស្រុកដែរ ចំណែកមិត្តថន ត្រូវបានត្រឡប់ទៅភូមិវិញ ទៅធ្វើការនៅមន្ទីរពេទ្យឃុំកកោះ ។

នៅនឹងអង្គភាពចល័តស្រុក មានកើតហេតុការណ៍ដ៏គួរឲ្យភ្ញាក់ផ្អើលមួយ ជាមួយនឹងដំណឹងចាប់ខ្លួនមិត្តពៅ ដែលកំពុងតែមានប្រជាប្រិយភាពយ៉ាងខ្លាំង ជាពិសេសក្នុងចំណោមពួកនារីៗអ្នកមូលដ្ឋានចាស់ៗ មិត្តពៅ ត្រូវបានអង្គការហៅឲ្យទៅចូលរួមប្រជុំនៅមន្ទីរស្រុក ។ ក្រោយពីចាប់ខ្លួន មិត្តពៅ រួចមក ទើបបានលេចឮដំណឹងថា មិត្តពៅ ជាខ្សែរយៈរបស់មិត្តចន គណៈតំបន់៤៣ ក្បត់ ។

មិត្តសឿង ប្រធានកងភ្ជួរ ត្រូវបានចាត់តាំងជាប្រធានអង្គភាពចល័តស្រុកសន្ទុកបណ្តោះអាសន្ន មិត្តសឿង ទទួលមុខតំណែងថ្មីទាំងបង្ខំចិត្ត ហើយមិត្តវិន (ហៅអង្គិតវិន) ត្រូវបានទៅធ្វើជាប្រធានកងភ្ជួរជំនួសមិត្តសឿង វិញ ។

ប៉ុន្មានថ្ងៃក្រោយមក នៅនឹងអង្គភាពចល័តស្រុក ស្រាប់តែ

*ឃើញមានវត្តមានអ្នក១៧ មេសាចំនួន៥ នាក់ទៀតដែលទើបតែនឹងបានបញ្ជូនមកពីឃុំកំពង់ថ្ម មានបងនឿន មកពីឃុំខ្វែក នៃ យ៉ា ក្មេងជាងគេនៅក្នុងចំណោមនោះដែលមានអាយុប្រហែលដប់ពីរឆ្នាំ (ជាកូនប្រុសពៅរបស់លោកស័ក្តិប្រាំត្រកូលថាច់) មកពីភូមិព្រៃក្ដូ អាបុង និងស្រីមុំ ជាប្អូនអាណោ មកពីភូមិកងសៅ ។ អ្នកមកដល់ថ្មីត្រូវបានគេបញ្ចូលតាមកងភ្លាមៗ អាបុង និងនៃ យ៉ា ត្រូវបានបញ្ចូលនៅក្នុងកងមិត្តឆាន ស្រីមុំ និងតារាស៊ីន ត្រូវបានបញ្ចូលទៅក្នុងកងយុវនារីដែលមានប្អូនស្រីបង្កើតរបស់បងហៀង ធ្វើជាប្រធានកង ។*

*ពេលយប់ងងឹតឡើង យើងមិនដែលហ៊ានជជែកគ្នាទេ ព្រោះខ្លាចជញ្ជាំងមានត្រចៀក ម៉្យាងមិត្តរៀម ដេក នឹងអង្រឹងក្បែរនោះផង តែរាល់ពេលទៅដល់កន្លែងធ្វើការកាប់គាស់ពង្រាបដីប្ដុចុះស្រែដកស្ទូង សេងចុះជាប់នឹងខ្ញុំរហូត ។ សេងជាកូនសិស្សរៀនថ្នាក់ទី៧ទំនើបជាតិនៃវិទ្យាល័យ១៨ មីនា កាលនៅភ្នំពេញ ផ្ទះសេង នៅម្ដុំផ្សារដើមអំពិលមុខសាលាបឋមសិក្សាអង្គអេង សេង មានចរិតស្លូតបំផុតមិនសូវនិយាយស្ដីតែកំប៉ុកកំប្លែង ។*

*ខ្ញុំ និងសេង នាំគ្នាជជែកតែពីរឿង «សង្គមចាស់» រឿងកាលពីនៅរៀន រឿងទៅមើលល្ខោន មើលកុនកាប់ដាវ កុនការ៉ាតេ ។ ពេលខ្លះសេងនិយាយរឿងកុនឲ្យខ្ញុំស្ដាប់ចប់ៗមួយរឿង ដែលទំរាំតែនឹងបានចប់ត្រូវចំណាយពេលអស់ជាច្រើនថ្ងៃ ។ ខ្ញុំនៅចាំរឿងចុងក្រោយដែល សេង និយាយឲ្យខ្ញុំស្ដាប់ គឺរឿងស្នេហាស្រុកស្រែ ។ រឿងសំខាន់មួយទៀតដែលខ្ញុំនិងសេងជជែកគ្នាមិនដែលខាននោះ គឺរឿង «ហូបខ្យល់» ដែលធ្វើឲ្យយើងបានទទួលអារម្មណ៍ឆ្ងាញ់ឃ្លានស្រក់ទឹកមាត់ ។ កាលនៅភ្នំពេញ ពេលល្ងាចចេញពីសាលារៀន សេងទៅក្លឹបហាត់ការ៉ាតេ ចេញពីក្លឹបមកវិញ សេង មិនទាន់ទៅផ្ទះវិញភ្លាមៗទេ សេង ចូលទៅមុខរោងកុនគិរីរម្យរកគុយទាវប្រហិតសាច់គោសិន ពេលគេលើកគុយទាវមកក្ដៅៗហុយៗ ទឹកស៊ុបចោលក្លិនឈ្ងុយឆ្ងាញ់ណាស់ មានល្ងាចខ្លះទៀត គុយទាវប្រហិតមួយចាន បែបស៊ើរ សេង ថែមនំប៉័ងប៉ាតេជ្រក់ល្ហុងមួយកំណាត់ទៀត ។*

*កងមិត្តឆាន ក៏សម្រាកក្នុងខ្ទមជាមួយខ្ញុំដែរ ថ្ងៃមួយខ្ញុំបានទទួលដំណឹងតាមរយៈអាបុង ថា អាណោ បងប្រុសវាត្រូវអង្គការចាប់យកទៅសម្លាប់បាត់ហើយ នៅសល់តែម្ដាយវាម្នាក់រស់នៅភូមិក្លាយទៅជាមនុស្សស៊ើរឆ្កួត ស៊ើរជា ។ នៃ យ៉ា ក៏បានបង្ហើបប្រាប់ខ្ញុំថា ឪពុកម្ដាយ និងបងស្រីវា សុរិយា ក៏ត្រូវបានអង្គការចាប់យកទៅសម្លាប់អស់ហើយ ។ រៀបរាប់ប្រាប់ខ្ញុំបណ្ដើរ នៃ យ៉ា ស្រក់ទឹកភ្នែកបណ្ដើរ ហើយបន្តទៀតថាៈ «ខ្លួនខ្ញុំមិនដឹងជាថ្ងៃណាទេ» ។*

*ជារៀងរាល់ថ្ងៃយើងនាំគ្នាទៅធ្វើការធម្មតា ទោះជាសភាពការណ៍ជុំវិញទាំងនៅភូមិឃុំ ទាំងនៅការដ្ឋានចល័តមានសភាពដូចជាមិនធម្មតាក៏ដោយ ។ ថ្ងៃខ្លះ ខ្ញុំបានចុះទៅដល់ស្រែកំពុងតែកាប់គាស់ដំបូកពង្រាបដីបានមួយកំណាត់ដំបូក ក៏ត្រូវបានប្រធានកងហៅឲ្យត្រឡប់ទៅខ្ទមវិញ ដើម្បីទៅកាត់សក់ឲ្យពួកគេ ព្រោះដើងសក់ពួកមិត្តប្រធានកងទាំងបួនប្រាំនាក់នោះត្រូវថ្មីរហូត ។*

*ព្រឹកថ្ងៃមួយពេលដែលខ្ញុំបានត្រឡប់មកដល់ខ្ទមវិញ ដើម្បីកាត់សក់ឲ្យមិត្តឆាន ស្រាប់តែខ្ញុំបានឃើញមិត្តឆាន ដើរតម្រង់ទៅរកអាបុង ដែលកំពុងតែដេកនៅឯចុងរោងទៅដល់ មិត្តឆាន បានស្រែកយ៉ាងខ្លាំងៗថាៈ «មិត្តបុង ក្រោកឡើងទៅធ្វើការ» ខ្ញុំបានឃើញអាបុង គ្រាន់តែងើបបង្ហើបក្បាលបន្តិចរួចក៏សម្ងំដេកទៅវិញ ឃើញដូច្នោះ មិត្តឆាន ជ្រួញចិញ្ចើមស្រែកសាជាថ្មី «មិត្តឯងឮខ្ញុំប្រាប់ឲ្យក្រោកទៅធ្វើការទេ? មិត្តឯងនៅដេកដល់ណាទៀត?» ។*

*ខ្ញុំស្រឡាំងកាំងគ្រាដែលបានឮអាបុង វាតបទៅមិត្តឆាន វិញថាៈ «ខ្ញុំមិនក្រោកទេ មិនដែលមានអាណាធ្វើការមិនដឹងពេលដេកពេលពួនអីចឹងទេ!» ។ និយាយរួចអាបុង ក៏យកដៃខ្ទប់ត្រចៀកទាំងសងខាង ហាក់ដូចជាធុញថប់ មិត្តឆាន ស្រែកទៅអាបុងវិញថាៈ «មនុស្សខ្ជិលរឹងទទឹងដូចមិត្តឯងទុកនៅក៏មិនចំណេញ ដកចេញក៏មិនខាតដែរ» ។ គ្រាន់តែបានឮមិត្តឆាន ពោលដូច្នេះ អាបុង ប្រឡោតតូងស្រែកខ្លាំងតបទៅវិញថាៈ «យកអញទៅវៃចោលទៅ! អញមិនចេះរស់នៅក្នុងរបបសាហាវឃោរឃៅរបស់ពួកអ្ហែងទេ នៅស្រុកគេ គេមានម៉ោងធ្វើការ មានម៉ោងសម្រាក ម៉ោងដេក ជីវិតមនុស្សម្នាក់ៗមានតម្លៃខ្លាំងណាស់ ក្នុងរបបពួកអ្ហែងជីវិតមនុស្សមិនបានស្មើ និងសត្វធាតុផង ពួកអ្ហែងសម្លាប់ម៉ែឪបងប្អូនអញអស់ហើយ ទុកអញធ្វើអីទៀត?» ។*

*ខ្ញុំនឹកភ័យជំនួសអាបុង ហើយមុនពេលដែលមិត្តឆាន ដើរចេញទៅ មិត្តឆាន បានបោះសំដីឲ្យ អាបុង ថា ៈ «បើមិត្តឯងចង់ងាប់ គង់តែបានងាប់ ក្បាលមិត្តឯងច្បាស់ជាគេចមិនផុតពីត្បូងចបទេ» ។ នាថ្ងៃបន្ទាប់ពេលដែលយើងឡើងពីស្រែមកហូបបាយថ្ងៃត្រង់វិញ ខ្ញុំ*

អត់ឃើញអាបុង នៅនឹងខ្ទមទៀតទេ បង្វេចអីវ៉ាន់របស់វាក៏មិនឃើញ ពេលដែលខ្ញុំដើរទៅកាន់រោងបាយ ស្រាប់តែខ្ញុំបានឃើញយោធាពីរនាក់ស្ពាយកាំភ្លើងនៅនឹងស្មា បណ្តើរអាបុង ចុះពីមន្ទីរមិត្តសឿង យកទៅឲ្យកាប់ដំបូកធំមួយដែលស្ថិតនៅឆ្ងាយបន្តិចពីមន្ទីរ ។

ស្អែកឡើងខ្ញុំនៅបានឃើញអាបុង ឈរកាប់ដំដូកដដែល ខ្ញុំចោលភ្នែកក្រឡេកមើលវាដោយក្តីអាណិតអាសូរ ។ ពីរថ្ងៃមកហើយនេះ កុំថាឡើយអាហារ សូម្បីតែទឹកមួយដំណក់ក៏ពួកយោធាមិនឲ្យអាបុង ផឹកផង ។ ព្រលប់ថ្ងៃដដែលនោះអាបុង ត្រូវពួកយោធាយកទៅសម្លាប់ចោលបាត់ទៅ ។ នៅនឹងអង្គភាពចល័តស្រុក អាពន្លកឧស្សាហ៍មកលេងនឹងខ្ញុំណាស់ ជាពិសេសថ្ងៃសម្រាកកន្លះថ្ងៃ អាពន្លកនៅបាននាំមិត្តភក្តិដែលជាយុវជនអ្នកថ្មីមានវ័យប្រហាក់ប្រហែលគ្នាបីបួននាក់ឡើងមកណែនាំឲ្យខ្ញុំស្គាល់ មានអា ស្រ៊ុន មកពីភូមិប្រាសាទ អាផុន មានអាយុបងខ្ញុំប្រហែលពីរឆ្នាំ (ខ្ញុំហៅ«ល្បងផុនៗ») និងប្អូនប្រុសល្បងផុន ម្នាក់ទៀតឈ្មោះផាន នៅភូមិស្រែដង្កោរ អាឡឿន និងអាឆ្លួន នៅភូមិបន្ទាយយមរាជ ។ ខ្ញុំពុំដែលបានទៅលេងពួកវាដល់អង្គភាពចល័តឃុំប្រាសាទម្តងណាទេ តែអាស្រ៊ុន អាពន្លក ល្បងផុន បាននាំខ្ញុំទៅដល់ភូមិ ហើយណែនាំឲ្យខ្ញុំបានស្គាល់ឪពុកម្តាយ និងបងប្អូនវាទាំងអស់គ្នា ។ ជាមួយនឹងផែនការ «ដឹកស្មៅត្រូវដឹកទាំងឫស» របស់អង្គការដែលបានសម្លាប់ប្រជាជនថ្មីទាំងគ្រួសារៗតាមភូមិរួចហើយអង្គការនៅតាមរកកម្ទេចអ្នកដែលនៅសល់តាមអង្គភាពចល័តនានា ដោយមានពួកយោធាឃុំ មកតាមចាប់ដល់ការដ្ឋានយកទៅសម្លាប់ទាំងភ្នែកស្រស់ ។ ប៉ុន្មានថ្ងៃចុងក្រោយនេះ ខ្ញុំបានឃើញមិត្តមឿន អតីតប្រធានកងខ្ញុំ កាលខ្ញុំនៅអង្គភាពចល័តឃុំ និងយោធាឃុំពីរនាក់ទៀតឧស្សាហ៍ចុះឡើងមន្ទីរមិត្តសឿង ។

រសៀលថ្ងៃមួយពេលដែលពួកខ្ញុំកំពុងតែឈរកាប់ដីពង្រាបដំបូកធំមួយ នៅពីក្រោយរោងបាយជុំគ្នាទាំងកង តែអវត្តមានមិត្តរៀម បានវិលត្រឡប់ទៅខ្ទមវិញ ។ គ្រាន់តែក្រឡេកឃើញមិត្តមឿន និងពួកយោធាពីរនាក់ទៀត លើខ្នងទំនប់ឆ្ងាយឯនាយក្បែររោងកំពុងតែឈរនិយាយគ្នាជាមួយមិត្តរៀម អាទៀត កូនខ្មែរអ៊ីស្លាមដែលមកពីភូមិទួលសង្កែជាមួយខ្ញុំទម្លាក់ចបចោលអង្គុយយំ ដោយទឹកមុខភ័យស្លាំង អាទៀត ដឹងខ្លួនច្បាស់ថាវាសនាអាក្រក់ធ្លាក់មកដល់ខ្លួនហើយពេលនេះ ។

បន្តិចក្រោយមកមិត្តរៀម បានដើរមកហៅ អាទៀត ឲ្យវិលត្រឡប់ទៅខ្ទមមួយភ្លែត ឲ្យយកទាំងចប់ទៅជាមួយផង ក្នុងសភាពដ៏ស្ងុតរន្ធត់នេះទាំងអស់គ្នាឈរទ្រើង ។ មុននឹងចេញដើរតាមពីក្រោយមិត្តរៀម ទៅអាទៀត ជាមួយនឹងទឹកភ្នែកដែលកំពុងតែហូររហាមបានពោលមកកាន់ពួកខ្ញុំជាចុងក្រោយថាៈ «បងៗទាំងអស់គ្នា ខ្ញុំសូមលាហើយ» ។

នៅលើខ្នងទំនប់ដែលមានយោធាពីរនាក់ស្ពាយកាំភ្លើងនៅនឹងស្មា និងមិត្តមឿន ដើរខ្លួនទទេ បានបណ្តើរអាទៀត ដែលកំពុងតែដើរលីចបនៅនឹងស្មាដោយខ្លួនឯងតាមបណ្តោយមាត់ស្ទឹងដែលកាន់តែខិតជិតមកដល់កន្លែងពួកខ្ញុំកាប់ដំបូក ។

អាហៀត ជាកូនខ្មែរអ៊ីស្លាមមកពីឃុំប្រាសាទ ស្ងុតខ្លាំងពេកទម្លាក់ចបចោលទៅដីអង្គុយយំតាមមើលគេ បណ្តើរអាទៀត ។ ទៅហួសពីនេះបន្តិចពួកគេចុះជិះទូកតូចមួយឆ្លងទៅត្រើយម្ខាងស្ទឹងរួចពួកយោធានាំអាទៀត យកទៅសម្លាប់ក្នុងព្រៃឫស្សីក្រាស់ក្បែរនោះបាត់ទៅ ។ អាហៀត នៅយំរៀបរាប់ថាៈ «ពួកគេសម្លាប់បងប្អូនឪពុកម្តាយអស់នៅឯភូមិ ឥឡូវពួកគេតាមមកយកខ្ញុំដល់ការដ្ឋានទៅសម្លាប់ទៀត...តើពួកខ្ញុំខ្មែរអ៊ីស្លាមមានធ្វើអីខុស?» ។

មួយស្របក់ក្រោយមកពួកយោធា និងមិត្តមឿន ឆ្លងទូកមកត្រើយម្ខាងវិញ ។ មិត្តមឿន ដើរលីចប់របស់អាទៀត ហើយនៅពេលដែលពួកយោធាទាំងពីរដើរឃ្លាតទៅមុខបន្តិច ស្រាប់តែខ្ញុំឃើញមិត្តមឿន ដើរបកក្រោយ តម្រង់មករកពួកខ្ញុំដែលកំពុងឈរកាំងជុំវិញដំបូក ។ ទាំងអស់គ្នាចោលភ្នែកមករកខ្ញុំ គ្រាដែលមិត្តមឿន បានបក់ដៃហៅចំឈ្មោះខ្ញុំឲ្យឡើងទៅជួបគាត់ដែលកំពុងតែឈររង់ចាំលើខ្នងទំនប់ ។

ពេលមកដល់ខ្ញុំបានបង្ហាញឲ្យមិត្តមឿន ឃើញនូវទឹកមុខដ៏សែនភិតភ័យ មិត្តមឿន ពេលនេះ ហាក់ដូចជាមិនមែនមិត្តមឿន ដែលជាប្រធានកងខ្ញុំធ្លាប់មានចិត្តអាណិតអាសូរចរិតស្លូតបូតគួរឲ្យគោរពនោះឡើយ ។ នៅចំពោះមុខខ្ញុំភ្នែកទាំងគូរបស់មិត្តមឿន ឡើងក្រហមដូចរងើកភ្លើង មិនដឹងស៊ីថ្លើមមនុស្សអស់ប៉ុន្មាននាក់ហើយទេ ហើយនៅពេលដែលមិត្តមឿនផ្តើមនិយាយមកកាន់ខ្ញុំ មាត់ និងដង្ហើមមានធំក្លិនស្រាយ៉ាំងខ្លាំង ។ **(តទៅលេខក្រោយ)**

**ប៉ុក ប៊ុនសូម៉ាឌ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ ញាណ សុជាតិ ទូរស័ព្ទលេខ ០៧០ ៩៨៨ ៦៦៦ ឬ អ៊ីម៉ែល ៖ truthsocheat@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ),៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានឆ្ពោះទៅរកការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 193, 2016 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.